**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការរៀបចំសណ្ដាប់ធ្នាប់ និងបរិស្ថាន ខណ្ឌច្បារអំពៅ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **ក.ជុំ សុតាន់**

**ក.ធា ស្រីពេជ្រ**

ណែនាំដោយ

លោក៖ **យ៉ុង និល**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ជុំ សុភាន់** និងនាងខ្ញុំឈ្មោះ **ទា ស្រីពេជ្រ** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែក នីតិសាស្ត្រ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០១៩-២០២៣។ សូមថ្លែងអំណរគុណ និងគោរពប្រតិបត្តិដោយសេចក្តី កត្តញ្ញូតាធម៌ ៖

## ជូនចំពោះ

- **លោកឪពុក អ្នកម្តាយ** ទាំងពីរដែលបានផ្តល់កំណើតដល់រូបកូន ព្រមទាំងបានខិតខំពុះពាររាល់ឧបសគ្គ ដើម្បីចិញ្ចឹមបីបាច់ថែរក្សាអប់រំទូន្មាន ប្រៀនប្រដៅ និងបានឧបត្ថម្ភទំនុកបម្រុងគ្រប់សព្វបែបយ៉ាងដល់ការរស់រានមានជីវិត មិនដែលខ្លាចនឿយហត់អ្វីឡើយ តាំងពីរូបកូនមិនទាន់ដឹងក្តីរហូតមកដល់ពេលនេះ កូនបានសិក្សារៀនសូត្រក្រេបយកចំណេះដឹងតាំងពីបឋមសិក្សារហូតដល់សាកលវិទ្យាល័យ ដើម្បីក្លាយជាកូនល្អ និស្សិតល្អ និងជាពលរដ្ឋល្អក្នុងសង្គម ដូចពេលនេះ។
- **ឯកឧត្តមសាកលវិទ្យាធិការ សាកលធិការរង** លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ អប់រំ ផ្តល់ចំណេះដឹង និងបទពិសោធន៍ល្អៗ ដល់យើងខ្ញុំទាំងពីរ រហូតទទួលបានជោគជ័យ និងឈានទៅដល់ការបញ្ចប់ការសិក្សានេះ។
- លោក **យ៉ុខ និល** ជាសាស្ត្រាចារ្យទទួលបន្ទុកដឹកនាំធ្វើសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដែលបានខិតខំបង្ហាត់បង្រៀន ជួយលើកទឹកចិត្ត ត្រួសត្រាយផ្លូវ និងផ្តល់ដំបូន្មានល្អៗមកដល់យើងខ្ញុំ ក៏ដូចជានិស្សិតដទៃទៀត។

ជាទីបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធិពរជ័យ សិរីសួស្តី វិបុលសុខ បវរមហាប្រសើរជូនដល់លោកអ្នកមានគុណទាំងអស់ ឱ្យទទួលបានជោគជ័យគ្រប់ភារកិច្ច និងសុខភាពល្អរឹងមាំ ព្រមទាំងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងទទួលនូវសេចក្តីរាប់អានអំពីយើងខ្ញុំ។

# អារម្ភកថា

ការរីកចម្រើននៃប្រព័ន្ធបច្ចេកវិទ្យា និងការអភិវឌ្ឍរបស់មនុស្ស គឺជាសកម្មភាពធ្វើឱ្យបរិស្ថានមានការផ្លាស់ប្តូរជាបន្តបន្ទាប់។ នៅក្នុងការដឹកនាំប្រទេសបែបទំនើបនៅពេលបច្ចុប្បន្ន មិនថាប្រទេសកំពុងតែអភិវឌ្ឍន៍ ឬប្រទេសអភិវឌ្ឍន៍ គឺតែងតែមានការយកចិត្តទុកដាក់លើការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានប្រកបដោយនិរន្តរភាពត្រូវបានរាប់បញ្ចូល និងគិតគូរជាការងារអាទិភាពលើការអភិវឌ្ឍន៍។

រាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា គឺជាមជ្ឈមណ្ឌលកណ្តាលនៃការរក្សាស្ថិរភាពនយោបាយ អភិវឌ្ឍន៍សេដ្ឋកិច្ច ការរក្សាកេរដំណែលវប្បធម៌ និងជាទីក្រុងរដ្ឋបាលសម្រាប់សហប្រតិបត្តិការអន្តរជាតិ។ រាជធានីភ្នំពេញជាទីក្រុងកំពុងអភិវឌ្ឍន៍ ជាទីក្រុងដែលមានប្រជាពលរដ្ឋកំពុងរស់នៅច្រើន នៅក្នុងប្រទេសកម្ពុជា។ ដូច្នេះហើយ ការអភិវឌ្ឍនៅរាជធានីភ្នំពេញ ក៏ដូចជានៅខណ្ឌច្បារអំពៅ គឺជាការងារដ៏សំខាន់ក្នុងការធានាឱ្យបាននូវបរិស្ថានស្អាត ទីក្រុងល្អ ដែលនាំឱ្យមានការគិតគូរដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានា ប្រព័ន្ធដឹកជញ្ជូន ការរៀបចំសណ្តាប់ធ្នាប់សាធារណៈ និងប្រព័ន្ធចរាចរណ៍ទីក្រុង ការការពារទឹកជំនន់ ការគ្រប់គ្រងសំណល់រឹង រាវ ការកាត់បន្ថយភាពក្រីក្រ ទប់ស្កាត់ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍជាច្រើនទៀត ដែលសំដៅដល់ការលើកកម្ពស់គុណភាពបរិស្ថាន សុខុមាលភាពប្រជាពលរដ្ឋ និងធានាបាននិរន្តរភាពបរិស្ថានទីក្រុងស្អាត។

យើងខ្ញុំសង្ឃឹមយ៉ាងមោះមុតថា កិច្ចការសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់យើងខ្ញុំនូវក្រោមប្រធានបទ៖ **ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានខណ្ឌច្បារអំពៅ** មួយនេះនឹងផ្តល់ជាប្រយោជន៍ដល់អ្នកសិក្សាផ្សេងៗ ដើម្បីពង្រឹងចំណេះដឹងបន្ថែមក្នុងការសិក្សាស្រាវជ្រាវមួយនេះ។ ជាងនេះទៅទៀត និងចូលរួមជួយផ្សព្វផ្សាយពីការថែរក្សាសណ្តាប់ធ្នាប់ និងបរិស្ថាន ដល់សិស្សានុសិស្ស និស្សិត និងអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ ឱ្យបានយល់ដឹងចូលរួមថែរក្សាគ្រប់ៗគ្នា។ យើងខ្ញុំសូមអភ័យទោសទុកជាមុន ទោះបីជាកិច្ចការសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រមួយនេះរបស់យើងខ្ញុំបានខិតខំប្រឹងប្រែងសរសេរយ៉ាងណាក៏ដោយ ក៏នៅមានកំហុសខុសឆ្គង អក្ខរាវិរុទ្ធ និងការបកស្រាយដោយជៀសពុំរួច។

ជាកិច្ចបញ្ចប់ យើងខ្ញុំរីករាយទទួលយកនូវការរិះគន់ កែលម្អ រាល់កំហុសខុសឆ្គង ដែលកើតឡើងដោយអចេតនាត្រង់ណាមួយពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងមិត្តទាំងអស់ដែលបានអានកិច្ចការសារណាបញ្ចប់ការសិក្សាមួយនេះ ដើម្បីស្ថាបនានូវស្នាដៃឱ្យកាន់តែពេលលេញប្រសើរឡើងប្រកបទៅបានដោយភាពត្រឹមត្រូវ ប្រកបដោយគុណភាព និងមានអត្ថប្រយោជន៍ខ្ពស់ក្នុងការលើកយកមកសិក្សាស្រាវជ្រាវបន្តទៅកាន់ប្អូនជំនាន់ក្រោយៗ។

# មាតិកា


**សេចក្តីផ្តើម** ........ ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. វិសាលភាពនៃការស្រាវជ្រាវ ........ ២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ២

៦. វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ២

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ២

**ជំពូកទី១**

**ការរៀបចំសណ្តាប់ធ្នាប់នៅខណ្ឌច្បារអំពៅ**

**១.១. ទិដ្ឋភាពទូទៅនៃខណ្ឌច្បារអំពៅ** ........ ៤

១.១.១. ប្រវត្តិសាស្រ្ត ........ ៥

១.១.២. ភូមិសាស្រ្ត ........ ៥

១.១.៣. គោលដៅ ........ ៦

**១.២. ហេតុដែលនាំឱ្យមានការរៀបចំខណ្ឌច្បារអំពៅ** ........ ៩

១.២.១. កំណើនប្រជាជន ........ ១០

១.២.២. កត្តាសេដ្ឋកិច្ច ........ ១០

១.២.៣. កត្តាសង្គម ........ ១១

១.២.៤. ស្ថានភាពសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ ........ ១១

១.២.៥. បញ្ហាចរាចរណ៍ ........ ១២

**១.៣. សមត្ថកិច្ចដែលពាក់ព័ន្ធ និងការរៀបចំ** ........ ១៦

១.៣.១. ក្រុមប្រឹក្សាខណ្ឌ ........ ១៦

១.៣.២. គណៈអភិបាលខណ្ឌ ........ ១៨

**១.៤. បច្ចុប្បន្នភាព** ........ ១៨

១.៤.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ........ ១៩

១.៤.២. ការអភិវឌ្ឍលំនៅដ្ឋាន ........ ២០

១.៤.៣. ការរៀបចំរបៀបរៀបរយ ........ ២០

**១.៥. ទិសដៅអនាគតនៃការរៀបចំ** ........ ២១

១.៥.១. ការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ........ ២១

១.៥.២. ការអភិវឌ្ឍលើទឹកស្អាត និងអនាម័យ ........ ២១

១.៥.៣. ការអភិវឌ្ឍលើវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ........ ២១

**១.៦. ដំណោះស្រាយពាក់ព័ន្ធសណ្តាប់ធ្នាប់នៅក្នុងខណ្ឌច្បារអំពៅ** ........ ២២

១.៦.១. ដំណោះស្រាយពាក់ព័ន្ធបញ្ហាសន្តិសុខសង្គម ........ ២៣

១.៦.២. ដំណោះស្រាយពាក់ព័ន្ធបញ្ហាចរាចរណ៍ ........ ២៤


## ជំពូកទី២

## សោភ័ណភាព និងបរិស្ថានក្នុងការរៀបចំខណ្ឌច្បារអំពៅ


**២.១. ការៀបចំសោភ័ណភាពពេលយប់ និងពេលថ្ងៃ** ........ ៣២

២.១.១. ការរៀបចំសោភ័ណភាពពេលយប់ ........ ៣២

២.១.២. ការរៀបចំសោភ័ណភាពពេលថ្ងៃ ........ ៣៣

**២.២. បរិស្ថានខណ្ឌច្បារអំពៅ** ........ ៣៦

២.២.១. លក្ខណៈទូទៅ និងហេតុបង្កនាំឱ្យមានការបំពុលបរិស្ថាន ........ ៣៦

២.២.២. ស្ថានភាពបរិស្ថានក្នុងខណ្ឌច្បារអំពៅ ........ ៣៦

២.២.២.១. ការបំពុលទឹក ........ ៣៧

២.២.២.២. ការបំពុលដី ........ ៣៨

២.២.២.៣. ការបំពុលខ្យល់ ........ ៣៩

២.២.២.៤. ការបំពុលសំណល់រឹង រាវ ........ ៣៩

២.២.២.៥. ការរំខានដោយសំឡេង ........ ៤១

២.២.៣. ដំណោះស្រាយពាក់ព័ន្ធ និងការបំពុលបរិស្ថានក្នុងខណ្ឌច្បារអំពៅ ........ ៤២

២.២.៣.១. ដំណោះស្រាយពាក់ព័ន្ធការបំពុលទឹក ........ ៤២

២.២.៣.២. ដំណោះស្រាយពាក់ព័ន្ធការបំពុលដី ........ ៤២

២.២.៣.៣. ដំណោះស្រាយពាក់ព័ន្ធការបំពុលខ្យល់ ........ ៤៣

២.២.៣.៤. ដំណោះស្រាយពាក់ព័ន្ធការបំពុលសំណល់រឹង រាវ ........ ៤៤

២.២.៣.៥. ដំណោះស្រាយពាក់ព័ន្ធការបំពុលដោយសំឡេង ........ ៤៤

**សេចក្តីសន្និដ្ឋាន** ........................................................................................................ ៤៦
**ការផ្តល់អនុសាសន៍** ........................................................................................................ ៤៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្ននៅប្រទេសភាគច្រើនទូទាំងសកលលោក គឺកំពុងតែយកចិត្តទុកដាក់ខ្លាំងទៅលើការថែរក្សាសណ្ដាប់ធ្នាប់ និងការរៀបចំបរិស្ថាននៅក្នុងប្រទេសរបស់ខ្លួនជានិច្ច ព្រោះវាជាបញ្ហាសំខាន់ និងជាគន្លឹះក្នុងការអភិវឌ្ឍប្រទេសរបស់ខ្លួនឱ្យឈានទៅរកភាពរីកចម្រើន។ ជាក់ស្ដែងនៅប្រទេសកម្ពុជាយើងនាពេលបច្ចុប្បន្ននេះ គឺមានការអភិវឌ្ឍស្ទើរតែគ្រប់វិស័យ គ្រប់ទីកន្លែង ដូចជា ទីក្រុង ស្រុក ខណ្ឌ សង្កាត់នានា ដែលជាតម្រូវការរបស់ប្រជាពលរដ្ឋរស់នៅតាមតំបន់នីមួយៗនៃផ្ទៃប្រទេស។

សព្វថ្ងៃនេះ ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសកំពុងតែអភិវឌ្ឍន៍ ស្របតាមការកំណត់នៃប្លង់គោលដែលបានរៀបចំឡើងដោយគណៈកម្មការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់នៅរាជធានីភ្នំពេញ។ នេះហើយជាមូលហេតុនាំឱ្យគណៈកម្មាធិការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខេត្តនីមួយៗត្រូវគូសប្លង់គោលដើម្បីធ្វើការរៀបចំ និងអភិវឌ្ឍន៍នៃរាជធានី ខេត្ត ក្រុងរបស់ខ្លួន។ ចំពោះការអភិវឌ្ឍក្នុងខណ្ឌទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង ក៏បានរៀបចំយកចិត្តទុកដាក់ទៅលើការរៀបចំសណ្ដាប់ធ្នាប់ និងបរិស្ថាន ជាបញ្ហាសំខាន់ដែលខណ្ឌនីមួយៗបាននឹងកំពុងយកចិត្តទុកដាក់កែលម្អ ឱ្យមានភាពប្រសើរឡើងស្របទៅតាមប្លង់គោល និងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដើម្បីធ្វើយ៉ាងណាឱ្យរាជធានី ក្រុង/ខេត្ត ស្រុក/ខណ្ឌ ឃុំ/សង្កាត់មានសណ្ដាប់ធ្នាប់ និងបរិស្ថានល្អ។ មូលហេតុនេះហើយទើបធ្វើឱ្យយើងខ្ញុំទាំងពីរជ្រើសរើសនូវប្រធានបទ "**ការរៀបចំសណ្ដាប់ធ្នាប់ និងបរិស្ថានខណ្ឌច្បារអំពៅ**" នេះយកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជារបាយការណ៍សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

ដោយសារតែឃើញនូវបញ្ហាប្រឈមនានា ដែលបានកើតឡើង រាជរដ្ឋាភិបាល ព្រមទាំងគណៈអភិបាលខណ្ឌច្បារអំពៅបានរៀបចំសណ្ដាប់ធ្នាប់ និងបរិស្ថាន ដូចជាធ្វើការស្ដារ និងជួសជុលប្រព័ន្ធបង្ហូរទឹក ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ នៅក្នុងខណ្ឌច្បារអំពៅ ដែលកត្តាទាំងអស់នេះហើយជាមូលហេតុនាំឱ្យមានការអភិវឌ្ឍឥតឈប់ឈរនៅក្នុងខណ្ឌច្បារអំពៅ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ឆ្លងតាមការសិក្សាស្រាវជ្រាវអស់មួយរយៈពេលកន្លងមក គឺនៅក្នុងខណ្ឌមួយរីកចម្រើនបានលុះត្រាតែយើងយល់ច្បាស់អំពីសារៈសំខាន់នៃការរៀបចំសណ្ដាប់ធ្នាប់ និងបរិស្ថាន។

១. តើមានមូលហេតុអ្វីខ្លះដែលនាំឱ្យមានការរៀបចំសណ្ដាប់ធ្នាប់នៅក្នុងខណ្ឌច្បារអំពៅ?

២. តើការរៀបចំសណ្ដាប់ធ្នាប់នៅក្នុងខណ្ឌច្បារអំពៅបានផ្ដល់ផលប្រយោជន៍អ្វីខ្លះដល់ការប្រកបរបរប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្នុងតំបន់នោះ?

៣. តើការរៀបចំសណ្តាប់ធ្នាប់អាចប្រកបដោយនិរន្តរភាពទៅបានត្រូវឈរលើការណ៍អ្វីខ្លះ ?

៤. តើមានមូលហេតុអ្វីខ្លះដែលនាំឱ្យមានការបំពុលបរិស្ថាននៅក្នុងខណ្ឌច្បារអំពៅ?

៥. តើការបំពុលបរិស្ថានក្នុងខណ្ឌច្បារអំពៅមានផលប៉ះពាល់ដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះដើម្បីៈ

- ស្វែងយល់ឱ្យបានច្បាស់អំពីការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថាននៅក្នុងខណ្ឌច្បារអំពៅ
- បញ្ហាប្រឈមពាក់ព័ន្ធសណ្តាប់ធ្នាប់ និងបរិស្ថាននៅក្នុងខណ្ឌច្បារអំពៅ
- ផ្តល់អនុសាសន៍ ដើម្បីលើកស្ទួយប្រសិទ្ធភាពនៃការអនុវត្តឱ្យកាន់តែប្រសើរឡើង។

## ៤. វិសាលភាពនៃការស្រាវជ្រាវ

គ្រប់ការសិក្សាស្រាវជ្រាវទាំងអស់គឺតែងតែមានដែនកំណត់ និងពេលវេលាច្បាស់លាស់ ដូច្នេះហើយក្នុងការសិក្សាស្រាវជ្រាវអំពីប្រធានបទមួយនេះ គឺផ្តោតទៅលើការប្រមូលព័ត៌មាន ដែលទាក់ទងទៅនឹងការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថាននៅក្នុងខណ្ឌច្បារអំពៅក្នុងឆ្នាំ២០២៣។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ដើម្បីបំផុសការយល់ដឹងជាសាធារណៈ ទៅកាន់ប្រជាពលរដ្ឋទូទៅ និងសិស្សនិស្សិត ឱ្យមានការយល់ដឹងអំពីការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថាន ក៏ដូចជាលើកកម្ពស់ស្មារតីទទួលខុសត្រូវខ្ពស់របស់ខណ្ឌច្បារអំពៅផងដែរ។ ហើយយើងខ្ញុំមានជំនឿថា របាយការណ៍ស្រាវជ្រាវសារណានេះ គឺប្រៀបដូចជាអ្នកនាំពាក្យ របស់ខណ្ឌក្នុងការចេញមុខការពារតម្លៃសកម្មភាពរួមទាំងអស់គ្នា បម្រើប្រជាពលរដ្ឋ និងទស្សនៈវិស័យរួមគ្នា ដើម្បីឱ្យមានភាពរីកចម្រើនរបស់ខណ្ឌច្បារអំពៅ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

យើងអាចប្រមូលទិន្នន័យតាមបែបគុណភាព និងបរិមាណ។ បន្ទាប់មកព័ត៌មានដែលយើងប្រមូលមកសរសេរដោយសំអាងទៅលើទាំងទិន្នន័យដែលបានពីការស្រាវជ្រាវតាមបណ្ណាល័យ តាមប្រព័ន្ធអ៊ីនធើណេត (គេហទំព័រនានា)។ ដើម្បីដំណើរការស្រាវជ្រាវនេះប្រកបដោយជោគជ័យទាមទារនូវតម្រូវការព័ត៌មានជាច្រើនដែលទទួលបានពី ឯកសារនៅក្នុងបណ្ណាល័យ តាមប្រព័ន្ធអ៊ីនធើណេត (គេហទំព័រនានា) និងឯកសារដែលលោកសាស្ត្រាចារ្យផ្តល់ឱ្យ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវនេះត្រូវបែងចែកចេញជា២ ជំពូកដូចខាងក្រោមៈ

- ជំពូកទី១ ការរៀបចំសណ្តាប់ធ្នាប់នៅខណ្ឌច្បារអំពៅ

- ជំពូកទី២ សោភ័ណភាព និងបរិស្ថានក្នុងការរៀបចំខណ្ឌច្បារអំពៅ

បន្ទាប់ពីធ្វើការបង្ហាញទាំង ២ ជំពូកខាងលើ យើងខ្ញុំក៏មានសេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ទៅលើសារណានេះផងដែរ។

# ជំពូកទី១

# ការរៀបចំសណ្តាប់ធ្នាប់នៅខណ្ឌច្បារអំពៅ

# ជំពូកទី១
# ការរៀបចំសណ្តាប់ធ្នាប់នៅខណ្ឌច្បារអំពៅ

## ១.១. ទិដ្ឋភាពទូទៅនៃខណ្ឌច្បារអំពៅ

ដើម្បីងាយស្រួលដល់ការកំណត់អត្ថន័យនៃអត្ថបទទាំងមូល ការកំណត់និយមន័យនៃពាក្យគន្លឹះ ដែលមាននៅក្នុងប្រធានបទជាមុនជាការចាំបាច់។ ពាក្យគន្លឹះទាំងនោះមានដូចជា៖ សណ្តាប់ធ្នាប់ និងបរិស្ថាន។

- **សណ្តាប់ធ្នាប់៖** សំដៅដល់ការទុកដាក់របស់ឱ្យមានរបៀបរៀបរយ ទុកដាក់តាមរបៀប[1] មានសន្តិសុខ មានភាពស្ងប់ស្ងៀម និងគ្មានការបំពុលទាំង៥។[2]
- **បរិស្ថាន៖** សំដៅអ្វីៗដែលមាននៅជុំវិញខ្លួនយើងដែលរាប់មានភាវៈមានជីវិតទាំងអស់នៅលើផែនដីមានទំនាក់ទំនងគ្នាទៅវិញទៅមក ហើយអាចជះឥទ្ធិពលពីគ្នាទៅវិញទៅមកដោយផ្ទាល់ និងដោយប្រយោល។[3]

ស្ថានភាពបញ្ហាសណ្តាប់ធ្នាប់នៅក្នុងរយៈពេលប៉ុន្មានឆ្នាំបានផ្សារភ្ជាប់ជាមួយ បញ្ហាប្រឈមជាមួយជម្ងឺរីករាលដាលកូវីដ១៩ ដែលកើតឡើងនាពេលបច្ចុប្បន្ននេះ។ យើងបញ្ជាក់ឱ្យឃើញថា ការរៀបចំសណ្តាប់ធ្នាប់នៅក្នុងខណ្ឌច្បារអំពៅនៅទីសាធារណៈត្រូវបានរដ្ឋបាលខណ្ឌធ្វើការយកចិត្តទុកដាក់យ៉ាងខ្លាំងណាស់ សម្រាប់ការថែរក្សាសន្តិសុខ ការពារសុវត្ថិភាព ព្រមទាំងការរៀបចំសណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋ នៅក្នុងខណ្ឌច្បារអំពៅទាំងអស់រស់នៅប្រកបដោយភាពត្រឹមត្រូវផងដែរ។ ប៉ុន្តែសណ្តាប់ធ្នាប់ក្នុងខណ្ឌច្បារអំពៅ គឺជាបញ្ហាមួយផងដែរសម្រាប់រដ្ឋបាលខណ្ឌ និងប្រជាពលរដ្ឋមួយចំនួនដែលបានបំពានច្បាប់ ដែលជាហេតុធ្វើឱ្យសណ្តាប់ធ្នាប់ក្នុងខណ្ឌច្បារអំពៅមិនទាន់មានភាពល្អប្រសើរនៅឡើយទេ។ បញ្ហាទាំងអស់នេះហើយ គឺជាបញ្ហាដ៏សំខាន់មួយដែលអាជ្ញាធរខណ្ឌច្បារអំពៅ ត្រូវតែយកចិត្តទុកដាក់ និងរកដោះស្រាយបញ្ហាឱ្យទាន់សភាពការណ៍ និងត្រូវព្យាយាមផ្សព្វផ្សាយច្បាប់ផ្សេងៗ ដែលពាក់ព័ន្ធនឹងការរៀបចំសណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋ និងបង្ហាញដោយភាពទន់ភ្លន់ ដើម្បីឱ្យប្រជាជនពលរដ្ឋងាយស្រួលក្នុងការយល់ដឹងអំពីច្បាប់ និងគោលដៅដែលរដ្ឋបាលខណ្ឌមានផែនការយុទ្ធសាស្ត្រនាពេលអនាគត។ ម៉្យាងវិញទៀត មុននឹងឈានដល់ការរៀបចំ ឬការអភិវឌ្ឍយើងត្រូវពិនិត្យមើលទៅតាមប្លង់គោល ដែលបានកំណត់ជាមុនសិន ក្នុងការរៀបចំ ឬការអភិវឌ្ឍរាជធានីភ្នំពេញ។ ប្លង់គោលជាឯកសារ ឬជាគម្រោងដែលមានលក្ខណៈជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍរាជធានីភ្នំពេញ។ ប្លង់គោលជាប្លង់គ្រឹះ និងជាតម្រង់ទិសក្នុងការបែងចែកកំណត់ផ្ទៃដី សម្រាប់តំបន់សាងសង់ តំបន់ចាក់សំរាម តំបន់សាលារៀន តំបន់ដែលត្រូវរក្សាការពារតំបន់ដែលត្រូវអភិវឌ្ឍន៍។ ក្នុងនោះផងដែរ បានកំណត់នៅក្នុងច្បាប់ស្តីពីការរៀបចំដែនដីនគ

[1] វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត

[2] សៀវភៅ នីតិនគរូបនីយវិទ្យា បណ្ឌិត អ៊ុន សកក្កដា ឆ្នាំ២០២៣ ទំព័រទី ១។

[3] ដកស្រង់ តើបរិស្ថានគឺជាអ្វី – អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (bcv-cambodia.org)

រូបនីយកម្ម និងសំណង់ដែលបានចែងក្នុងមាត្រា៧ បានចែងថាដីអាចសាងសង់បាន ឬសាងសង់មិនបានមាន ដូចជា៖

- តំបន់សម្រាប់ការពារជាតិ
- តំបន់សម្រាប់ពាណិជ្ជកម្ម
- តំបន់កសិកម្ម ឧស្សាហកម្ម
- តំបន់សិប្បកម្ម
- តំបន់ទេសចរណ៍
- តំបន់វប្បធម៌ សាសនា
- តំបន់សម្រាប់សំណង់នៃរដ្ឋបាល និងបរិក្ខារសាធារណៈ។[4]

### **១.១.១. ប្រវត្តិសាស្ត្រ**

ដំបូងឡើងច្បារអំពៅជាចំណុះនៃខេត្តកណ្ដាលរហូតដល់ឆ្នាំ១៩៩៨ ច្បារអំពៅបានក្លាយជាសង្កាត់មួយខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ខណ្ឌច្បារអំពៅ បានបង្កើតឡើងយោងតាមអនុក្រឹត្យ របស់រាជរដ្ឋាភិបាល លេខ ៥៧៩ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ត្រូវបានបង្កើតខណ្ឌច្បារអំពៅ[5] នៃរាជធានីភ្នំពេញ ដោយកាត់យក សង្កាត់ចំនួន៨ ពីខណ្ឌមានជ័យ នៃរាជធានីភ្នំពេញ។

### **១.១.២. ភូមិសាស្ត្រ**

ខណ្ឌច្បារអំពៅ ជាខណ្ឌមួយដែលបានបំបែកចេញពីខណ្ឌមានជ័យ។ នៅក្នុងរបបសាធារណៈរដ្ឋខ្មែរ ឃុំច្បារអំពៅត្រូវបានប្ដូរជាខណ្ឌច្បារអំពៅក្រុងភ្នំពេញ។ ដូច្នេះហើយទើបរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតខណ្ឌច្បារអំពៅនៃរាជធានីភ្នំពេញដោយកាត់យក សង្កាត់ចំនួន៨ ពីខណ្ឌមានជ័យ នៃរាជធានីភ្នំពេញគឺ៖

- សង្កាត់ច្បារអំពៅទី១
- សង្កាត់ច្បារអំពៅទី២
- សង្កាត់ព្រែកប្រា
- សង្កាត់និរោធ
- សង្កាត់ព្រែកថ្មី
- សង្កាត់ក្បាលកោះ
- សង្កាត់ព្រែកឯង

[4] មាត្រា៧ ច្បាប់ស្ដីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

[5] អនុក្រឹត្យ លេខ៥៧៩ អនក្រ.បក ស្ដីពីការបង្កើតខណ្ឌច្បារអំពៅនៃរាជធានីភ្នំពេញ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣។

- សង្កាត់វាលស្បូវ។

ខណ្ឌច្បារអំពៅត្រូវបានសម្ពោធឡើងជាផ្លូវការនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤។ មានព្រំប្រទល់ខាងជើងទល់នឹងទន្លេមេគង្គ ស្រុកល្វាឯម ខេត្តកណ្តាល ខាងត្បូវទល់នឹងទន្លេបាសាក់ ក្រុងតាខ្មៅ និងស្រុកស្អាង ខេត្តកណ្តាល ខាងលិចទល់នឹងទន្លេបាសាក់ ខណ្ឌមានជ័យ និងក្រុងតាខ្មៅ ខេត្តកណ្តាល ខាងកើតទល់នឹងស្រុកកៀនស្វាយខេត្តកណ្តាល។

នាពេលបច្ចុប្បន្នខណ្ឌច្បារអំពៅមានផ្ទៃដីសរុប៨០.៩៥ហិចតា០.៨៥១ម៉ែត្រការ៉េក្នុងនោះផងដែររួមមានផ្ទៃដីកសិកម្ម ៣៤៩ហិចតា ផ្ទៃដីលំនៅដ្ឋាន៧.៦៦៧ហិចតា ៨៥៥១ម៉ែត្រការ៉េ។

នៅក្នុងខណ្ឌច្បារអំពៅមានទន្លេចំនួន២ គឺទន្លេបាសាក់ និងទន្លេមេគង្គក្រោម។ ដែលក្នុងនោះផ្ទៃទឹកមានព្រែកចំនួន៥១ហិចតា ៧២ម៉ែត្រការ៉េ និងប្រឡាយចំនួន២៤ហិចតា ៥១ម៉ែត្រការ៉េ។

ទីតាំងនៃសាលាខណ្ឌច្បារអំពៅ គឺស្ថិតនៅសាលាខណ្ឌមានជ័យចាស់ រីឯសាលាខណ្ឌមានថ្មី ស្ថិតនៅសាលាចាក់អង្រែក្រោម។

**១.១.៣. គោលដៅ**

ក្នុងការរៀបចំខណ្ឌច្បារអំពៅជាលក្ខណៈពិធីការមួយ គឺត្រូវបានសង្កេតឃើញឈរក្រោមសសរស្តម្ភចំនួន៥ រួមមាន៖

- ផលិតភាព
- និរន្តរភាព
- ភាពដែលអាចរស់នៅបាន
- ភាពជាអ្នកដឹកនាំ
- ការរចនាដ៏ល្អប្រសើរ។

ជារួមមានន័យថា ត្រូវធ្វើយ៉ាងណាបង្កើតកន្លែងមួយដែលមាន ផលិតភាព និរន្តរភាព និងភាពអាចរស់នៅបានតាមរយៈភាពជាអ្នកដឹកនាំ និងការរួមបញ្ចូលគ្នានៃការរចនាខណ្ឌមួយដ៏ល្អប្រសើរ។[6]

❖ **ការរៀបចំទីកន្លែងមួយឱ្យមានផលិតភាព និងនិរន្តរភាពតាមរយៈ**

- ការលើកកម្ពស់ សកម្មភាពសេដ្ឋកិច្ចនៅក្នុងខណ្ឌ ដោយបង្កើតឱ្យមានការលើកទឹកចិត្ត និងការអនុវត្តក្នុងកាប្រកបអាជីវកម្មផ្សេងៗ នាំឱ្យមានភាពសម្បូរបែបនៃការប្រកបរបរទទួលទានបាន ស្របពេល ឱ្យបាននូវតម្រូវការយ៉ាងហោចណាស់ ជាមូលដ្ឋាន និងចាំបាច់សម្រាប់អ្នកធ្វើការ និងអ្នករស់នៅទីនោះ។

[6] សៀវភៅ នីតិនគរូបនីយវិទ្យា បណ្ឌិត អ៊ុន សកក្កដា ឆ្នាំ២០២៣ ទំព័រទី ៤៩។

លើសពីនេះពង្រឹង និងពង្រីកការសាងសង់ដែលមានលក្ខណៈជួយដល់បរិស្ថាន ទាំងរូបភាព គុណភាព មុខងារ និងការមើលឃើញ (ប្រព័ន្ធបៃតង)។

- ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ ផ្ទៃក្រឹងជាមួយនឹងសង្គម ដោយធានាបានថានៅក្នុងខណ្ឌ មានផ្លូវដែលតភ្ជាប់គ្នាបានល្អដែលឱ្យអ្នកនៅក្នុងខណ្ឌនោះ អាចដឹងកន្លែងដែលខ្លួនកំពុងនៅ និងងាយស្រួយរកឃើញកន្លែងដែលខ្លួនចង់ទៅ ព្រមទាំងតភ្ជាប់កន្លែងធ្វើការងារ សាលារៀន ផ្សារលក់ទំនិញ និងកន្លែងផ្តល់សេវាផ្សេងៗ។ និយាយបែបផ្សេង គឺត្រូវឱ្យមានដាច់ខាតនូវការតភ្ជាប់ផ្លូវដើរទៅកាន់តំបន់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រជាមួយសហគមន៍ និងអ្នកទេសចរណ៍។ បន្ថែមពីនេះទៅទៀត បង្កើតឱ្យមានភាពសម្បូរបែបនៃមធ្យោបាយធ្វើដំណើរដូចជា៖ ការដឹកជញ្ជូនសាធារណៈ ដើរ ឬជិះកង់ ដែលអ្នកធ្វើដំណើរមានអារម្មណ៍ថា ខ្លួនមានការផ្សារភ្ជាប់ ជាមួយធម្មជាតិ និងបរិស្ថានបៃតង ដែលខ្លួនកំពុងរស់នៅជាមួយ។
- ការធ្វើពិពិធកម្មនៃជម្រើស និងបទពិសោធន៍៖ ធ្វើឱ្យសហគមន៍នីមួយៗមានលក្ខណៈពិសេសផ្សេងៗគ្នា។ លើសពីនេះទៀតបង្កើតឱ្យមាននូវភាពសម្បូរបែប បរិក្ខារ សេវា និងសកម្មភាពផ្សេងៗដែលស្តែងចេញពីសុខដុមនីយកម្មសង្គម។ ដោយឡែក ការធ្វើផ្លូវក្នុងខណ្ឌអាចអនុញ្ញាតឱ្យអ្នកដំណើរជ្រើសរើសផ្លូវផ្សេងទៅតាមអារម្មណ៍ ប្រសិនបើអ្នកចង់ទៅកន្លែងមួយនៅក្នុងខណ្ឌ ដោយបង្កើតឱ្យពួកគេនូវបទពិសោធន៍ផ្សេងតាមរយៈការមិនធ្វើជម្រើសនៃលំនៅដ្ឋានច្រើនម៉ូត។ ផងដែរនោះ គឺត្រូវបំពេញនូវធាតុចាំបាច់មួយទៀត គឺជីវចម្រុះដែលរួមបញ្ចូលទាំងរុក្ខជាតិ និងសត្វផងដែរ។
- ការធ្វើឱ្យនិរន្តរភាព និងកាត់បន្ថយជាអតិបរិមានូវហានិភ័យដែលបណ្តាលមកពីការផ្លាស់ប្តូរអាកាសធាតុគ្រោះធម្មជាតិតាមរយៈការកសាងនូវប្រព័ន្ធសុវត្ថិភាព នៅកន្លែងសមរម្យដែលមាន គុណភាពល្អមានភាពរឹងមាំ និងមានការតាមដានថែរក្សាជាប្រចាំ។ បន្ថែមពីនេះទៅទៀត មានការរក្សាទុកនូវធនធានជាមូលដ្ឋានចាំបាច់នៅពេលមានគ្រោះអាសន្នដូចជា៖ អគ្គីសនី ទឹក និងស្បៀងអាហារដែលការសាងសង់ និងរក្សាទុកធនធានមូលដ្ឋានទាំងនេះ មានផលប៉ះពាល់តិចបំផុតដល់បរិស្ថាន និងធនធានបានថាអាចយកមកប្រើបាននៅពេលមានការបន្ទាន់យ៉ាងពិតប្រាកដ។[7]

**❖ ការរៀបចំទីកន្លែងមួយឱ្យមនុស្សអាចរស់នៅបានតាមរយៈ៖**

- ធ្វើឱ្យមានផាសុខភាពដែលជា ភាពងាយស្រួយនៅក្នុងការដើរហើរ ឈរ អង្គុយ និងសម្រាកកម្សាន្តលំហែដែលមិនត្រូវបានរំខានដោយភ្លៀង ខ្យល់ សំឡេង សំរាម កម្តៅ ការបំពុលបរិស្ថាន និងចរាចរណ៍អ្វីឡើយ។ លើសពីនេះគេអាចប្រើប្រាស់កន្លែងនោះដោយសេរីចំពោះខ្លួនម្នាក់ៗ ដោយមិនចាំបាច់

[7]សៀវភៅ នីតិនគរូបនីយវិទ្យា បណ្ឌិត អ៊ុន សកក្កដា ឆ្នាំ២០២៣ ទំព័រទី ៥១។

ចំណាយអ្វីឡើយ។ ក្នុងន័យនេះ ធ្វើយ៉ាងណាឱ្យមនុស្សម្នាក់មានអារម្មណ៍ថាខ្លួនគេជាផ្នែកមួយនៃសហគមន៍ដោយធ្វើការអភិវឌ្ឍ និងការរៀបចំទាំងឡាយណាអាចបំពេញបានទាំងចំណង់ចំណូលចិត្តរបស់មនុស្សវ័យក្មេង និងវ័យចាស់។

- ធ្វើឱ្យមានភាពរស់រវើកដោយធ្វើឱ្យបុគ្គលម្នាក់ៗមានអារម្មណ៍ថាមានមនុស្សអ្នកដទៃនៅទីនោះដែរ ដែលធ្វើការយ៉ាងសកម្មភាពក្នុងអង្គភាព និងក្រុមហ៊ុនរបស់គេរៀងៗខ្លួន ហើយមានកន្លែងសម្រាប់ជួបជុំសម្រាកកម្សាន្ត លំហែ ពិភាក្សា និងកាត់បន្ថយភាពតានតឹងដែលជាកន្លែងមនុស្សម្នាក់ចង់ទៅ និងចង់រស់នៅ។
- ធ្វើឱ្យមានសុវត្ថិភាពជាអតិបរិមាមិនថាយប់មិនថាថ្ងៃនៅក្នុងខណ្ឌ លើបញ្ហា សណ្តាប់ធ្នាប់ សន្តិសុខ និងលុបបំបាត់សញ្ញាណនៃភាពពុកផុយដូចជា សម្ភារចាស់ៗ ដែលបង្កបង្កើតឱ្យមានគ្រោះថ្នាក់រួមមាន៖ រូបគំនូរ បង្គោលភ្លើងចាស់ៗ អាគារចាស់ទ្រុឌទ្រោម (មិនអនុញ្ញាតឱ្យមនុស្សរស់នៅឡើយ)។ ជាពិសេសបង្កើតឱ្យមានផ្លូវសម្រាប់មនុស្សដើរ ដែលមានសុវត្ថិភាពបំផុត សម្រាប់សិស្ស ប្រជាជន និងមនុស្សចាស់ជរាធ្វើដំណើរ។
- អាចធ្វើឱ្យមនុស្សដើរ ឬធ្វើសកម្មភាពផ្សេងៗបានដោយងាយស្រួលតាមរយៈការផ្តល់អាទិភាពខ្ពស់ចំពោះអ្នកធ្វើដំណើរដោយថ្មើរជើង ឬជិះកង់ ឬរទេះ និងអ្នកលើកដាក់វ៉ាលីឥវ៉ាន់ផ្សេងៗមានភាពងាយស្រួលដំណើរដោយធ្វើការស្ថាបនាផ្លូវចិញ្ចើមផ្លូវ នៅខាងស្តាំដដែលមានទំហំធំ សមស្របសម្រាប់ពួកគេដែលលើកកម្ពស់មិនត្រឹមសកម្មភាពរាងកាយ និងទំនាក់ទំនងសង្គមទេថែមទាំងលើកកម្ពស់សុខភាពមនុស្សទៀតផង។

❖ **ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចតាមរយៈ៖**

- ធ្វើគម្រោងការឱ្យសមស្របទៅតាមស្ថានភាពប្រជាសាស្ត្រសង្គម និងសេដ្ឋកិច្ច ដែលមានការកំណត់ពីចក្ខុវិស័យច្បាស់លាស់ រួមបញ្ចូលគ្នាទាំងការគិតគូរលើបរិស្ថាន សណ្ឋានដី ជីវចម្រុះ ទិដ្ឋភាព និងការមើលឃើញទូទៅពាក់ព័ន្ធនឹងប្រព័ន្ធផ្លូវ បណ្តាញបង្ហូរ សំណង់អាគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដើម្បីឱ្យមានរូបរួមគំនិតគ្នាជាមួយបេតិកភណ្ឌវប្បធម៌ និងប្រវត្តិសាស្ត្រដែលអាចអាចឆ្លើយតប ជាមួយសកម្មភាពសង្គមសេដ្ឋកិច្ច នៅតំបន់ជុំវិញនោះ។
- បង្កើនការចូលរួមពីសំណាក់គ្រប់ដៃគូរពាក់ព័ន្ធ ដោយណែនាំគាត់អំពីគោលការណ៍នៃការរៀបចំខណ្ឌថាជាមូលដ្ឋាននៃការរៀបចំកន្លែងសម្រាប់ពួកគាត់រស់នៅ ដូច្នេះត្រូវចូលរួមសកម្មភាពអភិវឌ្ឍទាំងអស់គ្នាទើបអាចសម្រេចនូវសុបិន្តនេះបាន។

- ធ្វើឱ្យមានភាពល្អប្រសើរ និងគំនិតផ្តួចផ្តើមឱ្យមានភាពអ្នកជាដឹកនាំ តាមរយៈការផ្តល់អាទិភាពខ្ពស់ចំពោះគម្រោងការលទ្ធកម្ម វិស្វកម្ម ការរចនាទាំងឡាយណាដែលធ្លាប់ទទួលបានជោគជ័យនៅក្នុងការរៀបចំក្រុងនៃប្រទេសដទៃយកមកអនុវត្តក្នុងការរៀបចំខណ្ឌខ្លួន។ លើសពីនេះបញ្ចូលនូវអ្វីដែលមានបានគ្រោងទុកពីដំណាក់កាលដំបូងនៃការរៀបចំខណ្ឌ រហូតដល់ដំណាក់កាលបញ្ចប់ ដែលក្នុងដំណើរការនោះមានទាំងអ្នកមានជំនាញ ក្នុងការរៀបចំចូលរួមធ្វើ និងចូលរួមផ្តល់ការណែនាំ។
- មានអ្នកការពារ និងតាមដានថែរក្សាជាប្រចាំ ៖ ពីព្រោះខណ្ឌ បរិស្ថាន និងសហគមន៍ជារឿងដែលមានបរិវត្តន៍ភាព ដូច្នេះត្រូវរក្សាឱ្យបានលក្ខខណ្ឌនៅក្នុងការកែប្រែឱ្យបានល្អប្រសើរ ជាប្រចាំទើបអាចបំពេញបានតម្រូវការដាក់លាក់របស់មនុស្សក្នុងខណ្ឌនោះ ស្របពេលជាមួយគ្នានោះគឺ ត្រូវធ្វើការថ្លឹងថ្លែងអំពីផលប៉ះពាល់ និងគុណប្រយោជន៍ដែលទទួលបានផងដែរ។ ក្នុងន័យនេះ គឺត្រូវធានាថារាល់ការរចនារៀបចំកន្លែងនីមួយៗ គឺអំណោយផលដល់ការធ្វើប្រតិបត្តិការថែរក្សាជាប្រចាំ ជាពិសេសនៅពេលមានគ្រោះអាសន្នផ្សេងៗ។[8]

## ១.២. ហេតុដែលនាំឱ្យមានការរៀបចំខណ្ឌច្បារអំពៅ

សព្វថ្ងៃរាល់ការអភិវឌ្ឍទាំងឡាយ ឬធ្វើអ្វីមួយបានទាល់តែមានការរៀបចំគម្រោងដើម្បីរៀបចំ ឬធ្វើផែនការជាមុន។ ទន្ទឹមនឹងនេះ មុននឹងឈានដល់ការរៀបចំ ឬអភិវឌ្ឍន៍អ្វីមួយ គឺបណ្តាលមកពីភាពខ្វះខាតដែលហេតុនាំកើតមានឡើងនូវបញ្ហាផ្សេងៗផងដែរ។ យ៉ាងណាមិញយើងក្រឡេកមើលទៅ តាមបណ្តាលតំបន់នានាដូចជា៖ ភូមិ ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត/ក្រុង ក្នុងប្រទេសនានា ក៏ដូចជាប្រទេសកម្ពុជារបស់យើង តែងតែមានការរៀបចំនូវគម្រោង ឬដាក់ផែនការសកម្មភាពអភិវឌ្ឍនៅតាមតំបន់នានា ដែលកំពុងជួបនូវបញ្ហាខ្វះខាតដែលនឹងត្រូវមានការរៀបចំឱ្យមានសណ្តាប់ធ្នាប់ សំដៅដល់ការរៀបចំឱ្យកាន់តែប្រសើរឡើងជាងមុន។

ដូចច្នេះហើយ ផលដែលយើងបានមកពីរៀបចំខណ្ឌដូចជា៖

- ផ្លូវថ្នល់
- ប្រព័ន្ធលូ
- ប្រព័ន្ធដឹកជញ្ជូនសាធារណៈ (រថយន្តក្រុងសាធារណៈ)
- ការបំពាក់ភ្លើងសញ្ញាចរាចរណ៍
- ភ្លើងបំភ្លឺផ្លូវសាធារណៈ
- ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត

[8] សៀវភៅ នីតិនគរូបនីយវិទ្យា បណ្ឌិត អ៊ុន សកក្កដា ឆ្នាំ២០២៣ ទំព័រទី ៥២។

- ប្រកបដោយ អនាម័យ សន្តិសុខ ស្ងៀមស្ងាត់សម្រាប់ប្រជាពលរដ្ឋ។[9]

លទ្ធផលនៃការរៀបចំទាំងនេះហើយ គឺជាបញ្ហាដែលគួរគប្បីធ្វើការយកចិត្តទុកដាក់រៀបចំ ការថែរក្សាការពារ និងអភិវឌ្ឍន៍ជារៀងរាល់ឆ្នាំ ដើម្បីធ្វើឱ្យខណ្ឌមានសណ្តាប់ធ្នាប់ល្អ។ ការរៀបចំក្រុង គឺជាកត្តាមួយដែលអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវធ្វើការយកចិត្តទុកដាក់ឱ្យបានហ្មត់ចត់ ហើយបុព្វហេតុនៃការរៀបចំខណ្ឌច្បារអំពៅមានកត្តាមួយចំនួនដូចខាងក្រោមះ

**១.២.១. កំណើនប្រជាជន**

ជាទូទៅ មាននូវសមាសភាពនៃកំណើនប្រជាពលរដ្ឋក្នុងទីក្រុង៣សំខាន់ៗះ កំណើនដោយចំណាកស្រុកពីជនបទ និងកំណើនប្រជាពលរដ្ឋក្នុងក្រុងជាលក្ខណៈធម្មជាតិ បានធ្វើឱ្យមានការកើនឡើងយ៉ាងល្បឿនរហ័សនៃចំនួនប្រជាពលរដ្ឋ ចំណែកកំណើនដោយសារមានចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែក ប្រភេទសណ្ឋាននៃក្រុងថ្មី ដែលពីមុនមកតំបន់នេះ ជាទីជនបទគ្រាន់តែជាធាតុចូលបន្ទាប់បន្សំប៉ុណ្ណោះ។[10]

ជាក់ស្តែងនៅរាជធានី មានប្រជាជនរស់នៅសរុបប្រមាណជាង ១,៤៧០,៣០៣នាក់ (ឆ្នាំ២០១៨) ក្នុងនោះផងដែរ មានស្ត្រីចំនួន៩៦០,០៨១នាក់ ហើយចែកចេញគ្រួសារ គឺមានចំនួន ៣០៤,៧៦៧គ្រួសារ។[11]

**១.២.២. កត្តាសេដ្ឋកិច្ច**

ខណ្ឌច្បារអំពៅ គឺនៅជាយខាងត្បូងត្រើយខាងកើត នៃសាលារាជធានីភ្នំពេញក៏ពិតមែន តែជាខណ្ឌមួយស្ថិតក្នុងដែនដីសមត្ថកិច្ចនៃរាជធានីភ្នំពេញ ដែលជាបេះដូងរបស់ព្រះរាជាណាចក្រកម្ពុជា។ រាជធានីភ្នំពេញចែកចេញជា១៤ ខណ្ឌ ហើយខណ្ឌទាំងនោះត្រូវបានបែងចែកទៅជា ១០៥សង្កាត់ និង៩៥៣ភូមិ។[12]

យ៉ាងណាមិញ ចំពោះស្ថានភាពសេដ្ឋកិច្ចនៅក្នុងខណ្ឌច្បារអំពៅ ក៏មិនខុសគ្នាពីខណ្ឌផ្សេងៗនៃរាជធានីភ្នំពេញដែរ គឺសេដ្ឋកិច្ចកំពុងតែមានសន្ទុះយ៉ាងខ្លាំងក្លា អាស្រ័យដោយស្ថានភាពនយោបាយនៅប្រទេសកម្ពុជាប្រកបដោយសាមគ្គីភាព ភាពត្រឹមត្រូវ ច្បាស់លាស់ រឹងមាំ និងការទំនាក់ទំនងការទូទាត់ល្អទាំងថ្នាក់តំបន់ ថ្នាក់សហគមន៍ និងពិភពលោក ដែលជានាំឱ្យកម្ពុជាទទួលបាននូវសន្តិសុខ ស្ថេរភាពនយោបាយ។ ខណ្ឌច្បារអំពៅគឺជាមជ្ឈមណ្ឌលសេដ្ឋកិច្ចយ៉ាងសំខាន់មួយក្នុងការធ្វើជំនួញពាណិជ្ជកម្ម ឧស្សាហកម្ម និងជាបណ្តុំការងារច្រើន

[9] សៀវភៅ នីតិនគរូបនីយវិទ្យា បណ្ឌិត អ៊ុន សកក្កដា ឆ្នាំ២០២៣ ទំព័រទី ១៦។

[10] សៀវភៅ នីតិនគរូបនីយវិទ្យា បណ្ឌិត អ៊ុន សកក្កដា ឆ្នាំ២០២៣ ទំព័រទី ១៧។

[11] https://phnompenh.gov.kh/phnom-penh-city/facts/ ដកស្រង់ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣

[12] https://phnompenh.gov.kh/phnom-penh-city/facts/ដកស្រង់ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៣

មានដូចជាបណ្តុំសំណង់ អាគារធំៗជាច្រើនរួមបញ្ចូលទាំងទីផ្សារ និងផ្សារទំនើប សាលារៀនជាច្រើន សម្រាប់សិស្សានុសិស្សសិក្សារៀនសូត្រ កំពង់ផែផ្លូវទឹក និងកំពង់ផែផ្លូវគោក ជាពិសេសគឺផ្លូវជាតិលេខ១ សម្រាប់ផ្គត់ផ្គង់ការដឹកជញ្ជូន និងផ្ទុកទំនិញផ្សេងៗ និងជាកន្លែងទេសចរណ៍កម្សាន្តរមណីយដ្ឋាន ដែលអាចទាក់ទាញភ្ញៀវទេសចរណ៍ជាតិ ភ្ញៀវអន្តរជាតិបានយ៉ាងច្រើនកុះករផងដែរ។

### ១.២.៣. កត្តាសង្គម

ចំពោះស្ថានភាពសង្គមកិច្ចក្នុងខណ្ឌច្បារអំពៅ ដែលក្នុងនោះរួមមានដូចជា ការអប់រំ កីឡា សុខាភិបាល យ៉េនឌ័រ សន្តិសុខជាដើម ដែលជាកិច្ចការទាំងឡាយ មានគោលដៅបម្រើផលប្រយោជន៍រួមសង្គម។ ក្នុងខណ្ឌច្បារអំពៅ ក៏បានខិតខំបម្រើប្រជាពលរដ្ឋខ្លួនតាមរយៈការកសាងផ្លូវ ថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ ផ្ទះសម្បែង វត្តអារាមនានា ការជួយសង្គ្រោះជនរងគ្រោះដោយសារហានិភ័យ គ្រោះធម្មជាតិ ការបង្ក្រាបល្បែងស៊ីសង ការកម្ចាត់ជនទុច្ចរិត។ល។

រីឯស្ថានភាពវប្បធម៌ និងសាសនាវិញ ក៏មិនខុសគ្នាអំពីផ្នែកសង្គមកិច្ចដែរ គឺថាប្រជាពលរដ្ឋគ្រប់រូបទាំងនៅក្នុងដែនសមត្ថកិច្ច និងមជ្ឈដ្ឋាននានាមានភាពសប្បាយរីករាយ មានសិទ្ធិសេរីភាពពេញលេញចំពោះការគោរពអនុវត្តទៅលើទំនៀមទម្លាប់ ប្រពៃណី វប្បធម៌ និងសាសនារបស់ខ្លួន ដោយមិនមានការហាមឃាត់ ឬបំបិទសិទ្ធិសេរីភាពនោះទេ។ កត្តាទាំងនេះហើយ ដែលជាហេតុនាំឱ្យមាននូវសាមគ្គីភាព សុខសាន្ត សុភមង្គលដែលកើតចេញពីការគោរពស្រលាញ់ និងឱ្យតម្លៃគ្នាទៅវិញទៅមក។

### ១.២.៤. ស្ថានភាពសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់

ដោយសារតែប្រទេសកម្ពុជា គឺជាប្រទេសដែលកំពុងអភិវឌ្ឍន៍ ដូច្នេះបញ្ហាប្រឈមមួយចំនួន គឺតែងតែកើតមានគ្រប់ទីកន្លែង ដោយហោចណាស់ទៅសូម្បីប្រទេសដទៃក៏មានបញ្ហាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ដូចគ្នាដែរ។ សម្រាប់ស្ថានភាពសន្តិភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងខណ្ឌច្បារអំពៅក៏មានការជួបប្រទះផងដែរនូវអំពើលួច ឆក់ ប្លន់ រំលោភសេពសន្ថវៈ កាប់សម្លាប់ ល្បែងស៊ីសង គ្រឿងញៀន គ្រោះថ្នាក់ចរាចរណ៍ ការកកស្ទះ និងការល្មើសច្បាប់នានា ដែលជាកត្តានាំឱ្យមានអសន្តិសុខមួយចំនួនតូចក្នុងខណ្ឌផងដែរ។

ដើម្បីធានាដល់ការរស់នៅមានការការពារសុវត្ថិភាព ដល់ប្រជាពលរដ្ឋអាជ្ញាធរគ្រប់ជាន់ថ្នាក់នៅក្នុងខេត្តក្រុងត្រូវយកចិត្តទុកដាក់ជាខ្លាំង នូវការថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈជូនប្រជាជន ដែលអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងផែនការណែនាំស្តីពី ការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ដែលមានលក្ខណៈសម្បត្តិ៥យ៉ាង។ នាពេលបច្ចុប្បន្នរាជរដ្ឋាភិបាល

បានរៀបចំកែលម្អលក្ខណៈសម្បត្តិគោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព បន្ថែមរហូតដល់៧ចំណុច ដូចខាងក្រោម៖

- គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ
- ផ្តល់សេវាសាធារណៈជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត។
- គ្មានអំពើអានាចារ ការជួញដូរស្ត្រី កុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង
- មានសណ្តាប់ធ្នាប់ល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍
- ដោះស្រាយវិវាទការនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធិភាព
- មានអនាម័យ មានសោភ័ណល្អ និងមានបរិស្ថានល្អ
- ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយនិងជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធិភាព។[13]

### ១.២.៥. បញ្ហាចរាចរណ៍

បញ្ហាចរាចរណ៍ គឺជាហេតុនាំឱ្យមានការរៀបចំខណ្ឌច្បារអំពៅ និងនាំឱ្យប្រទេសជាតិមានការអភិវឌ្ឍជឿនលឿនទៅមុខជាបន្តបន្ទាប់ផងដែរ។ កាលណាប្រទេសកំពុងតែជួបប្រទះបញ្ហាការកកស្ទះចរាចរណ៍នៅក្នុងទីក្រុងហើយពិតណាស់ នាំឱ្យមានគុណវិបត្តិសម្រាប់ប្រជាពលរដ្ឋ ដូចជាខាតបង់ពេលវេលា ខាតបង់ថវិកា និងប៉ះពាល់ដល់សុខភាព ជាពិសេសសុខភាពផ្លូវចិត្តអ្នកបើកបររាប់ម៉ឺននាក់នៅដងផ្លូវ។ តួយ៉ាងកំពុងកើតឡើងមានប្រចាំថ្ងៃ ទាំងព្រឹក ទាំងល្ងាច នៅពេលដែលប្រជាពលរដ្ឋចេញចូលធ្វើការ សិស្សានុសិស្សពីសាលារៀន និងប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ។ ជារៀងរាល់ថ្ងៃសង្កេតឃើញថា អ្នកបើកបរមួយចំនួនបញ្ជៀតរុលទៅមុខ នៅពេលមានការកកស្ទះចរាចរណ៍ រួមទាំងការបន្ថែមល្បឿននៅពេលឃើញភ្លើងស្តុបពណ៌លឿង រថយន្ត ម៉ូតូ និងកង់បីបើកបរនៅលើផ្លូវម៉ូតូ ការចតលើចំណីផ្លូវ យកចំណីផ្លូវមកធ្វើអាជីវកម្មប្រកបរបរចិញ្ចឹមជីវិត និងមានប្រជាពលរដ្ឋបើកបរបញ្ច្រាសផ្លូវជាដើម។ ជារាល់ថ្ងៃការកកស្ទះចរាចរណ៍នេះ បានបង្កផលប៉ះពាល់ខាងសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ គឺដោយសារតែមានការចំណាយថ្លៃប្រេងសាំងដែលបញ្ចេះចោល និងការខាតបង់ពេលវេលាប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ ហើយនៅពេលខ្លះនៅតាមដងផ្លូវមានការបង្កអំពើហិង្សាកើតឡើងដោយធ្វើឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយា ចរិត និងសតិអារម្មណ៍របស់អ្នកបើកបរនៅតាមដងផ្លូវ ដែលនាំឱ្យមានការប៉ះពាល់ដល់ទំនាក់ទំនងសង្គមនៅទីសាធារណៈ និងក្រុមគ្រួសាររបស់ប្រជាពលរដ្ឋ។ បន្ថែមពីនេះទៅទៀត ស្ថានភាពនៃការ

[13] គោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព របស់រាជរដ្ឋាភិបាល លេខ០១ គនប

កកស្ទះចរាចរណ៍នេះ ជារាល់ថ្ងៃនោះគឺមានភាពតានតឹងផ្លូវចិត្តរបស់ប្រជាពលរដ្ឋ និងមានភាពតានតឹងផ្នែកសង្គមកាន់តែធ្ងន់ធ្ងរខ្លាំង ហើយក៏មានគ្រោះថ្នាក់ចរាចរណ៍កើនឡើងផង។[14]

**បញ្ហាគ្រោះថ្នាក់ចរាចរណ៍ និងការកកស្ទះចរាចរណ៍បណ្តាលមកពីកត្តា ៣យ៉ាង៖**

- **កត្តាមនុស្ស** ៖ បណ្តាលមកពីមនុស្សកើនឡើងច្រើន ហើយបានធ្វើដំណើរតាមដងផ្លូវ ដែលជាហេតុនាំឱ្យមានការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍ជាបន្តបន្ទាប់។ ហើយគ្រោះថ្នាក់ចរាចរណ៍របស់អ្នកផ្សេងទៀត គឺកើតចេញពីការមិនគោរពច្បាប់ មិនគោរពភ្លើងផ្លាកសញ្ញា មិនគោរពគំនូសសញ្ញា មិនអនុវត្តច្បាប់ឱ្យមានតម្លាភាព និងបើកបរមិនយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមកជាដើម។

- **ការមិនគោរពផ្លាកសញ្ញា និងគំនូសញ្ញាចរាចរណ៍** ៖ ប្រការមួយផ្នែកទៀតដែលធ្វើឱ្យមានការកកស្ទះចរាចរណ៍ជារៀងរាល់ថ្ងៃនោះ គឺដោយសារការមិនគោរពផ្លាកសញ្ញាចរាចរណ៍ និងគំនូសញ្ញាចរាចរណ៍របស់អ្នកបើកបរ។ ការបើកបរបែបនេះ គឺធ្វើឱ្យស្ទះនៅតាមដងផ្លូវទៅណាមិនរួចនោះទេ ដោយសារតែអ្នកគោរពនៅតែគោរព រីឯអ្នកមិនគោរពនៅតែមិនគោរព ចំណុចនេះហើយទើបធ្វើឱ្យវាទៅមុខមិនរួច បកក្រោយក៏មិនបាន ចុងក្រោយស្ទះទាំងអស់គ្នា។ ផ្លាកសញ្ញាចរាចរណ៍ និងគំនូសសញ្ញាចរាចរណ៍នៅលើផ្លូវត្រូវបានរៀបចំជាប្រព័ន្ធទាក់ទងស៊ីសង្វាក់គ្នាជាហូរហែរនៅតាមដងផ្លូវដែលមានសារៈប្រយោជន៍យ៉ាងខ្លាំងណាស់ ដល់អ្នកធ្វើដំណើរដែលប្រើប្រាស់ដងផ្លូវងាយស្រួលមើលឃើញផ្លូវ។ បើទោះបីជាការបំពាក់នូវសញ្ញាចរាចរណ៍ និងគំនូសសញ្ញាចរាចរណ៍នៅក្នុងរាជធានីភ្នំពេញពុំទាន់ត្រឹមត្រូវបានគ្រប់ជ្រុងជ្រោយក៏ដោយ ប៉ុន្តែសញ្ញាចរាចរណ៍ទាំងអស់នោះបានផ្តល់នូវភាពសមល្មមសម្រាប់អ្នកបើកបរ ដើម្បីអនុវត្តហើយក៏ជាការរួមចំណែកដ៏សំខាន់ ក្នុងការកាត់បន្ថយការកកស្ទះចរាចរណ៍ផងដែរ។ ប៉ុន្តែផ្ទុយមកវិញអ្នកបើកបរនៅខណ្ឌច្បារអំពៅបច្ចុប្បន្ននេះ មិនបានគោរពទៅតាមគំនូសសញ្ញា ឬផ្លាកសញ្ញាចរាចរណ៍នោះទេ សូម្បីតែគំនូសសញ្ញាចរាចរណ៍សម្រាប់អ្នកថ្មើរជើងនៅតាមដងផ្លូវបាត់ទៅហើយ។ យើងឃើញថា ដូចជាគ្មានសណ្តាប់ធ្នាប់ នៅពេលបច្ចុប្បន្ននេះ ក៏ត្រូវបានប្រែក្លាយទៅជាចំណតសម្រាប់យានយន្តឈប់រងចាំភ្លើងសញ្ញាចរាចរណ៍ភាពជាជួរ បានរំលោភលើគន្លងផ្លូវ និងស្នាមគំនូសកាត់ទទឹងទ្រូងផ្លូវ[15] គំនូសអ្នកថ្មើរជើង ដែលបង្កបានជាការកកស្ទះចរាចរណ៍ និងការរិះគន់ច្រើនពីសំណាក់ប្រជាពលរដ្ឋដែលបានគោរពច្បាប់ចរាចរណ៍។ លើសពីនេះទៅទៀតនោះ នៅតាមបណ្តាលដងវិថីមួយចំនួនមានការចតយានជំនិះជាច្រើនហូរហែ ទាំងដែលនៅតាមដងវិថីទាំងអស់នោះមានផ្លាកសញ្ញាហាមចត ហាមឈប់

---

[14]គេហទំព័រ https://khmer.voanews.com/amp/phnom-penh-chronic-traffic-congestion-consumes-its-residents-time-economic-and-mental-wellbeing/6714438.html ដកស្រង់នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣។

[15] កថាខណ្ឌទី២ នៃមាត្រា១១ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ២០១៧

កត្តាទាំងអស់នេះហើយ ធ្វើឱ្យទំហំផ្លូវកាន់តែរួមតូចបង្កជាបញ្ហាការកកស្ទះចរាចរណ៍ស្ទើរតែរាល់ថ្ងៃ។ នៅមានពេលខ្លះ ផ្លាកសញ្ញាចរាចរណ៍ស្ទើរតែគ្មានអត្ថន័យសម្រាប់អ្នកបើកបរមួយចំនួន នៅក្នុងខណ្ឌច្បារអំពៅសព្វថ្ងៃនេះទៀយ។

- **ការមិនគោរពភ្លើងសញ្ញាចរាចរណ៍** ៖ ភ្លើងសញ្ញាចរាចរណ៍ត្រូវបានគេបង្កើត ដើម្បីសម្រួលដល់ការធ្វើដំណើររបស់អ្នកបើកបរយានយន្តគ្រប់ប្រភេទ ដោយធ្វើការបែបចែកនូវពេលវេលាត្រឹមត្រូវច្បាស់លាស់សិទ្ធិអាទិភាពក្នុងការបើកបរ ធ្វើយ៉ាងណាឱ្យសមស្របសម្រាប់ទិសដៅ និងស្ថានភាពទំហំផ្លូវនីមួយៗ។ ភ្លើងសញ្ញាចរាចរណ៍គឺមានបីពណ៌ ភ្លើងសញ្ញាចរាចរណ៍ដែលបញ្ចេញពន្លឺពណ៌លឿងជាសញ្ញាឱ្យប្រុងប្រយ័ត្នត្រៀមឈប់ ពន្លឺពណ៌បៃតងជាសញ្ញាអនុញ្ញាតឱ្យយានជំនិះចេញដំណើរ ពន្លឺពណ៌ក្រហមជាសញ្ញាឃាត់ឱ្យឈប់។[16] ប្រជាពលរដ្ឋបើកបរដោយមិនបានគោរពទៅតាមភ្លើងសញ្ញាចរាចរណ៍ឱ្យបានត្រឹមត្រូវ គឺបណ្តាលឱ្យស្ថានភាពដងផ្លូវមានសភាពរញ៉េរញ៉ៃ និងគ្មានសណ្តាប់ធ្នាប់បង្កជាការកកស្ទះចរាចរណ៍ដ៏គួរឱ្យធុញទ្រាន់។ តាមការសង្កេតមើល ជាក់ស្តែងអ្នកបើកបរភាគច្រើនមិនបានប្រុងប្រយ័ត្នមើលភ្លើងសញ្ញា ឬអ្នកមិនបានយល់ដឹងអំពីភ្លើងសញ្ញាចរាចរណ៍ ឬអ្នកបានដឹងហើយ ប៉ុន្តែតែងតែលើកយកមូលហេតុផ្សេងៗជាច្រើនឥតគណនាមកបំពានលើភ្លើងសញ្ញាទាំងអស់នោះ បើទោះបីជាទង្វើនោះបណ្តាលឱ្យខ្លួនក្លាយជាមនុស្សអាត្មានិយមក៏ដោយ។
- **ការជិះបញ្ច្រាសផ្លូវរបស់អ្នកបើកបរ** ៖ នៅលើដងផ្លូវនៅក្នុងប្រទេសកម្ពុជា គឺមានការបែងចែកគន្លងផ្លូវសម្រាប់ធ្វើចរាចរណ៍ជាពីរ ហើយអ្នកបើកបរត្រូវប្រកាន់យកចំណែកផ្លូវខាងស្តាំក្នុងការធ្វើចរាចរណ៍។ ប៉ុន្តែប្រជាពលរដ្ឋមួយចំនួនបានបើកបររំលោភបំពានទៅលើចំណែកផ្លូវរបស់ខ្លួន ដោយការជិះបញ្ច្រាសផ្លូវ ជិះចូលគន្លងផ្លូវរបស់អ្នកដទៃ ធ្វើយ៉ាងណាឱ្យតែមានយានជិះរបស់ពួកគាត់បានរុលទៅមុខ និងទៅដល់ទិសដៅរបស់ពួកគាត់ដោយមិនខ្វល់ពីស្ថានភាពចរាចរណ៍នឹងទៅជាយ៉ាងណា កត្តានេះហើយ មិនត្រឹមតែធ្វើឱ្យពួកគាត់កាន់តែខាតបង់ពេលវេលានោះទេ ថែមទាំងបានបង្កឱ្យស្ថានភាពផ្លូវម្ខាងទៀតនោះមានការកកស្ទះលើសដើម ហើយជួនកាលអាចនឹងបង្កឱ្យគ្រោះថ្នាក់ចរាចរណ៍ប៉ះពាល់ដល់អាយុជីវិតអ្នកដទៃថែមទៀតផង។
- **ការប្រើប្រាស់ទូរស័ព្ទក្នុងពេលបើកបរ** ៖ ប្រជាពលរដ្ឋកម្ពុជាចូលចិត្តណាស់ ចំពោះការប្រើប្រាស់ទូរស័ព្ទក្នុងខណៈពេលបើកបរត្រូវបានច្បាប់កំណត់មិនឱ្យប្រើប្រាស់នោះទេ ករណីគ្មានឧបករណ៍ភ្ជាប់សំឡេង។ មួយរយៈពេលក្រោយនេះ សង្កេតឃើញថា អ្នកបើកបរនៅរាជធានីភ្នំពេញមួយចំនួនតែងនិយាយទូរស័ព្ទ

[16] មាត្រា១១ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ២០១៧។

គ្រប់ពេលវេលា ដែលទង្វើទាំងអស់នេះធ្វើឱ្យអ្នកបើកបរបាត់បង់ការផ្ដោតអារម្មណ៍ទៅលើដងវិថី ដែលបណ្ដាលឱ្យយានយន្តមានលក្ខណៈវេចង្កូត ឆ្វេង ស្ដាំជារឿយៗដែលអាចនឹងបង្កជាបញ្ហាដល់អាយុជីវិតអ្នកដទៃហើយនាំឱ្យមានការកកស្ទះចរាចរណ៍យ៉ាងខ្លាំងផងដែរ។

- **ការមិនគោរពសិទ្ធិអាទិភាព ៖** នៅពេលដែលយើងនិយាយអំពីពាក្យថាអាទិភាព គឺសំដៅទៅលើសិទ្ធិដែលអ្នកបើកបរអាចនឹងទទួលបានមុនគេនៅក្នុងស្ថានភាពផ្លូវធ្វើដំណើរនៅពេលកំពុងបើកបរ។ បើកបររំលោភបំពានលើផ្លូវអាទិភាពរបស់អ្នកដទៃ គឺជាចំណែកមួយក្នុងការបង្កឱ្យមានការកកស្ទះចរាចរណ៍កាន់តែខ្លាំង អ្នកបើកបរមិនបានយល់ដឹងពីច្បាប់ ផ្លូវណាសម្រាប់អ្នកជិះម៉ូតូ ផ្លូវណាសម្រាប់អ្នកជិះឡាននោះទេ អ្នកបើកបរទាំងអស់ចង់តែប្រជែងទៅមុខរៀងៗខ្លួន ហើយនឹងមានការរំលោភបំពានទៅលើផ្លូវអាទិភាពរបស់គេ។

❖ **កត្តាយានយន្ត ៖** នៅក្នុងប្រទេសកម្ពុជាសម្បូរទៅដោយយានយន្តមួយទឹកៗ មកពីក្រៅប្រទេសលក់សម្រាប់ប្រជាពលរដ្ឋ ប្រើប្រាស់ជាមធ្យោបាយធ្វើដំណើរ ជាហេតុនាំឱ្យមានផលប៉ះពាល់ដល់បរិស្ថានយ៉ាងខ្លាំងផងដែរ។ គួរតែយកចិត្តទុកដាក់ដល់លើការបង្កើតឱ្យមាន សេវាដឹកជញ្ជូនសាធារណៈប្រើប្រាស់រថយន្ត ផ្ទាល់ខ្លួនធ្វើបែបនេះទើបអាចកាត់បន្ថយការកកស្ទះចរាចរណ៍។

❖ **កត្តាផ្លូវ ៖** ផ្លូវថ្នល់ប្រៀបបាននឹងសរសៃឈាមដែលបានមិនអាចនឹងខ្វះបាន ហើយបាននឹងកំពុងតែឆ្លើយតបទៅនឹងតម្រូវការចាំបាច់ឥតឈប់ឈររបស់អ្នកធ្វើដំណើរ។ ប្រព័ន្ធគមនាគមន៍មួយចំនួនមិនទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅឡើយនោះទេ។ បើក្រឡេកមើល ចំពោះទិដ្ឋភាពនៅក្នុងខណ្ឌច្បារអំពៅវិញ យើងអាចសង្កេតឃើញថា នៅមានតាមបណ្ដាផ្លូវជាច្រើនត្រូវបានសាងសង់ដោយពុំទាន់មានស្តង់ដាបច្ចេកទេសច្បាស់លាស់ គ្មានការបំពាក់នូវផ្លាកសញ្ញាចរាចរណ៍ឱ្យបានត្រឹមត្រូវ គ្មានការគិតគូរពីទំហំផ្លូវប្រៀបធៀបនឹងស្ថានភាពចរាចរណ៍ដែលកំពុងតែបើកបររៀងរាល់ថ្ងៃ ហើយផ្លូវខ្លះទៀតត្រូវបានខូចខាតអស់ ដែលទាមទារឱ្យអាជ្ញាធរមានសមត្ថកិច្ចចាំបាច់ត្រូវតែចាំបាច់គិតគូរឱ្យបានទាន់ពេលវេលា។ ជាការពិតមែនហើយ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅតែដើរតួនាទីដ៏សំខាន់ក្នុងការកាត់បន្ថយបញ្ហាកកស្ទះចរាចរណ៍ ហើយបើផ្លូវថ្នល់តូចនោះ អ្នកបើកបរពិតមានភាពលំបាកហើយបង្កជាការកកស្ទះចរាចរណ៍គួរឱ្យធុញជាមិនខាន ម្យ៉ាងទៀតដោយសារតែប្រជាពលរដ្ឋមួយចំនួន នៅតែមានទម្លាប់រុលទៅមុខ ដោយមិនបានគិតគូរពីអ្នកដទៃ ដែលនៅជុំវិញខ្លួនបែបនេះហើយ ដូច្នេះហើយស្ថានភាពផ្លូវតូចៗមួយចំនួនក ពិតជាបង្កឱ្យស្ថានភាពកកស្ទះចរាចរណ៍កាន់តែធ្ងន់ធ្ងរទៅពីមួយថ្ងៃទៅមួយថ្ងៃ។ មូលហេតុដ៏ចម្បងមួយដែលរួមចំណែកធ្វើឱ្យអ្នកដំណើរមានផលវិបាកជាខ្លាំង ពីព្រោះនៅលើ

ផ្លូវសុទ្ធតែគ្រឿងចក្រជួសជុលផ្លូវ ដូចនេះហើយទើបបង្កឱ្យមានការធ្វើដំណើរយឺតយ៉ាវហើយថែមទាំងធ្វើឱ្យមានការកកស្ទះចរាចរណ៍ថែមទៀតផង។

## ១.៣. សមត្ថកិច្ចដែលពាក់ព័ន្ធ និងការរៀបចំ

### ១.៣.១. ក្រុមប្រឹក្សាខណ្ឌ

❖ **ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ**

- ការងាររដ្ឋបាល លិខិតស្នាមផ្សេងៗ ទំនាក់ទំនងសាធារណៈ និងការងារពិធីការ
- គ្រប់គ្រង និងថែរក្សារដ្ឋបាលខណ្ឌតាមការកំណត់
- ការងារស្ថិតិប្រជាពលរដ្ឋ និងការងារអាត្រានុកូលដ្ឋាន
- ការងារ បុគ្គលិក ក្រមខណ្ឌ បៀវត្សរ៍ និងកម្រៃផ្សេងៗរបស់មន្ត្រីបុគ្គលិកសាលាខណ្ឌ
- សហការរៀបចំនីតិវិធីរដ្ឋបាល នីតិគ្រប់គ្រងទ្រព្យសម្បត្តិសាលាខណ្ឌ
- សិក្សាលើកយោបល់លើការបង្កើត កែសម្រួល និងការរំសាយការិយាល័យចំណុះសាលាខណ្ឌ
- ការបណ្តុះបណ្តាល និងកសាងសមត្ថភាពមន្ត្រីបុគ្គលិកសាលាខណ្ឌ
- រៀបចំសេចក្តីព្រាង របៀបវារៈខ្លឹមសារសម្រាប់របៀបវារៈនីមួយៗ និងឯកសារកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានាក្រុមប្រឹក្សាខណ្ឌ
- ទទួល និងការបែងចែកលិខិតស្នាមឯកសារនានា ឱ្យបានត្រឹមត្រូវ ទៅសមាជិកក្រុមប្រឹក្សាខណ្ឌអភិបាលខណ្ឌ អភិបាលរងខណ្ឌ និងរដ្ឋបាលខណ្ឌព្រមទាំងក្រសួងស្ថាប័ន មន្ទីរអង្គភាពការិយាល័យជំនាញ និងអ្នកពាក់ព័ន្ធ
- រក្សាទុកដាក់ឱ្យបានត្រឹមត្រូវ និងគង់វង្សនូវឯកសារលិខិតបទដ្ឋានគតិយុត្តទាំងអស់របស់ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាល និងរដ្ឋបាលខណ្ឌ
- សហការក្នុងការត្រៀមរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ នៅតាមសង្កាត់នានាក្នុងខណ្ឌ
- ជំរុញ និងអនុវត្តកិច្ចការពាក់ព័ន្ធ ការបញ្ជ្រាបយេនឌ័រ និងបង្កើនសិទ្ធិអំណាចស្ត្រី
- អនុវត្តនូវកិច្ចការផ្សេងៗទៀតតាមការប្រគល់របស់នាយករដ្ឋបាលរបស់សាលាខណ្ឌ និងតាមការកែតម្រូវរបស់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។[17]

❖ **ការិយាល័យផែនការ និងអភិវឌ្ឍន៍**

[17] សៀវភៅការគ្រប់គ្រងរដ្ឋបាល សាលាខណ្ឌច្បារអំពៅ ឆ្នាំ២០១៤ ទំព័រទី ៦៤។

- រៀបចំផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគដើម្បីបញ្ចូលនៅក្នុងផែនការអភិវឌ្ឍរយៈពេល ៥(ប្រាំ)ឆ្នាំ កម្មវិធីវិនិយោគរយៈពេល ៣(បី)ឆ្នាំរំកិលប្រចាំឆ្នាំរបស់រាជធានីភ្នំពេញ
- អនុវត្តគម្រោងកម្មវិធីអភិវឌ្ឍន៍នានា របស់សាលាខណ្ឌ សិក្សាវាយតម្លៃ និងលើកយោបល់អំពីសមត្ថភាពរបស់ក្រុមប្រឹក្សាសង្កាត់
- តម្រូវការគាំទ្រ ដើម្បីដោះស្រាយសំណើរ សំណូមពរ និងបញ្ហាប្រឈមនានារបស់សង្កាត់នីមួយៗក្នុងខណ្ឌ
- ការសម្របសម្រួល និងគាំទ្រកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និងផ្តល់សេវា ក្នុងចំណោមសង្កាត់នីមួយៗក្នុងខណ្ឌ
- កិច្ចការផ្សេងៗដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋាននានា ដែលតម្រូវដោយក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ។[18]

❖ **ការិយាល័យអន្តរវិស័យ**

- ការងារដីធ្លី និងសំណង់
- ការងារសេដ្ឋកិច្ច (ពាណិជ្ជកម្ម កសិកម្ម ទេសចរណ៍)
- ការងារសង្គមកិច្ច
- ការងារវប្បធម៌ សាសនា
- ការងារបរិស្ថាន កាកសំណល់ អនាម័យ សួនច្បារ
- ការងារសាធារណៈការ
- ការងារទទួលពាក្យបណ្តឹង
- ការងារសម្របសម្រួល
- ការងារវប្បធម៌
- បញ្ជូនបន្ត
- ការងារលទ្ធកម្ម
- ការងារដេញថ្លៃសម្រាប់ប្រភេទលទ្ធកម្មនីមួយៗ
- ការងារផ្សព្វផ្សាយលទ្ធកម្មនៃការដេញថ្លៃ
- សេចក្តីព្រាងកិច្ចសន្យាទៅតាមអនុលោមបទដ្ឋាន និងគំរូកិច្ចសន្យា

[18] សៀវភៅការគ្រប់គ្រងរដ្ឋបាល សាលាខណ្ឌច្បារអំពៅ ឆ្នាំ២០១៤ ទំព័រទី ៦៥។

- តាមដាន និងទូទាត់នៃកិច្ចសន្យាជូនអ្នកផ្គត់ផ្គង់ និងអ្នកទទួលការ ឬទីប្រឹក្សា
- តាមដានរបាយការណ៍ស្ដីពីកិច្ចការលទ្ធកម្ម ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ
- កិច្ចការច្បាប់ និងសិទ្ធិមនុស្ស ការលោភច្បាប់ ការដោះស្រាយវិវាទនៅមូលដ្ឋាន។[19]

### ១.៣.២. គណៈអភិបាលខណ្ឌ

នៅក្នុងសាលាខណ្ឌច្បារអំពៅគណៈអភិបាល និងអភិបាលរងចំនួន៥រូបមានដូចជា៖

- គណៈអភិបាល លោក ចេង មុនីរ៉ា ឋានន្តរស័ក្តឧត្តមមន្ត្រី ថ្នាក់លេខ៦នៃគណៈអភិបាលខណ្ឌច្បារអំពៅ។[20]
- អភិបាលរង១រូប លោក ញាណ ច័ន្ទសោភា ឋានន្តរស័ក្តវរមន្ត្រី ថ្នាក់លេខ១ ជាអភិបាលរងនៃគណៈខណ្ឌច្បារអំពៅ។[21]
- អភិបាលរង១រូប លោក ម៉ុក ពុទ្ធា ឋានន្តរស័ក្តវរមន្ត្រី ថ្នាក់លេខ១ ជាអភិបាលរងនៃគណៈខណ្ឌច្បារអំពៅ។[22]
- អភិបាលរង លោក ឡាយ ស្ទីវិន ឋានន្តរស័ក្តអនុមន្ត្រីថ្នាក់លេខ៣ ជាអភិបាលរងនៃគណៈខណ្ឌច្បារអំពៅ។[23]
- អភិបាលរងខណ្ឌ លោក កាទើ អះម៉ាត់សទើរ។[24]

## ១.៤. បច្ចុប្បន្នភាព

ខណ្ឌច្បារអំពៅ គឺជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤ របស់រាជធានីភ្នំពេញ ដែលមានទីតាំងស្ថិតនៅក្បែរទីក្រុងភ្នំពេញផងនោះ ជាហេតុនាំឱ្យមានប្រជាពលរដ្ឋរស់នៅប្រកបរបរច្រើនប្រភេទ។ ជាងនេះទៅទៀត ក្នុងខណ្ឌច្បារអំពៅ ឃើញថាបច្ចុប្បន្ន គឺសម្បូរទៅដោយសំណង់អគារខ្ពស់ៗ បុរី លំនៅដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ រមណីយដ្ឋាន សួនច្បារតាមដងផ្លូវ មណ្ឌលពាណិជ្ជកម្ម ផ្សារទំនើបសង់អមសងខាងផ្លូវដងវិថីតូចធំខ្វាត់ខ្វែងអាចទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិចូលមកទស្សនា និងទិញទំនិញគ្រប់ប្រភេទ។ ក្រៅពីនេះទៅទៀតខណ្ឌច្បារអំពៅ ហាក់បីដូចជាទីក្រុងមួយដែលសម្បូរទៅដោយកន្លែងកំសាន្ត លំហែកាយ របស់ប្រជាពលរដ្ឋ ព្រមទាំងមានការតាំងលក់នូវទំនិញប្រើប្រាស់ទំនើបៗ និងភោជនីយដ្ឋានដ៏សម្បូរបែបទៀតផង។

[19] សៀវភៅការគ្រប់គ្រងរដ្ឋបាល សាលាខណ្ឌច្បារអំពៅ ឆ្នាំ២០១៤ ទំព័រទី ៦៥

[20] អនុក្រឹត្យលេខ៣១៨ ស្ដីពី ការតែងតាំងមន្ត្រីរាជការ ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២១។

[21] ប្រកាស ស្ដីពីការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ លេខ៤៦៦១ ប្រក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២។

[22] ប្រកាស ស្ដីពីការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ លេខ៤៦៦១ ប្រក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២។

[23] ប្រកាស ស្ដីពីការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ លេខ៤៦៦១ ប្រក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២។

[24] https://khmerpostasia.com/archives/92340 ដកស្រង់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២៣។

មិនតែប៉ុណ្ណោះនៅមានសំណង់អគារតូចធំ របស់ស្ថាប័នរាជរដ្ឋាភិបាល គ្រឹះស្ថានឯកជន អង្គការក្រៅរដ្ឋាភិបាលជាច្រើនដែលបោះទីតាំងនៅក្នុងសង្កាត់ទាំង៨ របស់ខណ្ឌច្បារអំពៅ និងបង្កឱ្យមានលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍន៍មូលដ្ឋាន ដើម្បីឆ្លើយតបនូវតម្រូវការជាក់ស្តែងរបស់មូលដ្ឋាន និងសំណូមពររបស់ប្រជាពលរដ្ឋ។

### ១.៤.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

បណ្តាហេដ្ឋារចនាសម្ព័ន្ធក្នុងខណ្ឌច្បារអំពៅ មានដូចជាកសាងផ្លូវប្រព័ន្ធលូបង្ហូរទឹក ការដាក់បង្គោលភ្លើងសាធារណៈ និងកសាងស្ពាន។ ពិតជាមានសារៈប្រយោជន៍ដល់ប្រជាពលរដ្ឋនៅក្នុងខណ្ឌនោះ មានភាពងាយស្រួលក្នុងការធ្វើដំណើរ និងងាយស្រួលប្រកបអាជីវកម្ម បន្ថែមពីនេះធ្វើឱ្យខណ្ឌច្បារអំពៅមានសណ្តាប់ធ្នាប់ និងជួយកាត់បន្ថយការកកស្ទះលូ និងកកស្ទះចរាចរណ៍នៅតាមដងផ្លូវបានមួយចំណែកធំ។

❖ **ការកសាងផ្លូវ**

ការអនុវត្តគម្រោងកសាងផ្លូវពេលបច្ចុប្បន្ននេះ បាននាំមកនៅការអភិវឌ្ឍជាច្រើនដោយបានការកាត់បន្ថយការរាំងស្ទះចរាចរណ៍ ដល់ប្រជាពលរដ្ឋបានមួយកម្រិតបន្ថែមទៀត ពីព្រោះពេលបច្ចុប្បន្ននៅក្នុងខណ្ឌមានការកើនឡើង កំណើនប្រជាពលរដ្ឋ និងកំណើនការសាងសង់លំនៅដ្ឋានជាច្រើន បន្ថែមពីនេះមានការកើនឡើងនូវមធ្យោបាយធ្វើដំណើរដូចជាយានយន្ត និងយានជំនិះផ្សេងៗនៅក្នុងខណ្ឌច្បារអំពៅនេះ។

❖ **ការកសាងប្រព័ន្ធលូបង្ហូរទឹក**

ខណ្ឌច្បារអំពៅមានការស្ថាបនាប្រព័ន្ធបង្ហូរទឹក ដើម្បីកាត់បន្ថយនូវការជន់លិចដែលបណ្តាលមកពីការស្ទះលូ មានផលប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋផងដែរ ដូច្នេះខណ្ឌបានយកចិត្តទុកដាក់ ដោយធ្វើការស្ថាបនាប្រព័ន្ធថ្មីៗនៅតាមសង្កាត់នីមួយៗនៅក្នុងខណ្ឌ និងជួសជុលនូវឥទ្ធូរចាស់ៗ ដើម្បីជាភាពងាយស្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋនៅតាមតំបន់មួយចំនួន។

❖ **ការដាក់បង្គោលបំភ្លឺសាធារណៈ**

ក្នុងខណ្ឌច្បារអំពៅមានការរៀបចំដាក់បង្គោលភ្លើងបំភ្លឺ នៅតាមដងផ្លូវសាធារណៈនានា ដើម្បីជួយសម្រួលដល់ការបើកបររបស់ប្រជាពលរដ្ឋនានា។

❖ **ការកសាងស្ពាន**

ស្ពាន គឺជាមធ្យោបាយដ៏សំខាន់មួយសម្រាប់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរ ព្រមទាំងមធ្យោបាយដ៏សំខាន់ក្នុងការដឹកជញ្ជូន ដែលបម្រើដល់វិស័យសេដ្ឋកិច្ចបានមួយផ្នែកធំ។ ក្នុងនោះផងដែរ ខណ្ឌច្បារអំពៅក៏មានស្ពានចំនួន២ ដែលភ្ជាប់ទៅខណ្ឌសព្វថ្ងៃមានដូចជា ស្ពានព្រះមុនីវង្សចាស់ និងស្ពានព្រះមុនីវង្សថ្មី។

ក្នុងនោះផងដែរ ស្ពានដែលជាបន្ទុករបស់ខណ្ឌច្បារអំពៅ គឺស្ពានព្រះមុនីវង្សចាស់មានឈ្មោះជាភាសាអង់គ្លេស GUSTAVE EIFFEL ដែលប្រជារាស្ត្រខ្មែរយើងសម័យមុន មានឈ្មោះស្ពានជ្រោយអោក បានកសាង

ពីឆ្នាំ១៩៨៥ លុះមកដល់ឆ្នាំ១៩៦៤ មានការទ្រុឌទ្រោមយ៉ាងខ្លាំង។ ដោយស្ពាននេះបានសាងសង់ឡើងវិញរួម ប្រារព្ធធ្វើសម្ពោធនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៦៦។ ស្ពានមុនីវង្ស គឺជាស្ពានមួយនៅភ្នំពេញដែលមានចាចរណ៍។ ស្ពាននេះមានប្រវែង២៦៩ម៉ែត្រ ទទឹង២គុណ១៤ម៉ែត្រ តភ្ជាប់ច្រាំងខាងលិច ដែលចុងបញ្ចប់នៃផ្លូវជាតិលេខ២ ឆ្លងកាត់ទន្លេបាសាក់ ទៅកាន់ច្រាំងខាងកើតដែលមាន ផ្លូវជាតិលេខ១ ជាច្រកឆ្ពោះទៅខេត្តមួយចំនួននៃខាងកើតប្រទេស ក៏ដូចជាទៅកាន់ប្រទេសវៀតណាម។

### ១.៤.២. ការអភិវឌ្ឍលំនៅដ្ឋាន

ពេលបច្ចុប្បន្ននៅក្នុងខណ្ឌច្បារអំពៅ មានការអភិវឌ្ឍខ្លាំងទៅលើវិស័យសំណង់លំនៅដ្ឋានដែលនៅក្នុងនោះផងដែរមានបុរី ខុនដូរ លំនៅដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្ត ភោជនីយដ្ឋាន ផ្សារទំនើប សួនច្បារមជ្ឈមណ្ឌលពាណិជ្ជកម្ម លើសពីនេះទៀត គឺមានសំណង់ស្ថាប័នរដ្ឋជាច្រើន ដែលបានធ្វើការសាងសង់នៅក្នុងខណ្ឌច្បារអំពៅ។

### ១.៤.៣. ការរៀបចំរបៀបរៀបរយ

ការរៀបចំរបៀបរៀបរយ គឺធានាបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការរក្សាការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈដល់ប្រជាពលរដ្ឋ។ ការរៀបចំរបៀបរៀបរយ គឺជាការរៀបចំទៅលើបញ្ហាដែលអាជីវករ ឬប្រជាពលរដ្ឋណាមួយបានធ្វើអាជីវកម្ម ឬការសាងសង់សំណង់ដោយមានការរំលោភយកផ្លូវសាធារណៈ និងការរៀបចំផ្សាររដ្ឋ និងផ្សារឯកជន ឱ្យមានភាពត្រឹមត្រូវប្រកបដោយរបៀបរៀបរយមានសណ្តាប់ធ្នាប់។

ជាក់ស្តែង អនុវត្តតាមផែនការណែនាំរបស់លោក ចេង មុនីរ៉ា អភិបាលខណ្ឌច្បារអំពៅ នៅព្រឹកថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣នេះ លោក ហ៊ត គឹមនី អភិបាលរងខណ្ឌ ដឹកនាំកម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌចុះរៀបចំសណ្តាប់ធ្នាប់តាមផ្លូវ៣៦៩ ចាប់ពីគល់ស្ពានព្រះមុនីវង្សចាស់ រហូតដល់មាត់ទន្លេច្រាំងបាក់ ក្នុងភូមិដើមចាន់១ សង្កាត់ច្បារអំពៅទី២ ហើយក្នុងនោះ បានធ្វើកិច្ចសន្យាណែនាំដល់ម្ចាស់ទីតាំងប្រក់រោងដាក់តុលក់ដូរ លើដីសាធារណៈរបស់រដ្ឋ ហៀរមកលើចិញ្ចើមផ្លូវ គឺត្រូវឱ្យរុះរើចេញ ដោយទុកពេលមួយសប្តាហ៍។

ការងារចុះរៀបចំសណ្តាប់ធ្នាប់នេះ ក៏មានការចូលរួមពីលោក គួច ចំណាន ប្រធានគណៈកម្មការគ្រប់គ្រងផ្សារច្បារអំពៅ និងលោក សាន់ ប៊ុនណា ប្រធានគណៈកម្មការគ្រប់គ្រងផ្សារបន្លែ និងកម្លាំងសណ្តាប់ធ្នាប់ខណ្ឌ កម្លាំងអធិការនគរបាលខណ្ឌច្បារអំពៅ។ ជាមួយគ្នានេះរដ្ឋបាលខណ្ឌច្បារអំពៅ សូមអំពាវនាវដល់ប្រជាពលរដ្ឋដែលប្រកបរបរលក់ដូរតាមបណ្តាផ្លូវនានា ក្នុងភូមិសាស្ត្រខណ្ឌ ត្រូវចូលរួមទាំងអស់គ្នា បញ្ឈប់ការ

យកចិញ្ចើមផ្លូវសាធារណៈដាក់តាំងលក់ប្រកបរបរអាជីវកម្ម ដើម្បីចូលរួមថែរក្សាសោភ័ណភាព សុវត្ថិភាព របៀបរៀបរយក្នុងមូលដ្ឋានខណ្ឌនៃរាជធានីភ្នំពេញ។[25]

## ១.៥. ទិសដៅអនាគតនៃការរៀបចំ

### ១.៥.១. ការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធ

បណ្ដាហេដ្ឋារចនាសម្ព័ន្ធក្នុងខណ្ឌច្បារអំពៅមានដូចជា កសាងផ្លូវប្រព័ន្ធលូបង្ហូរទឹក ការដាក់បង្គោលភ្លើងសាធារណៈ និងកសាងស្ពាន។ ការកសាងផ្លូវប្រព័ន្ធលូបង្ហូរទឹក ការដាក់បង្គោលភ្លើងសាធារណៈ និងការកសាងស្ពាន ពិតជាមានសារៈប្រយោជន៍ដល់ប្រជាពលរដ្ឋនៅក្នុងខណ្ឌនោះ មានភាពងាយស្រួលក្នុងការធ្វើដំណើរ និងងាយស្រួលប្រកបអាជីវកម្ម បន្ថែមពីនេះធ្វើឱ្យខណ្ឌច្បារអំពៅមានសណ្ដាប់ធ្នាប់ និងជួយកាត់បន្ថយការកកស្ទះលូ និងកកស្ទះចរាចរណ៍នៅតាមដងផ្លូវបានមួយចំណែកធំ។

### ១.៥.២. ការអភិវឌ្ឍលើទឹកស្អាត និងអនាម័យ

ចំពោះការរំពឹងទុកនាឆ្នាំ២០២៣ខាងមុខនេះ ប្រជាពលរដ្ឋប្រមាណ៧០ភាគរយមានទឹកស្អាតប្រើប្រាស់ ដោយខណ្ឌបានរៀបចំបណ្ដាញទឹកស្អាត សម្រាប់ប្រជាពលរដ្ឋ។ ការអភិវឌ្ឍទៅលើវិស័យទឹកស្អាត និងអនាម័យនេះក្នុងគោលបំណងជំរុញឱ្យមានការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាពលរដ្ឋឱ្យបានគ្រប់គ្រាន់ និងមានអនាម័យ ដល់ប្រជាពលរដ្ឋ។ មួយវិញទៀត ដើម្បីសម្រេចនូវគោលបំណងនេះក៏ត្រូវមាននូវយុទ្ធសាស្ត្រសម្រេចលើការអភិវឌ្ឍវិស័យនេះ ដោយជំរុញឱ្យមានការតបណ្ដាញទឹកស្អាត ការសង់ និងជួសជុល និងការស្ដារស្រះ ដើម្បីឱ្យប្រជាពលរដ្ឋមានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់នៅគ្រប់មូលដ្ឋានទាំងអស់។[26]

### ១.៥.៣. ការអភិវឌ្ឍលើវិស័យសន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ

ចំពោះគោលដៅអភិវឌ្ឍវិស័យសន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈខណ្ឌច្បារអំពៅទៅថ្ងៃអនាគត ដោយរំពឹងថា នឹងសម្រេចបានក្នុងឆ្នាំ២០២៣ខាងមុខ ប្រជាពលរដ្ឋរស់នៅប្រកបដោយសុវត្ថិភាព ដោយខណ្ឌមានការអភិវឌ្ឍទៅលើ ៖

ពង្រឹងសកម្មភាពរក្សាសន្តិសុខសណ្ដាប់ធ្នាប់ក្នុងមូលដ្ឋាន ទប់ស្កាត់ការចែកចាយ និងប្រើប្រាស់គ្រឿងញៀន បង្ក្រាបអំពើចោរកម្ម និងលេងល្បែងស៊ីសងគ្រប់ប្រភេទ ពង្រឹងការប្រើប្រាស់នូវអាវុធខុសច្បាប់

- ប្រមូលក្រុមជនពាលដើម្បីអប់រំ
- សង់/ជួសជុលប៉ុស្តិ៍ប្រជាការពារ

[25] https://freshnewsasia.com/index.php/en/localnews/273693-2023-01-11-09-32-24.html ដកស្រង់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣។

[26] ច្បាប់ស្ដីពីការគ្រប់គ្រង់ទឹកស្អាត មាត្រា៦។

- ពង្រឹងការពារ និងទប់ស្កាត់ជំងឺកូវីដ១៩
- ពង្រឹងវិធានការណ៍ការពារគ្រោះថ្នាក់ចរាចរណ៍

ការអភិវឌ្ឍលើវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ក្នុងគោលបំណងបង្កើនការគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដើម្បីធ្វើឱ្យប្រជាពលរដ្ឋក្នុងខណ្ឌរស់នៅប្រកបដោយ សន្តិសុខ សុវត្ថិភាព ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត បន្ថែមពីនេះដើម្បីការពារអាយុជីវិតរបស់ប្រជាពលរដ្ឋជៀសផុតពីជំងឺកូវីដ១៩ មានសុវត្ថិភាពសាធារណៈ គ្មានភ័យខ្លាច ស្ងៀមស្ងាត់។ ជាពិសេសនោះ គឺការរស់នៅប្រកបដោយសុវត្ថិភាព ដោយគេចផុតពីជំងឺដ៏កាចសាហាវ។ ដូច្នេះដើម្បីសម្រេចបាននូវគោលបំណងខាងលើខណ្ឌច្បារអំពៅ បានដាក់ចេញនូវ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទៅលើវិស័យសន្តិសុខសណ្តាប់ធ្នាប់សាធារណៈមានដូចខាងក្រោម ៖

- ផ្សព្វផ្សាយច្បាប់ស្តីពីការជួញដូរ ចែកចាយ និងប្រើប្រាស់គ្រឿងញៀន
- ពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈក្នុងមូលដ្ឋាន
- អនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព
- ផ្សព្វផ្សាយច្បាប់អនុវត្តវិធានការការពារតាមការណែនាំរបស់ក្រសួងសុខាភិបាល ទប់ស្កាត់ការឆ្លងជំងឺកូវីដ១៩ ដល់ប្រជាពលរដ្ឋគ្រប់ភូមិ និងសង្កាត់ទាំងអស់នៅក្នុងខណ្ឌច្បារអំពៅ។
- រៀបចំសណ្តាប់ធ្នាប់សាធារណៈ
- ជំរុញការចុះធ្វើរដ្ឋបាល។

### ១.៦. ដំណោះស្រាយពាក់ព័ន្ធសណ្តាប់ធ្នាប់នៅក្នុងខណ្ឌច្បារអំពៅ

ការរៀបចំសណ្តាប់ធ្នាប់មួយដ៏ល្អ និងមានរបៀបរៀបរយទៅបាន លុះត្រាដែលមានការចូលរួមពីតួអង្គសំខាន់ដែលពាក់ព័ន្ធដូចជា៖

**ក.អាជ្ញាធរមានសមត្ថកិច្ច**

មន្ត្រីមានអាជ្ញាធរ គឺជាតួអង្គយ៉ាងសំខាន់ក្នុងការងាររៀបចំសណ្តាប់ធ្នាប់ក្នុងខណ្ឌរបស់ខ្លួន ក្នុងនោះមន្ត្រីត្រូវមានភារៈកិច្ចដូចខាងក្រោម៖

- ពង្រឹង និងអនុវត្តនៅបទដ្ឋានគតិយុត្តដែលមានស្រាប់
- លើកកម្ពស់ការចូលរួមឱ្យបានសកម្មក្នុងការងារសង្គមរបស់មន្ត្រីគ្រប់ជាន់ថ្នាក់ក្នុងការងាររៀបចំសណ្តាប់ធ្នាប់ក្នុងខណ្ឌច្បារអំពៅ
- ពិនិត្យ និងតាមដាន រាល់ការវិវត្តន៍ និងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងស្វែងរកដំណោះស្រាយឱ្យបានទាន់ពេលវេលា
- លុបបំបាត់រាល់សកម្មភាពដែលធ្វើឱ្យរាំងស្ទះ និងបង្កភាពអនាធិបតេយ្យដល់ការរៀបចំសណ្តាប់ធ្នាប់

- បំផុសចលនាចូលរួមរបស់សហគមន៍ពាក់ព័ន្ធការគាំពារសង្គម និងសន្តិសុខសង្គម
- បង្កើតឱ្យមានការយល់ដឹង និងជ្រាបតាមរយៈដៃគូអភិវឌ្ឍន៍ធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋមានការយល់ដឹងខ្ពស់
- អនុវត្ត និងពង្រឹងនៅគោលការណ៍ភូមិ ឃុំ មានសុវត្ថិភាពល្អ។

**ខ.ប្រជាពលរដ្ឋ**

ប្រជាពលរដ្ឋ ជាកត្តាលើកក្នុងការជម្រុញការងារនេះឱ្យបានរលូនទៅមុខ និងមានប្រសិទ្ធភាពខ្ពស់ ត្រូវឈរលើគោលគំនិតដូចជា៖

- ចូលរួមគោរព និងអនុវត្តនូវបទដ្ឋានដែលមាន
- ចូលរួមសកម្មភាពក្នុងសហគមន៍ឱ្យបានសកម្ម និងរួមចំណែកលុបបំបាត់ភាពអសកម្មដែលជាកត្តាអវិជ្ជមានដល់ការងាររៀបចំ
- មានស្មារតី និងមនសិការខ្ពស់ក្នុងការជួយជ្រោមជ្រែងដល់ការងាររៀបចំសណ្តាប់ធ្នាប់សាធារណៈ បង្កើនការទទួលព័ត៌មានឱ្យបានជាក់លាក់ ជៀសវាងការទទួលព័ត៌មានដែលមានលក្ខណៈញុះញង់។

**១.៦.១. ដំណោះស្រាយពាក់ព័ន្ធបញ្ហាសន្តិសុខសង្គម**

ដើម្បីធានាបាននូវសណ្តាប់ធ្នាប់ និងសន្តិសុខល្អ នៅក្នុងមូលដ្ឋានខណ្ឌច្បារអំពៅ លោក ចេង មុនីរ៉ា អភិបាលខណ្ឌ និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌច្បារអំពៅ បានក្រើនរំលឹកដល់កម្លាំងគណៈបញ្ជាការឯកភាពខណ្ឌសង្កាត់ ត្រូវរួមគ្នាខិតខំពង្រឹងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព ឱ្យបានម៉ឺងម៉ាត់បំផុត។

ការក្រើនរំលឹកជាថ្មីនេះ របស់លោកអភិបាលខណ្ឌ បានធ្វើឡើង នៅក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌច្បារអំពៅ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ ដោយមានចូលរួមពីលោកមេបញ្ជាការកងរាជអាវុធហត្ថខណ្ឌ លោកអធិការរងនគរបាលខណ្ឌ លោក-លោកស្រី ជាអភិបាលរង លោក-លោកស្រី ចៅសង្កាត់ទាំង៨ លោកនាយក-នាយករងរដ្ឋបាលខណ្ឌ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលទាំង៨ និងប្រធានការិយាល័យគ្រប់ការិយាល័យ។

លោកអភិបាលខណ្ឌ ក៏ណែនាំដល់កម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌ និងសង្កាត់ ត្រូវរួមគ្នាអនុវត្តបទបញ្ជាខ្ពង់ខ្ពស់របស់សម្តេចតេជោ ហ៊ុន សែន ឱ្យបានម៉ឺងម៉ាត់បំផុត ក្នុងការលុបបំបាត់ល្បែងស៊ីសងគ្រប់ប្រភេទ និងល្បែងតាមអនឡាញ។ ជាពិសេសកិច្ចការពង្រឹងសន្តិសុខនៅតាមមូលដ្ឋានចុះល្បាតជាប្រចាំនៅតាមគោលដៅងាយរងគ្រោះរួមមាន គោលដៅចោរកម្ម គោលដៅស្មុគស្មាញ គោលដៅក្មេងទំនើង គោលដៅប្រើប្រាស់ និងចែកចាយគ្រឿងញៀន។

លោកបានបន្តថា គោលដៅសំខាន់មួយទៀត ត្រូវរួមគ្នា បង្ការ ទប់ស្កាត់ និងបង្ក្រាបគ្រឿងញៀន ព្រោះវាធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ក្រុមគ្រួសារដល់សហគមន៍ និងសង្គមជាតិទាំងមូលជាពិសេសប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរសង្កាត់ ត្រូវរួមគ្នាកំណត់មុខសញ្ញាគ្រប់ប្រភេទនៅក្នុងមូលដ្ឋាន ធ្វើយ៉ាងណាឱ្យមូលដ្ឋានរបស់យើងគ្មានគ្រឿងញៀន មួយទៀតត្រូវជំរុញការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋពីផលប៉ះពាល់ និងគ្រោះថ្នាក់ ដែលបង្កឡើងដោយគ្រឿងញៀន។ ការងារសន្តិសុខនេះ ជាកត្តាសំខាន់ណាស់ ដែលមិនអាចខ្វះបាន ហើយមនុស្សគ្រប់គ្នា គ្រប់ស្រទាប់វណ្ណៈ មិនថា អ្នកមាន ឬអ្នកក្រនោះទេ គឺចង់បានមូលដ្ឋានមានសន្តិសុខល្អ រស់នៅក្នុងភាពសុខដុមរមនា។[27]

### ១.៦.២. ដំណោះស្រាយពាក់ព័ន្ធបញ្ហាចរាចរណ៍

ដើម្បីជៀងវាងការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍អ្នកបើកបរយានយន្តគ្រប់ប្រភេទត្រូវអនុវត្តវិធានដូចខាងក្រោម៖

- ត្រូវគោរពផ្លាកសញ្ញា និងគំនូសញ្ញាចរាចរណ៍
- ហាមពិសារគ្រឿងស្រវឹងដែលបណ្តាលមកពីឱ្យមានអត្រាជាតិអាល់កុលចាប់ពី០,២៥មីលីក្រាម ក្នុងមួយលីត្រខ្យល់ ឬ០,៥០ក្រាមក្នុងមួយលីត្រឈាមឡើងទៅ
- មិនត្រូវជិះបញ្ច្រាសផ្លូវរបស់អ្នកបើកបរ
- ហាមប្រើប្រាស់ទូរស័ព្ទក្នុងពេលបើកបរដោយគ្មានឧបករណ៍សំឡេងភ្ជាប់ទំនាក់ទំនង
- ត្រូវគោរពសិទ្ធិអាទិភាព
- អ្នកបើកបរយានយន្តដែលមានទំហំស៊ីឡាំងចាប់ពី៤៩សង់ទីម៉ែត្រគូប ឡើងទៅត្រូវមានបណ្ណបើកបរតាមប្រភេទយានយន្ត
- នៅពេលបើកបរយានជំនិះអ្នកបើកបរត្រូវមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ចហើយស្ថិតក្នុងស្ថានភាពដែលមិនអាចធ្វើសកម្មភាពបើកបរបានយ៉ាងស្រួល និងឆាប់រហ័សជាពិសេសលទ្ធភាពនៃការធ្វើចលនា មិនត្រូវឱ្យមានរំខានឡើយ
- ហាមធ្វើឱ្យរំខានដល់អ្នករស់នៅជាប់តាមដងផ្លូវ និងអ្នកប្រើប្រាស់ផ្លូវ
- ហាមបើកបរយានជំនិះដែលមានកង់ច្រវាក់ដែក ផ្ទាល់នឹងផ្លូវ។ យានជំនិះប្រភេទនេះត្រូវដឹកតាមយានជំនិះដែលមានប្រភេទកង់កៅស៊ូ
- ហាមផ្ទុកអ្នកដំណើរ ទំនិញ ឬវត្ថុផ្សេងៗដែលនាំឱ្យបាំងភ្នែកអ្នកបើកបរ

[27] អភិបាលខណ្ឌច្បារអំពៅ គ្រើនរំលឹកសមត្ថកិច្ចទូទាំងខណ្ឌ-សង្កាត់ ត្រូវរួមគ្នាខិតខំពង្រឹងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ឱ្យបានម៉ឺងម៉ាត់បំផុត (freshnewsasia.com) ដកស្រង់ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣។

- ទោចក្រយានយន្តអាចផ្ទុកមនុស្សពីរនាក់ និងអាចបន្ថែមបានកុមារមួយនាក់ អ្នកបើកបរទោចក្រយានយន្ត និងអ្នករួមដំណើរ ព្រមទាំងកុមារដែលមានអាយុចាប់ពី៣ឆ្នាំ ឡើងត្រូវពាក់មួកសុវត្ថិភាពឱ្យបានត្រឹមត្រូវ។[28]

**ពិន័យអន្តរការណ៍**

បុគ្គលណាដែលប្រព្រឹត្តអំពើល្មើសមិនគោរពតាមវិធានច្បាប់ និងត្រូវដាក់ពិន័យដូចខាងក្រោម ៖

**ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរទោចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្ត ឬម៉ូតូកង់បួនចំពោះអំពើល្មើសដូចខាងក្រោម ៖**

១. ត្រូវពិន័យទឹកប្រាក់ចំនួន ៦០,០០០រៀល ចំពោះអ្នកបើកបរដែលបានប្រព្រឹត្តអំពើល្មើសដូចក្រោម៖

ក. អ្នកបើកបរ និងអ្នករួមដំណើរ ព្រមទាំងកុមារដែលមានអាយុពី៣ឆ្នាំ ឡើងទៅមិនពាក់មួកសុវត្ថិភាព ឬពាក់មួកសុវត្ថិភាពដោយមិនដាក់គន្លឹះខ្សែសុវត្ថិភាព។ ការពិន័យអន្តរការណ៍ករណីល្មើសនេះ ត្រូវគិតតាមចំនួនជនប្រព្រឹត្តិបទល្មើស លើកលែងតែត្រីចក្រយានយន្ត ដែលមានដំបូលរឹងមាំបិទជិត។

ខ. បើកបរទោចក្រយានយន្តមានទំហំស៊ីឡាំងលើសពី១២៥ សង់ទីម៉ែត្រគូប ឬមានថាមពលអគ្គិសនីលើសពី១១គីឡូវ៉ាត់ ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្ត ឬម៉ូតូកង់បួន ដែលមិនបានយកភ្ជាប់តាមខ្លួននូវឯកសារដើមនៃបណ្ណបើកបរយានយន្ត។

គ. ឈប់ ឬចតល្មើសនឹងមាត្រា២៣ នៃច្បាប់ស្តីចរាចរណ៍ផ្លូវគោក។

ឃ. បើកបរដោយកុងទ័រល្បឿនមិនដំណើរការ។

ង. បើកបរលើសល្បឿនកំណត់ចាប់ពី១ ទៅ១៩គីឡូម៉ែត្រក្នុងមួយម៉ោង។

ច.បើកបរដឹកអ្នកដំណើរលើសចំណុះល្មើសនឹងចំណុចទី៨នៃមាត្រា៨ថ្មីនៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក លើកលែងករណីដឹកអ្នកជម្ងឺ។

ឆ. បើកបរមិនគោរពសញ្ញាបញ្ជាចរាចរណ៍របស់មន្ត្រីនគរបាលចរាចរណ៍។

ជ. បើកបរដោយគ្មានកញ្ចក់មើលក្រោយ។

២. ត្រូវពិន័យទឹកប្រាក់ចំនួន ៨០,០០០រៀល ចំពោះអ្នកបើកបរដែលបានប្រព្រឹត្តអំពើល្មើសដូចខាងក្រោម៖

ក. ប្រើទូរស័ព្ទនៅពេលបើកបរដោយគ្មានឧបករណ៍សម្លេងភ្ជាប់ទំនាក់ទំនង។

ខ. បើកបរសញ្ញាសូរសព្ទមិនត្រឹមត្រូវតាមប្បញ្ញត្តិច្បាប់។

គ. បើកបរដោយដាក់តាំងភ្លើង និងភ្លើងសញ្ញានៃយានមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

---

[28] ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៥។

ឃ. បើកបរល្មើសល្បឿនកំណត់ចាប់ពី២០ ទៅ២៩គីឡូម៉ែត្រក្នុងមួយម៉ោង។

៣. ត្រូវពិន័យទឹកប្រាក់ចំនួន ១០០,០០០រៀល ចំពោះអ្នកបើកបរដែលបានប្រព្រឹត្តអំពីល្មើសដូចខាងក្រោម៖

ក. បើកបរបង្ហោះ ផេចុះផេឡើង ឆាបឬគៀរ។

ខ. បើកបរអូសជន្ទល់លើផ្លូវថ្នល់ ឬព្រលែងដៃចង្កូត ឬលើកជើងដាក់លើដៃចង្កូត។

គ. បើកបរបញ្ចេញសម្លេងម៉ាស៊ីនខ្លាំង ឬផ្សែងច្រើនខុសពីបទដ្ឋានបច្ចេកទេស។

ឃ. បើកបរមិនគោរពលក្ខខណ្ឌសុខភាពតម្រូវឱ្យពាក់វ៉ែនតាដែលមានកំណត់ក្នុងបណ្ណបើកបរ។

ច. បើកបរខុសទិសចរាចរណ៍ ឬបើកបរជាន់គំនូសបង្ហូតកណ្ដាលទ្រូងផ្លូវ។

ឆ. បើកបរលើសល្បឿនកំណត់ចាប់ពី៣០ ទៅ៣៩គីឡូម៉ែត្រក្នុងមួយម៉ោង។

ជ. បើកបរល្មើសនឹងការជៀស ការបត់ និងការជែង។

ឈ. បើកបរល្មើសនឹងសិទ្ធិអាទិភាពផ្លូវប្រសព្វ។

ញ. ប្រើភ្លើងហ្វាកូត ឬភ្លើងសញ្ញាប្ដូរទិសនៃយានមិនត្រឹមត្រូវ ឬកែច្នៃភ្លើងខុសបទដ្ឋានបច្ចេកទេស។

ដ. បើកបរដោយគ្មាន ឬមិនដំណើរការភ្លើងហ្វាកូត ភ្លើងបំភ្លឺផ្លាកលេខភ្លើងសញ្ញាប្ដូរទិស ភ្លើងហ្វ្រាំង។

ឋ. បើកបរមិនគោរពភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហម ឬក្រហមភ្លឺបភ្លែតៗ។

ឌ. បើកបរមិនគោរពផ្លាកសញ្ញាហាមឃាត់ ឬផ្លាកសញ្ញាបញ្ជា ឬផ្លាកសញ្ញាសិទ្ធិអាទិភាពឬគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់។

ឍ. បើកបរផ្ទុកទំនិញល្មើសនឹងចំណុចទី១ ទី២ ទី៥ នៃមាត្រា៥៦ នៃច្បាប់ស្ដីចរាចរណ៍ផ្លូវគោក។

៤. ត្រូវពិន័យទឹកប្រាក់ចំនួន ១២០,០០០រៀល ចំពោះអ្នកបើកបរដែលបានប្រព្រឹត្តអំពើល្មើសដូចក្រោម៖

ក. បើកបរដោយគ្មានបណ្ណបើកបរ ឬក្នុងរយៈពេលដែលបណ្ណបើកបរត្រូវបានដកហូត ព្យួរទុក ឬទុកជាមោឃៈ ឬហួសសុពលភាព។

ខ. បើកបរដោយគ្មានបណ្ណសម្គាល់ និង/ផ្លាកលេខ។

គ. បើកបរដោយមិនបានត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តតាមច្បាប់កំណត់។

ឃ. ប្ដូរពណ៌យានយន្តដោយគ្មានការអនុញ្ញាត ឬបិទពណ៌មិនត្រឹមត្រូវ។

ង. ប្រើបណ្ណបើកបរមិនត្រឹមត្រូវតាមប្រភេទយានយន្ត។

ច. លេខសម្គាល់យានយន្តដែលរចនាខុសពីលក្ខណៈដើម ឬលុបលេខ ឬបាក់ផ្លាក បាត់លេខ ឬដាក់សម្ភារ ឬវត្ថុផ្សេងៗបាំងផ្លាកលេខ។

៥. ត្រូវពិន័យទឹកប្រាក់ចំនួន ១៥០,០០០រៀល ចំពោះអ្នកបើកបរដែលប្រណាំងគ្នាដោយគ្មានការអនុញ្ញាតលើផ្លូវសម្រាប់ធ្វើចរាចរណ៍ជាសាធារណៈ។

៦. ត្រូវពិន័យអន្តការណ៍ចំនួនទឹកប្រាក់ ២៥០,០០០រៀល ចំពោះអ្នកបើកបរដែលស្ថិតនៅក្នុងស្ថានភាពស្រវឹងដែលមានអត្រាជាតិអាល់កុលចាប់ពី០,២៥ ទៅ០,៣៩មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី០,៥ទៅ០,៧៩ក្រាមក្នុងមួយលីត្រឈាម។

ក្នុងករណីនេះ ត្រូវបញ្ឈប់មិនឱ្យបើកបរបន្តដំណើរទៅមុខទៀត។[29]

**ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរយានយន្តធុនស្រាល និងអ្នកបើកបរយានយន្តធុនធ្ងន់ដែលប្រព្រឹត្តិអំពើបទល្មើសដូចខាងក្រោម៖**

១. ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ៧៥,០០០រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន ១៥០,០០០រៀល ចំពោះអំពើបទល្មើសដូចខាងក្រោម៖

ក. បើកបរមិនបានយកភ្ជាប់តាមខ្លួននូវឯកសារដើមរួមមានបណ្ណបើកបរយានយន្ត និងលិខិតអនុញ្ញាតធ្វើអាជីវកម្មចំពោះរថយន្តដែលប្រកបអាជីវកម្មដឹកជញ្ជូន។

ខ. បើកបរដោយមិនពាក់ខ្សែក្រវ៉ាត់សុវត្ថិភាព។

គ. ឈប់ ឬចតល្មើសនឹងមាត្រា២៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ឃ. បើកបរដោយកុងទ័រល្បឿនមិនដំណើរការ។

ង. បើកបរដឹកអ្នកដំណើរលើសចំណុះល្មើសនឹងចំណុចទី៨ មាត្រា៨ថ្មី និងចំណុចទី៦ នៃមាត្រា៦៦ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ច. អ្នកបើកបរយានយន្តធុនធ្ងន់យានយន្តឧបករណ៍យានយន្តសណ្តោងរ៉ឺម៉ក ឬសីមីរ៉ឺម៉កបិទស្លាកសញ្ញាចាំង ពន្លឺខុសបទដ្ឋានកំណត់ ឬមិនមានបិទស្លាកសញ្ញាចាំងពន្លឺ។

២. ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ១២០,០០០រៀល និង អ្នកបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន ២២៥,០០០រៀល ចំពោះអំពើបទល្មើសដូចខាងក្រោម៖

ក. បើកបរប្រើទូរស័ព្ទគ្មានឧបករណ៍សម្លេងភ្ជាប់ទំនាក់ទំនង។

ខ. បើកបរប្រើសញ្ញាសូរសព្ទមិនត្រឹមត្រូវតាមប្បញ្ញត្តិច្បាប់។

គ. បើកបរដោយដាក់តាំងភ្លើង និងភ្លើងសញ្ញានៃយានយន្ត មិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

ឃ. បើកបរដោយគ្មានផ្លិតទឹកជូតកញ្ចក់មុខ ឬផ្លិតទឹកជូតកញ្ចក់មុខមិនដំណើរការ ឬកញ្ចក់មុខ ឬកញ្ចក់ក្រោយមានប្រេះសាំដែលលំបាកមើលផ្លូវ ឬគ្មានកញ្ចក់មើលក្រោយ។

ង. បើកបរមានប៊ូឡុងកង់ ឬអេគ្រូកង់មិនគ្រប់តាមចំនួនកំណត់នៃប្រភេទរថយន្តនីមួយៗ។

[29] អនុក្រឹត្យ ស្តីពីការកែសម្រួលក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក មាត្រា៦ថ្មី

ច. បើកបរលើសល្បឿនកំណត់ចាប់ពី១ ទៅ១៩គីឡូម៉ែត្រក្នុងមួយម៉ោង។

ឆ. បើកបររថយន្តធ្វើអាជីវកម្មផ្ទាល់ខ្លួនដឹកអ្នកដំណើរ ឬដឹកទំនិញ គ្មានសញ្ញាសម្គាល់បញ្ជាក់អំពីទំហំ ទម្ងន់រថយន្ត ទម្ងន់ផ្ទុក ចំណុះផ្ទុក ចំនួនកៅ ឬប្រើសញ្ញាសម្គាល់មិនត្រឹមត្រូវ។

ជ. បើកបរល្មើសនឹងបែបបទនៃការសណ្ដោងយានយន្តដូចមានចែងក្នុងមាត្រា១៤ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក។

ឈ. បើកបរដោយមិនបានប្រើភ្លើងសញ្ញាអាសន្ន ឬមិនបានដាក់សញ្ញាត្រីកោណជាដំណឹងក្នុងករណីដែលយានយន្តខូចមិនអាចរំកិលចេញពីទ្រូងផ្លូវបាន។

ញ. បើកបររថយន្តដឹកទំនិញមានគ្រោះថ្នាក់គ្មានសញ្ញាសម្គាល់ ឬប្រើសញ្ញាសម្គាល់មិនត្រឹមត្រូវ។

៣. ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ១៥០,០០០រៀល និង អ្នកបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន ៣០០,០០០រៀល ចំពោះអំពើបទល្មើសដូចខាងក្រោម៖

ក. បើកបរបង្អោះ ឬចុះឡើង ឆាបឬគៀរ។

ខ. បើកបរបញ្ចេញសម្លេងម៉ាស៊ីនខ្លាំង ឬផ្សែងច្រើនខុសពីបទដ្ឋានបច្ចេកទេស។

គ. បើកបរយានយន្តផ្ទាល់ខ្លួនដោយគ្មានលិខិតអនុញ្ញាតធ្វើអាជីវកម្ម ឬប្រើលិខិតធ្វើអាជីវកម្មហួសសុពលភាព។

ឃ. បើកបរមិនគោរពលក្ខខណ្ឌសុខភាពដែលតម្រូវឱ្យពាក់វ៉ែនតា។

ច. បើកបរខុសទិសចរាចរណ៍ ឬបើកបរជាន់គំនូសបង្ខូតកណ្ដាលទ្រូងផ្លូវ។

ឆ. បើកបរលើសល្បឿនកំណត់ចាប់ពី២០ ទៅ២៩គីឡូម៉ែត្រក្នុងមួយម៉ោង។

ជ. បើកបរល្មើសនឹងការជៀស ការបត់ និងការជែង។

ឈ. បើកបរល្មើសនឹងសិទ្ធិអាទិភាពផ្លូវប្រសព្វ។

ញ. ប្រើភ្លើងហ្វាកូត ឬភ្លើងសញ្ញាប្ដូរទិសនៃយានយន្តមិនត្រឹមត្រូវ ឬកែច្នៃភ្លើងខុសបទដ្ឋានបច្ចេកទេស។

ដ. បើកបរដោយគ្មានភ្លើង ឬមិនដំណើរការភ្លើងហ្វាកូត ភ្លើងសញ្ញាប្ដូរទិស ភ្លើងហ្វាំង ភ្លើងទីតាំងខាងមុខរថយន្ត និងភ្លើងក្រហមខាងក្រោយរថយន្ត។

ឋ. បើកបរមិនគោរពភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហម ឬក្រហមភ្លឹបភ្លែតៗ។

ឌ. បើកបរមិនគោរពផ្លាកសញ្ញាហាមឃាត់ ឬផ្លាកសញ្ញាបញ្ជា ឬផ្លាកសញ្ញាសិទ្ធិអាទិភាព ឬគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់។

ឍ. បើកបរប្រើប្រាស់សំបកកង់សឹកលើសកម្រិតកំណត់ ឬរហែក ឬប្រេះ ឬប៉ោង។

ណ. បើកបរមិនគោរពសញ្ញាបញ្ជាចរាចរណ៍របស់មន្ត្រីនគរបាលចរាចរណ៍។

ត. បើកបរផ្ទុកទំនិញជើងនឹងចំណុចទី១ ទី២ ទី៣ ទី៤ ទី៥ មាត្រា៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ថ. បើកបរថយន្តធុនធ្ងន់ដែលគ្មានរនាំងសុវត្ថិភាព ឬមានរនាំងសុវត្ថិភាពមិនត្រឹមត្រូវតាមតួថយន្តខាងក្រោម ឬគ្មានគន្លឹះសុវត្ថិភាពសម្រាប់ភ្ជាប់កុងតែន័រ ឬមានគន្លឹះសុវត្ថិភាពសម្រាប់ភ្ជាប់កុងតែន័រមិនគ្រប់គ្រាន់ ឬគន្លឹះសុវត្ថិភាពសម្រាប់ភ្ជាប់កុងតែន័រមិនដំណើរការ។

៤. ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ១៨០,០០០រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន ៣៧៥,០០០រៀល ចំពោះអំពើបទល្មើសដូចខាងក្រោម៖

ក. បើកបរដោយគ្មានវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ឬប្រើវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសហួសសុពលភាព។

ខ. ប្តូរពណ៌យានយន្តដោយគ្មានការអនុញ្ញាត ឬបិទពណ៌មិនត្រឹមត្រូវតាមបណ្ណសម្គាល់យានយន្ត

គ. ប្រើប្រាស់បណ្ណបើកបរមិនត្រឹមត្រូវតាមប្រភេទយានយន្ត។

ឃ. ប្រើបណ្ណបើកបរយានយន្តហួសសុពលភាព។

ង. បើកបរយានយន្តមានកង់ច្រវាក់ដែកផ្ទាល់នៅលើទ្រូងផ្លូវថ្នល់ក្រាលកៅស៊ូ។

ច. ប្រើប្រាស់ផ្លាកលេខសម្គាល់យានយន្តដែលរចនាខុសពីលក្ខណៈដើម ឬលុបលេខ ឬបាក់ផ្លាកបាត់លេខ ឬដាក់សម្ភារ ឬវត្ថុផ្សេងៗបាំងផ្លាកលេខ។

ឆ. បើកបរលើសល្បឿនកំណត់ចាប់ពី៣០ ទៅ៣៩ក្នុងមួយគីឡូម៉ែត្រ។

៥. ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ៣០០,០០០រៀល និងអ្នកដែលបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន ៦២៥,០០០រៀល ចំពោះអំពើបទល្មើសដូចខាងក្រោម៖

ក. បើកបរយានយន្តដែលកែច្នៃដំឡើងខុសបទដ្ឋានបច្ចេកទេស។

ខ. បើកបរយានយន្តប្រណាំងគ្នាដោយគ្មានការអនុញ្ញាតលើផ្លូវដែលមានអត្រាជាតិអាល់កុលចាប់ពី ០,២៥ ទៅ០,៣៩មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី០,៥ ទៅ០,៧៩ក្រាមក្នុងមួយលីត្រឈាមដូតទៅ៖

- ទឹកប្រាក់ចំនួន ៤០០,០០០រៀល សម្រាប់យានយន្តធុនស្រាល
- ទឹកប្រាក់ចំនួន ៨០០,០០០រៀល សម្រាប់យានយន្តធុនធ្ងន់។

ក្នុងករណីនេះ ត្រូវបញ្ឈប់មិនឱ្យបន្តដំណើរទៅមុខទៀត។[30]

[30] អនុក្រឹត្យលេខ ៣៩ អនក្រ.បក មាត្រា៧ថ្មី ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។

**ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរយានយន្តដោយគ្មានបណ្ណបើកបរ ឬក្នុងរយៈពេលដែលបណ្ណបើកបរត្រូវបានដកហូត ព្យួរទុក ឬទុកជាមោឃៈ ដូចតទៅ៖**

- ទឹកប្រាក់ចំនួន ១,២០០,០០០រៀល សម្រាប់យានយន្តធុនស្រាល
- ទឹកប្រាក់ចំនួន ២,៤០០,០០០រៀល សម្រាប់យានយន្តធុនធ្ងន់។

ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ ប៉ុន្តែនៅបន្តប្រព្រឹត្តបទល្មើសនេះទៀតក្នុងរយៈពេល៦ខែ ចាប់គិតពីការពិន័យអន្តរការណ៍លើកមុន ត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ត្រូវរៀបចំកំណត់ហេតុបញ្ជូនទៅអយ្យការអមសាលាដំបូង ដើម្បីចាត់វិធានការតាមច្បាប់ជាធរមាន។[31]

**ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបរយានយន្តដោយគ្មានបណ្ណសម្គាល់យានជំនិះ និង/ឬគ្មានផ្លាកលេខដូចតទៅ៖**

- ទឹកប្រាក់ចំនួន ១,២០០,០០០រៀល សម្រាប់យានយន្តធុនស្រាល។
- ទឹកប្រាក់ចំនួន ២,៤០០,០០០រៀល សម្រាប់យានយន្តធុនធ្ងន់។

ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍លើកមុនតែនៅបន្តប្រព្រឹត្តបទល្មើសនេះទៀតក្នុងរយៈពេល៦ខែ ចាប់គិតពីការពិន័យអន្តរការណ៍លើកមុន ត្រូវផ្តន្ទាទោសតាមច្បាប់ស្តីចរាចរណ៍ផ្លូវគោក។ ក្នុងករណីនេះ មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកត្រូវរៀបចំកំណត់ហេតុបញ្ជូនទៅអយ្យការអមសាលាដំបូង ដើម្បីចាត់វិធានការតាមច្បាប់ជាធរមាន។[32]

**ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរបរយានយន្តស្ថិតក្នុងភាពស្រវឹង ដែលមានអត្រាជាតិអាល់កុលចាប់ពី០,៤០មីលីក្រាមក្នុងមួយលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី០,៨០ក្រាមក្នុងមួយលីត្រឈាមឡើងទៅដូចតទៅ៖**

- ទឹកប្រាក់ចំនួន ១,០០០,០០០រៀល សម្រាប់ទោចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្ត ឬម៉ូតូកង់បួន
- ទឹកប្រាក់ចំនួន ២,០០០,០០០រៀល សម្រាប់យានយន្តធុនស្រាល។
- ទឹកប្រាក់ចំនួន ៤,០០០,០០០រៀល សម្រាប់យានយន្តធុនធ្ងន់។

[31] អនុក្រឹត្យលេខ ៣៩ អនក្រ.បក មាត្រា៨ថ្មី ស្តីពី ការកែសម្រួលអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។

[32] អនុក្រឹត្យលេខ ៣៩ អនក្រ.បក មាត្រា៩ថ្មី ស្តីពី ការកែសម្រួលអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។

ក្នុងករណីនេះ ត្រូវបញ្ឈប់មិនឱ្យបន្តដំណើរទៅមុខទៀត។

ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅប្រព្រឹត្តបទល្មើសនេះទៀតក្នុងរយៈពេល ៦ខែ ចាប់គិតពីការពិន័យអន្តរការណ៍លើកមុន ត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ ក្នុងករណីនេះ មន្ត្រីគរបាលចរាចរណ៍ផ្លូវគោកត្រូវរៀបចំកំណត់ហេតុបញ្ជូនទៅអយ្យការអមសាលាដំបូងដើម្បីចាត់វិធានការតាមច្បាប់ធរមាន។[33]

**ម្ចាស់ហាងលក់យានយន្តគ្រប់ប្រភេទដែលមិនបានបំពេញបែបបទចុះបញ្ជីយានយន្តសុំបណ្ណសម្គាល់យានយន្ត និងសុំផ្លាកលេខសម្គាល់យានយន្តឱ្យបានចាប់សព្វគ្រប់មុនប្រគល់ឱ្យអ្នកទិញ ត្រូវទទួលរងពិន័យអន្តរការណ៍ដូចតទៅ៖**

- ទឹកប្រាក់ចំនួន ១២០,០០០រៀល សម្រាប់ទោចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្ត ឬម៉ូតូកង់បួន
- ទឹកប្រាក់ចំនួន ១,២០០,០០០រៀល សម្រាប់យានយន្តធុនស្រាល។
- ទឹកប្រាក់ចំនួន ២,៤០០,០០០រៀល សម្រាប់យានយន្តធុនធ្ងន់។

**ត្រូវពិន័យអន្តរការណ៍ចំពោះនីតិបុគ្គលដែលមិនបានស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនដូចខាងក្រោម៖**

- ទឹកប្រាក់ចំនួន ១៥០,០០០រៀល សម្រាប់យានយន្តធុនស្រាល
- ទឹកប្រាក់ចំនួន ៣០០,០០០រៀល សម្រាប់យានយន្តធុនធ្ងន់។[34]

ជនណាដែលស្ថិតក្រោមឥទ្ធិពលនៃគ្រឿងញៀន មិនអនុញ្ញាតឱ្យបើកបរយានយន្តឡើយ។ អ្នកបើកបរយានយន្តស្ថិតក្រោមឥទ្ធិពលនៃគ្រឿងញៀន ត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។[35]

---

[33] អនុក្រឹត្យលេខ ៣៩ អនក្រ.បក មាត្រា១០ថ្មី ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។

[34] អនុក្រឹត្យលេខ ៣៩ អនក្រ.បក មាត្រា១១ថ្មី ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។

[35] អនុក្រឹត្យលេខ ៣៩ អនក្រ.បក មាត្រា១២ថ្មី ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។

# ជំពូកទី២
# សោភ័ណភាព និងបរិស្ថានក្នុងការរៀបចំខណ្ឌច្បារអំពៅ

# ជំពូកទី២

# សោភ័ណភាព និងបរិស្ថានក្នុងការរៀបចំខណ្ឌច្បារអំពៅ

កាលណាតំបន់មួយ ឬទីកន្លែងមួយមានភាពស្រស់ស្អាតនោះនឹងក្លាយទៅជាតំបន់មួយ ដែលពោរពេញទៅដោយភាពទាក់ទាញ ភាពល្អប្រសើរ និងភាពស្រស់បំព្រងដោយសារតែបរិស្ថាន និងអនាម័យនៅក្នុងតំបន់នោះ។ សោភ័ណភាព គឺជាអ្វីៗដែលធ្វើឱ្យកាន់តែប្រសើរឡើងជាងមុន ធ្វើឱ្យល្អហ្មត់ហ្មង និងជាអ្វីៗទាំងអស់ដែលអាចមើលឃើញនឹងភ្នែកបាន ហើយធ្វើឱ្យមានការចាប់អារម្មណ៍។

សព្វថ្ងៃនេះ បើយើងធ្វើការប្រៀបធៀបខណ្ឌច្បារអំពៅក្នុងរយៈពេល១០ឆ្នាំមុន និងពេលបច្ចុប្បន្នយើងឃើញថាសន្ទុះនៃការអភិវឌ្ឍនៅក្នុងខណ្ឌមានការផ្លាស់ប្តូរដែលគួរឱ្យកត់សម្គាល់ ជាពិសេសនោះ គឺសំដៅទៅលើបញ្ហាសោភ័ណភាពនេះឯង។ នៅក្នុងការរៀបចំនូវសោភ័ណភាពខណ្ឌ គឺអាស្រ័យទៅលើហេតុផលជាច្រើនដែលតម្រូវឱ្យអាជ្ញាធរខណ្ឌត្រូវយកចិត្តទុកដាក់ខ្លាំងជាទីបំផុត ចំណែកឯផលដែលទទួលបានពីការរៀបចំនោះមានដូចជា ធ្វើឱ្យខណ្ឌមានភាពស្រស់ស្អាត មានផាសុកភាព ជាពិសេសមានការកែលម្អពីភាពអនាធិបតេយ្យប្រែក្លាយមកជាភាពស្រស់ស្អាត មានសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយត្រឹមត្រូវតាមស្តង់ដារ ដែលធ្វើឱ្យប្រជាពលរដ្ឋនៅក្នុងខណ្ឌផ្ទាល់ មានការរស់នៅប្រកបដោយសុខដុមរមនា មានសុវត្ថិភាពទាំងផ្លូវកាយ ទាំងផ្លូវចិត្ត មានសន្តិសុខ សណ្តាប់ធ្នាប់ មានផាសុខភាព អនាម័យល្អ និងមានអារម្មណ៍ស្រស់ស្រាយជាមួយនឹងសោភ័ណភាពល្អប្រសើររបស់ខណ្ឌច្បារអំពៅ។ មូលហេតុនេះហើយ ទើបធ្វើឱ្យរដ្ឋបាលខណ្ឌច្បារអំពៅបានខិតខំប្រឹងប្រែងស្វះស្វែង កែកុន រិះរកគ្រប់មធ្យោបាយទាំងអស់ ដើម្បីស្ថាបនាឱ្យខណ្ឌច្បារអំពៅមានភាពរីកចម្រើនសុះសាយ និងមានភាពលេចធ្លោ ជាពិសេសនោះ ដើម្បីប្រកួតប្រជែងខាងផ្នែកសោភ័ណភាពស្រស់ស្អាតជាមួយខណ្ឌដទៃទៀតនៅរាជធានីភ្នំពេញ។

## ២.១. ការរៀបចំសោភ័ណភាពពេលយប់ និងពេលថ្ងៃ

ទូទៅរាល់ខណ្ឌនីមួយៗនៃរាជធានីភ្នំពេញតែងតែមានភាពអភិវឌ្ឍន៍ខ្លួន និងចង់ឱ្យខណ្ឌរបស់ខ្លួនក្លាយជាទីចាប់អារម្មណ៍ពីសំណាក់មហាជន និងមជ្ឈដ្ឋាននានា។ ការរៀបចំសោភ័ណភាពនៅក្នុងខណ្ឌភាគច្រើន គឺផ្តោតសំខាន់ទៅលើសោភ័ណភាពទាំងពេលថ្ងៃ និងទាំងសោភ័ណភាពយប់។

### ២.១.១. ការរៀបចំសោភ័ណភាពពេលយប់

សោភ័ណភាពពេលយប់ គឺសំដៅទៅលើការបំពាក់ភ្លើងបំភ្លឺតាមអគារនានា និងតាមដងមហាវិថីនានាក្នុងទីក្រុងជាពិសេសការបំពាក់ភ្លើងបំភ្លឺចម្រុះពណ៌ពេលរាត្រីនៅតាមសួនច្បារសាធារណៈផងដែរ។ ការលម្អសោភ័ណភាពនាពេលយប់មិនត្រឹមតែជាគ្រឿងលម្អតុបតែងតែប៉ុណ្ណោះទេតែជាការរៀបចំ ដែលធ្វើឱ្យទិដ្ឋភាពនៅក្នុងខណ្ឌច្បារអំពៅមានភាពប្លែក ជួយបង្កើនសម្រស់ ភាពទាក់ទាញដល់ភ្ញៀវទេសចរណ៍ឱ្យមកលេងកម្សាន្ត

បែបលក្ខណៈគ្រួសារ ឬបែបមិត្តភាពផ្សេងទៀត ជាពិសេសអាចជួយបំភ្លឺផ្លូវដល់អ្នកដំណើរ ដែលនេះក៏អាចជួយកាត់បន្ថយនូវ គ្រោះថ្នាក់ បានមួយកម្រិតផងដែរ។ ការរៀបចំសោភ័ណភាពនាពេលយប់រួមមាន៖ ការបំពាក់ភ្លើងតាមដងផ្លូវ និង ការបំពាក់ភ្លើងចម្រុះពណ៌តាមសួនច្បារ និងទីកន្លែងសាធារណៈ។

### ២.១.២. ការរៀបចំសោភ័ណភាពពេលថ្ងៃ

សំដៅទៅលើការកសាងហេដ្ឋានរចនាសម្ព័ន្ធរួមមាន ផ្លូវថ្នល់ ស្ពានប្រព័ន្ធលូ ចិញ្ចើមផ្លូវ សំណង់អាគារតូចធំទាំងរបស់រដ្ឋ និងឯកជន សួនច្បារសាធារណៈ ផ្លូវក្រោមដី និងប្រព័ន្ធសុវត្ថិភាពចរាចរណ៍រួមមាន ភ្លើងសញ្ញា ផ្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍ រួមទាំងការធ្វើដំណើរតាមដងផ្លូវនៃយានយន្តគ្រប់ប្រភេទ និងទាំងថ្មើរជើងផង ប្រកបដោយសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយថែមទៀត។ ក្នុងនោះដែរយើងសង្កេតឃើញថា នៅក្នុងខណ្ឌច្បារអំពៅមានភាពអភិវឌ្ឍន៍ខ្លាំង និងមានភាពលេចធ្លោទៅលើការដាំដើមឈើតាមដងផ្លូវ ដាំស្មៅលម្អតាមសួនច្បារ ការបង្កើតប្រព័ន្ធសុវត្ថិភាពតាមដងផ្លូវ ចិញ្ចើមផ្លូវ ការបំពាក់ភ្លើងសញ្ញា ផ្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍តាមដងផ្លូវ ព្រមទាំងបានរៀបចំសំណង់អគារធំ តាមដងផ្លូវឱ្យមានសណ្តាប់ធ្នាប់ ប្រកបទៅតាមស្តង់របស់សាលាខណ្ឌដែលបានកំណត់។

- **ការបង្កើតប្រព័ន្ធសុវត្ថិភាពតាមដងផ្លូវ៖** ការបង្កើតប្រព័ន្ធសុវត្ថិភាពដងផ្លូវ មានសារៈសំខាន់ណាស់សម្រាប់អ្នកធ្វើដំណើរគ្រប់រូប ដូចជាការបំពាក់កាំមេរ៉ាសុវត្ថិភាព ការក្សាសុវត្ថិភាពតាមផ្លូវ ចិញ្ចើមផ្លូវ ការបំពាក់ភ្លើងសញ្ញា គំនូសសញ្ញា និងផ្លាកសញ្ញាចរាចរណ៍ជាដើម។ កាំមេរ៉ាសុវត្ថិភាពមានសារៈប្រយោជន៍ចាំបាច់ណាស់ដែលបានរួមចំណែកក្នុងការកាត់បន្ថយបទល្មើសនានា តាមដានស្ថានភាពចរាចរណ៍ ការពារសន្តិសុខ សណ្តាប់ធ្នាប់ និងងាយស្រួលក្នុងការទទួលបាននូវព័ត៌មានជាក់ស្តែងពីបទល្មើសផ្សេងៗដែលកើតមានឡើងនៅក្នុងប្រទេស ជាពិសេសនៅរាជធានីភ្នំពេញតែម្តង។ បច្ចេកទេសរបស់កាំមេរ៉ាសុវត្ថិភាពត្រូវបានគេប្រើប្រាស់តាមបណ្តាប្រទេស ជាច្រើនលើសកលលោកដែលគេប្រើក្នុងគោលបំណងដើម្បីទប់ស្កាត់ បង្ក្រាប តាមចាប់បទល្មើស តាមទីសាធារណៈ ដែលបង្កើនទំនុកចិត្តដល់ភ្ញៀវទេសចរណ៍ និងអ្នកដំណើរគ្រប់រូបនៅតាមដងផ្លូវនេះ គឺជាឧទាហរណ៍ដែលល្អបំផុតសម្រាប់ប្រជាជនប្រទេសកម្ពុជាយកអនុវត្តបាន។ កាំមេរ៉ាសុវត្ថិភាពសាធារណៈមានសារៈប្រយោជន៍សម្រាប់ថតយករូបភាពពីតាំងគោលដៅ និងពីពេលវេលាជាក់លាក់ដែលបទល្មើសមួយកើតឡើង។ មិនថែមទាំងប្រើសម្រាប់ថតរូបតែប៉ុណ្ណោះទេ គឺគេអាចយកទិន្នន័យ ដើម្បីមកប្រើប្រាស់ជាប្រយោជន៍ដែលអាចជាតម្រុយនៃបទល្មើស ឬអាចជាភស្តុតាងជាក់ស្តែងសម្រាប់បទល្មើសដែលកើតមាន។ ហេតុដូចនេះហើយទើបរដ្ឋបាលរាជធានីភ្នំពេញ បានស្នើឱ្យម្ចាស់បុរី និងខុនដូទាំងអស់នៅក្នុងរាជធានីភ្នំពេញ ផ្តល់ទិន្នន័យពីកាំមេរ៉ាសុវត្ថិភាពជូនសមត្ថកិច្ច ដើម្បីពង្រឹងកិច្ចសហការជាមួយគ្នា ឱ្យបានល្អក្នុងការពារសន្តិ

សុខ សណ្តាប់ធ្នាប់ ជូនប្រជាពលរដ្ឋឱ្យកាន់តែប្រសើរហើយសមត្ថកិច្ចនឹងការសម្ងាត់ដោយមិនអនុញ្ញាតឱ្យយកទិន្នន័យចេញពីកាមេរ៉ានេះនឹងធ្វើឡើងនៅតាមច្រកសំខាន់ៗនៅក្នុងខណ្ឌទាំង១៤ នៃរាជធានីភ្នំពេញ ក្នុងនោះផងដែរខណ្ឌច្បារអំពៅដែលជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤ ដែលសម្បូរទៅដោយ ប្រជាពលរដ្ឋធ្វើដំណើរឆ្លងកាត់ ទាំងប្រជាពលរដ្ឋចំណាកស្រុក ទាំងកម្មករ កម្មការនី ទាំងមន្ត្រីរាជការតូចធំ ជាពិសេសទាំងរថយន្តគ្រប់ធុន មិនថាបែបទេសចរណ៍ រថយន្តដឹកទំនិញ រថយន្តក្រុង និងជាពិសេស ប្រភេទរថយន្តធំៗដែលដឹកទំនិញចេញចូលទៅផែរស្វ័យតទៅភ្នំពេញ ឥតឈប់ឈរ ដែលនេះជាហេតុធ្វើឱ្យសាលារាជធានីភ្នំពេញបានបំពាក់នូវកាមេរ៉ាសុវត្ថិភាពច្រើនគ្រឿង នៅតាមស្តុបសំខាន់ៗក្នុងខណ្ឌច្បារអំពៅ ដើម្បីការពារសន្តិសុខ សុវត្ថិភាពរបស់អ្នកធ្វើដំណើរ ជាពិសេសនៅពេលនៅពេលយប់ និងផ្តល់ជាភាពងាយស្រួលក្នុងការកំណត់បាននូវមុខសញ្ញាច្បាស់លាស់ ទីតាំងភស្តុតាង ពេលវេលាដែលបទល្មើសកើតមាននៅក្នុងខណ្ឌច្បារ។

- **ចំពោះបញ្ហាចិញ្ចើមផ្លូវ** ៖ ដោយសារតែស្ថានភាពចរាចរណ៍នៅលើផ្លូវជាតិលេខ១ ក្នុងតំបន់ខណ្ឌច្បារអំពៅ មានបញ្ហាកកស្ទះស្ទើរតែរៀងរាល់ថ្ងៃ ដែលបណ្តាលមកពីការដាក់តាំងលក់ទំនិញគ្រប់ប្រភេទ នៅលើចិញ្ចើមផ្លូវយ៉ាងអនាធិបតេយ្យ គ្មានសណ្តាប់ធ្នាប់ នេះជាកត្តាដែលនាំឱ្យរដ្ឋបាលធ្វើការដោះស្រាយ និងរៀបចំពោះបញ្ហានេះឱ្យបានលឿនបំផុត។ សាលាខណ្ឌក៏បានចូលរួមក្នុងការអនុវត្តនូវសេចក្តីណែនាំរបស់សាលារាជធានីភ្នំពេញ ដើម្បីធ្វើយ៉ាងណាចូលរួមថែរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ កាត់បន្ថយ ការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ផ្សេងៗ ជាពិសេសដើម្បីលើកកម្ពស់សោភ័ណភាពខណ្ឌ និងចូលរួមទប់ស្កាត់ការរីករាលនៃការឆ្លងជំងឺកូវីដ១៩ ទប់ស្កាត់ការប្រមូលផ្តុំ មនុស្សច្រើនដែលមិនបានអនុវត្តវិធានការ ៣កុំ និង៣ការពារ របស់ប្រមុខរាជរដ្ឋាភិបាល ព្រមទាំងការពារចិញ្ចើមផ្លូវតាមបណ្តោយផ្លូវជាតិលេខ១ ក្នុងតំបន់ខណ្ឌច្បារអំពៅដូចជា៖
- ហាមសាងសង់ រោងតូប និងស្តង់ដាក់តាំងលក់ទំនិញគ្រប់ប្រភេទល្មើសសណ្តាប់ធ្នាប់នៅលើផ្លូវសាធារណៈ និងតាមបណ្តោយផ្លូវជាតិលេខ១ ចំណុចផ្សារព្រែកឯង តាមបណ្តោយផ្លូវ៣៦៩ និងផ្លូវ៣៥៧ ក្នុងសង្កាត់ច្បារអំពៅទី២។
- ហាមចតត្រីចក្រយានយន្តគ្រប់ប្រភេទយ៉ាងអនាធិបតេយ្យ និងគ្មានសណ្តាប់ធ្នាប់ នៅលើផ្លូវសាធារណៈ និងតាមបណ្តោយផ្លូវជាតិលេខ១ ក្នុងសង្កាត់ព្រែកឯង និងសង្កាត់ច្បារអំពៅទី២។

តាមសេចក្តីណែនាំស្តីពីការរៀបចំ "ការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ" បានចេញសេចក្តីណែនាំទៅដល់ខណ្ឌ១៤ ក្នុងរាជធានីភ្នំពេញ ក្នុងការណែនាំដល់ប្រជាពលរដ្ឋនៅក្នុងខណ្ឌរបស់ខ្លួនចំពោះការប្រើប្រាស់ដីផ្លូវ ក៏ដូចជាចិញ្ចើមផ្លូវដោយ

ស្របតាមការកំណត់របស់រដ្ឋបាលរាជធានីភ្នំពេញ ក្នុងគោលដៅ ដោះស្រាយបញ្ហាកកស្ទះចរាចរណ៍ និងលើកកម្ពស់សោភ័ណភាពទីក្រុង ខណ្ឌ និងធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ចិញ្ចើមផ្លូវ ទាំងផ្នែកខាងលើ និងផ្នែកខាងក្រោមដីសម្រាប់បម្រើជាផលប្រយោជន៍ដល់សាធារណៈជនស្របតាមលក្ខណៈបច្ចេកទេស។ ក្នុងសេចក្តីណែនាំនោះសាលារាជធានីភ្នំពេញបានកំណត់ឱ្យប្រើប្រាស់ចិញ្ចើមផ្លូវដូចខាងក្រោម ៖

- ចិញ្ចើមផ្លូវទុកបម្រើដល់ការធ្វើចរាចរណ៍ដោយថ្មើរជើង
- បម្រើសកម្មភាពដូចជា សកម្មភាពវប្បធម៌ កីឡា ការតាំងពិព័រណ៍ និងពិធីបុណ្យផ្សេងទៀត នៅលើដងផ្លូវ ប៉ុន្តែត្រូវមានអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ទៅតាមកម្រិតនៃពិធី និងតាមភាពចាំបាច់
- បម្រើសកម្មភាពដឹកនាំជីកកប់បណ្តាញក្រោមដីដូចជា បណ្តាញទឹកស្អាត ប្រព័ន្ធលូ ខ្សែបញ្ជូនអគ្គីសនី បំពង់ទុយោ ខ្សែកាបអុបទិចគ្រប់ប្រភេទ និងបរិក្ខារក្រោមដីផ្សេងៗទៀត
- បម្រើសកម្មភាពសាងសង់ក្នុងគម្រោងចាំបាច់មួយចំនួនដូចជា បរិក្ខារបម្រើឱ្យវិស័យការពារជាតិសន្តិភាពជាតិ បរិក្ខារបម្រើឱ្យការគ្រប់គ្រង ឬការសាងសង់ផ្លូវ និងបរិក្ខារសំណង់សេវាសាធារណៈផ្សេងៗទៀតតាមការចាំបាច់
- សម្រាប់ប្រជាពលរដ្ឋដែលជាម្ចាស់លំនៅដ្ឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន អ្នកគ្រប់គ្រងមន្ទីរពេទ្យ គ្រឹះស្ថានអប់រំ អគារសាធារណៈ វិស័យឯកជន និងអ្នកប្រើប្រាស់ចិញ្ចើមផ្លូវត្រឹម១/៣ សម្រាប់ការរៀបចំសម្ភារទំនិញ ម៉ូតូ និងរថយន្តដាក់តាំងលក់ ជាលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ ដោយទុក២/៣ សម្រាប់ថ្មើរជើង និងបម្រើឱ្យការងារសណ្តាប់ធ្នាប់ និងចរាចរណ៍។ រាល់ការប្រើប្រាស់ចិញ្ចើមផ្លូវជាទីតាំងផ្ញើរកង់ ម៉ូតូ មិនត្រូវឱ្យលើសពី ១/៣ នៃចិញ្ចើមផ្លូវឡើយ។

ដោយឡែករដ្ឋបាលខណ្ឌក៏បានដាក់កំហិតទៅអ្នកដែលបានសង់រោងតូប ឬស្តង់ដាក់តាំងលក់ទំនិញគ្រប់ប្រភេទ ល្មើសសណ្តាប់ធ្នាប់ត្រូវរុះរើចេញវិញដោយខ្លួនឯង ក្នុងរយៈពេល០៣ថ្ងៃ គិតចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ ដែលបានចេញ សេចក្តីជូនដំណឹងនេះតទៅ។ ក្នុងករណី ចរចេសរឹងរូសមិនបានអនុវត្តតាមការណែនាំខាងលើ រដ្ឋបាលនឹងចុះអនុវត្តវិធានការរដ្ឋបាលដោយមិនទទួលខុសត្រូវ ចំពោះការបាត់បង់ទ្រព្យសម្បត្តិ ឬខូចខាតសម្ភារអ្វីឡើយ។

- **ការបំពាក់ភ្លើងសញ្ញាចរាចរណ៍** ៖ ការបំពាក់ភ្លើងសញ្ញា គំនូសសញ្ញា និងផ្លាកសញ្ញាចរាចរណ៍តាមផ្លូវត្រូវបានចែងក្នុងជំពូកទី២ មាត្រា៥ នៃច្បាប់ចរាចរណ៍ផ្លូវគោក ដែលចែងថា៖ សញ្ញាចរាចរណ៍ផ្លូវគោករួមមាន ផ្លាកសញ្ញាចរាចរណ៍តាមផ្លូវភ្លើងសញ្ញាចរាចរណ៍ គំនូសសញ្ញានៅលើដងផ្លូវ សញ្ញាបញ្ជារបស់ភ្នាក់ងារចរាចរណ៍ និងសញ្ញាផ្សេងៗទៀត។ ផ្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ និងគំនូសសញ្ញាចរាចរណ៍ និងសញ្ញាចរាចរណ៍នៅលើដងផ្លូវត្រូវរៀបចំជាប្រព័ន្ធទាក់ទងស៊ីសង្វាក់គ្នាជាហូរហែ

នៅតាមកន្លែងមានសារៈប្រយោជន៍ដែលធ្វើឱ្យអ្នកប្រើប្រាស់ផ្លូវ ងាយស្រួលមើលឃើញ។ សញ្ញាគ្រោះថ្នាក់នៅតាមដងផ្លូវដែលមានលក្ខណៈមិនអចិន្ត្រៃយ៍ ត្រូវដាក់ក្នុងចម្ងាយ សមស្របល្មមគ្រប់គ្រាន់តាមប្រភេទផ្លូវ ចំណាត់ថ្នាក់ផ្លូវ និងស្ថានភាពផ្លូវ ដែលធ្វើឱ្យអ្នកបើកបរមានស្មារតីប្រុងប្រយ័ត្នជាមុនបាន។

ចំណែកនៅក្នុងខណ្ឌច្បារអំពៅវិញ ការរៀបចំដំឡើងភ្លើងសញ្ញាចរាចរណ៍ ត្រូវបានស្ថាបនាដោយក្រុមការងារបច្ចេកទេសរបស់មន្ទីរសាធារណៈការរាជធានីភ្នំពេញ សហការជាមួយក្រុមការងារបច្ចេកទេសមកពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ដែលហៅកាត់ថា JICA។

- **ការដាក់គំនូសសញ្ញាចរាចរណ៍៖** ការដាក់គំនូសសញ្ញាចរាចរណ៍មានសារៈសំខាន់សម្រាប់អ្នកធ្វើដំណើរតាមដងផ្លូវ ដែលបានបង្កលក្ខណៈងាយស្រួលសម្រាប់អ្នកបើកបរ និងអ្នកថ្មើរជើងដែលបានធ្វើការបែងចែកសិទ្ធិអាទិភាពនៃការបើកបរលើដងផ្លូវដូចជាគំនូសសញ្ញាពណ៌សកាត់ទទឹងផ្លូវ គំនូសសញ្ញាតាមបណ្តោយទ្រូងផ្លូវ គំនូសសញ្ញាព្រួញលើទ្រូងផ្លូវគំនូសសញ្ញាផ្សេងៗលើទ្រូងផ្លូវ។
- **ការដាក់ផ្លាកសញ្ញាចរាចរណ៍៖** ចំពោះការដាក់នូវផ្លាកសញ្ញាចរាចរណ៍សាលារាជធានីភ្នំពេញបានរៀបចំដាក់តាមបណ្តោយផ្លូវនានានៅក្នុងខណ្ឌទាំង១៤ ដើម្បីផ្តល់ព័ត៌មានសម្រាប់អ្នកបើកបរក៏ដូចជាអ្នកដំណើរថ្មើរជើង ឱ្យមានការប្រុងប្រយ័ត្នកាន់តែខ្ពស់ជាងមុន ព្រមទាំងជួយកាត់បន្ថយ ក៏ដូចជាបញ្ចៀសនូវបញ្ហាគ្រោះថ្នាក់ចរាចរណ៍ ដែលបានកើតឡើងជាយថាហេតុ។

## ២.២. បរិស្ថានខណ្ឌច្បារអំពៅ

### ២.២.១. លក្ខណៈទូទៅ និងហេតុបង្កនាំឱ្យមានការបំពុលបរិស្ថាន

ការបំពុលបរិស្ថាន គឺជាការបង្កភាពកង្វក់ទៅលើសារធាតុ និងជីវចម្រុះគ្រប់ប្រភេទលើភពផែនដីតាមរយៈការបញ្ចេញសារធាតុពុលគ្រប់ទម្រង់ រឹង រាវ ឧស្ម័ន ដូចនេះបញ្ហានៃការបំពុលបរិស្ថាន គឺជាការព្រួយបារម្ភចម្បងមួយដែលប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាលកំពុងតែប្រឈមមុខ។ ការបំពុលបរិស្ថានដែលយើងតែងតែជួបប្រទះរួមមាន ការបំពុលទឹក ដី ខ្យល់ សំណល់ និងសំឡេង។[36]

### ២.២.២. ស្ថានភាពបរិស្ថានក្នុងខណ្ឌច្បារអំពៅ

នៅក្នុងខណ្ឌច្បារអំពៅនាពេលបច្ចុប្បន្នយើងសង្កេតឃើញថា កំណើនប្រជាពលរដ្ឋគឺពិតជាមានការកើនឡើងជាលំដាប់ដែលជាហេតុនាំឱ្យមានការរីកចម្រើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ ជាក់ស្តែងទន្ទឹមនេះ និងការអភិវឌ្ឍតតឈប់ឈរ និងការរីកចម្រើនស្ទើរតែគ្រប់វិស័យទាំងនេះ យើងឃើញថាបញ្ហាផ្សេងៗជាច្រើនកំពុងកើតមានឡើង ដែលជាហេតុនាំឱ្យមានការបំពុលបរិស្ថាន។ សព្វថ្ងៃនេះ បញ្ហាបរិស្ថាន ជាបញ្ហាចម្បងមួយក្នុង

[36] https://opendevelopmentcambodia.net/km/topics/pollution-and-waste/ដកស្រង់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣។

ចំណោមបញ្ហាដទៃទៀតដែលនាំឱ្យមានផលប៉ះពាល់ និងងាយគ្រោះថ្នាក់បំផុតដល់ការរស់នៅ ការប្រកបរបរ និងសុខភាពរបស់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈផងដែរ ដោយសារការបំពុលបរិស្ថាន។

**២.២.២.១. ការបំពុលទឹក**

ជាការពិតណាស់ទឹកមានសារៈសំខាន់សម្រាប់ការទ្រទ្រង់ជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្ស សត្វ រុក្ខជាតិ ឬភាវៈរស់មានជីវិតដែលរស់នៅក្នុងភពផែនដី។ មិនតែប៉ុណ្ណោះទឹក គឺជាផ្នែកមួយដ៏សំខាន់ដែលជួយជំរុញឱ្យសេដ្ឋកិច្ចក្នុងប្រទេសមានការអភិវឌ្ឍ និងការរីកចម្រើនយ៉ាងខ្លាំងស្ទើរតែគ្រប់វិស័យក្នុងនោះមានដូចជាវិស័យឧស្សាហកម្ម កសិកម្ម សិប្បកម្ម គមនាគមន៍ ទេសចរណ៍ រួមទាំងវិស័យផ្សេងៗទៀតផងដែរ។ ប៉ុន្តែប្រសិនបើប្រភពទឹកដ៏សំខាន់ទាំងនោះត្រូវបានរងនូវការបំពុល ឬបង្កឱ្យកើតមានឡើងដូចជា ការបង្ហូរលូទឹកស្អុយចូលទៅក្នុងទឹក ការចាក់ប្រេង កាកសំណល់រឹង រាវ កម្ទេចកម្ទី សំរាម និងសារធាតុគីមីផ្សេងៗចូលទៅក្នុងទឹកដែលនាំឱ្យមានកង្វក់ទឹក ជាហេតុធ្វើឱ្យមានផលប៉ះពាល់ដល់ការរស់នៅរបស់មនុស្ស សត្វ និងរុក្ខជាតិ ដែលរស់នៅទីនោះផងដែរ។

ការបំពុលទឹក គឺជាការធ្វើឱ្យកង្វក់ដល់ទឹក នៅពេលដែលសារធាតុបំពុលនានាបានហូរចូលទៅក្នុងប្រភពទឹក។[37] ការបំពុលទឹក ជាបញ្ហាមួយដែលកើតឡើងស្ទើរតែគ្រប់ប្រទេសទាំងអស់នៅទូទាំងពិភពលោក។ ជាក់ស្តែងកើតចេញពីកន្លែងមួយចំនួនដូចជាទីក្រុង ទីប្រជុំជន និងទីកន្លែងកម្សាន្តនានាជាដើម។

កត្តាដែលនាំឱ្យមានការបំពុលទឹកមានដូចជា៖

- ការបំពុលដោយសកម្មភាពរបស់មនុស្សដូចជា ការចោលសំរាមចូលទៅក្នុងទឹក
- ការបន្ទោរបង់ចូលក្នុងទឹក ការបង្ហូរលូទឹកសម្អុយចូលទៅក្នុងទឹក និងការបង្ហូរកាកសំណល់ផ្សេងដែលនាំឱ្យទឹកកខ្វក់
- ការបំពុលដោយសារធាតុគីមីផ្សេងៗដែលចេញពីរោងចក្រឧស្សាហកម្ម សិប្បកម្ម
- ការបំពុលដោយសំណល់រឹងរាវមានដូចជាថង់ប្លាស្ទិកកម្ទេចកម្ទីដែកសំបកកំប៉ុងសំបកដបជ័រចូលទៅក្នុងទឹក
- បង្ហូរចូលទៅក្នុងទឹកដែលក្នុងនោះរួមមាន ឧស្ម័នពុល (កាឌីមីញ៉ូម និងអាសេនិច) ជីគីមី និងថ្នាំសម្លាប់សត្វល្អិតជាដើម
- ការបំពុលដោយកាកសំណល់វិទ្យុសកម្ម
- ការបំពុលដោយការចាក់ប្រេង ឬការធ្លាយប្រេងសាំងចូលទៅក្នុងទឹក

[37] https://opendevelopmentcambodia.net/km/topics/water-pollution ដកស្រង់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣។

- ការបង្ហូរកាកសំណល់ចេញពីរោងចក្រឧស្សាហកម្មចូលទៅក្នុងទឹក។

ជាក់ស្តែងសកម្មភាពនៃការបំពុលទឹកទាំងអស់នេះ គឺបានជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់មនុស្ស សត្វ រុក្ខជាតិ និងបរិស្ថាន ព្រមទាំងធ្វើឱ្យប៉ះពាល់ដល់ទីក្រុង និងទីប្រជុំជនផងដែរ។ មិនតែប៉ុណ្ណោះប្រសិនបើកង្វះការយល់ដឹងតាមរយៈការប្រើប្រាស់ និងការបរិភោគទឹកមិនស្អាត អាចបណ្តាលឱ្យប៉ះពាល់ដល់សុខភាពមនុស្ស និងមានជំងឺឈឺស្កាត់កើតឡើង។ ការបំពុលទឹកនេះវាក៏បានធ្វើឱ្យប៉ះពាល់ទៅដល់វិស័យមួយចំនួនផងដែរដូចជាវិស័យកសិកម្ម នៅពេលដែលយើងយកទឹកដែលត្រូវបានបំពុលដោយសារធាតុគីមីបង្កឡើងដោយឧស្ម័នពុលកម្មេចកម្មីប្លាស្ទិក ជីគីមី ថ្នាំសម្លាប់សត្វល្អិត និងសារធាតុគីមីផ្សេងៗទៀតដែលមាននៅក្នុងប្រភពទឹក ហើយយកមកប្រើប្រាស់ដើម្បីស្រោចស្រពលើដំណាំលទ្ធផលប្រាកដណាស់ធ្វើឱ្យដំណាំទាំងនោះខូចខាត ខូចគុណភាព ព្រមទាំងគ្មានទីផ្សារធ្វើឱ្យប្រជាពលរដ្ឋបាត់បង់នូវប្រាក់ចំណូលថែមទៀតផងដោយសារតែការបំពុលទឹក។

**២.២.២.២. ការបំពុលដី**

ការបំពុលដី គឺជាដំណើរការនៃការរិចរិលគុណភាពនៃផ្ទៃផែនដីដែលបណ្តាលមកពីសារធាតុគីមី និងដំណើរការផ្សេងទៀតនៃអន្តរាគមន៍របស់មនុស្ស[38]។ ការបំពុលដី ជាបញ្ហាប្រឈមមួយដែលកំពុងកើតមានឡើងនាពេលបច្ចុប្បន្ន ហើយវាបានជះឥទ្ធិពលខ្លាំងបំផុតដល់អ្នកដែលរស់នៅតាមបណ្តាលខេត្តដែលប្រកបរបបកសិកម្មនៅទីនោះ។ ថ្វីត្បិតតែ ការបំពុលដីនេះមិនសូវជះឥទ្ធិពលដល់អ្នករស់នៅទីក្រុងក៏ដោយ ប៉ុន្តែការបំពុលនេះ គឺធ្វើឱ្យប៉ះពាល់វិស័យកសិកម្មមួយចំនួនដូចជា ការបំពុលដីធ្វើឱ្យមានការថយចុះសារធាតុចិញ្ចឹមនៅក្នុងដី ការថយចុះនូវជីវចម្រុះ និងធ្វើឱ្យដីមានភាពលំបាកក្នុងការដាំដុះដំណាំ[39] នាំឱ្យទិន្នផលកសិកម្មមានការធ្លាក់ចុះ ព្រមទាំងបាត់បង់នូវប្រព័ន្ធអេកូឡូស៊ីទៀតផងដែរ។ មិនតែប៉ុណ្ណោះ កត្តាដ៏ធំចម្បងបំផុតជាងគេដែលដីងាយ និងទទួលរងនូវការបំពុលនោះគឺ ការបំពុលដោយសំរាម និងកាកសំណល់ផ្សេងៗ។ បញ្ហាសំរាមតែងតែកើតមានឡើងនូវគ្រប់ទិសទី មិនថាទីណាកន្លែងណា ឬប្រទេសណានោះទេសុទ្ធតែមានសំរាម។ ការទុកដាក់ការចោលសំរាមដែលមិនបានត្រឹមត្រូវ ឬការចោលវាលពាសកាលទៅលើដី ជាហេតុនាំឱ្យដីទទួលរងនូវផលប៉ះពាល់ដោយសារការបំពុលនេះ ព្រោះប្រភេទសំរាមខ្លះជាប្រភេទសំរាមដែលត្រូវប្រើរយៈពេលយូរទើបអាចរលាយអស់ (សំបកដប ឬជ័រ) ដូច្នេះហើយ ដីទាំងនោះត្រូវបាត់បង់នូវគុណភាព និងជីវជាតិហើយមិនអាចមិនអាចយកមកប្រើប្រាស់បានឡើងវិញទៀតនោះទេ។

កត្តាដែលនាំឱ្យមានការបំពុលដីមានដូចជា៖

- ការអនុវត្តប្រព័ន្ធធារាសាស្ត្រទាបបង្កើនឱ្យដីមានជាតិប្រៃ

[38] https://km.warbletoncouncil.org/contaminacion-del-suelo-3188 ដកស្រង់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣។

[39] https://opendevelopmentcambodia.net/km/topics/air-pollution/ដកស្រង់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣។

- ការបំពុលកាកសំណល់ឧស្សាហកម្ម
- ការប្រើប្រាស់ជីគីមី ថ្នាំសម្លាប់សត្វល្អិត ថ្នាំពុលច្រើនហួសកម្រិត។

**២.២.២.៣. ការបំពុលខ្យល់**

ខ្យល់ត្រូវបានបំពុលនៅពេលដែលប៉ះពាល់នឹងភាពកខ្វក់នៃឧស្ម័នពុល និងភាគល្អិតតូចៗដែលបញ្ចេញពីរោងចក្រឧស្សាហកម្ម ព្រមទាំងមធ្យាបាយដឹកជញ្ជូនទៅក្នុងបរិយាកាសខាងក្រៅ[40]។ ជាទូទៅការបំពុលខ្យល់ គឺមានសភាពធ្ងន់ធ្ងរខ្លាំងណាស់នៅក្នុងខណ្ឌច្បារអំពៅ តំបន់ឧស្សាហកម្ម តំបន់ទំនាប ឬតំបន់ដែលឡោមព័ទ្ធដោយទីប្រជុំជន និងកន្លែងជាច្រើនទៀតដែលមានខ្យល់មិនល្អ មិនបរិសុទ្ធ ជាហេតុនាំឱ្យមានការបំពុលខ្យល់កើតឡើង។

កត្តាដែលនាំឱ្យមានការបំពុលខ្យល់កើតឡើង មានដូចជា៖

- ការដុតឥន្ទនៈផូស៊ីល (ប្រេង ធ្យូង ម៉ាស៊ូត សាំង)
- ការដុតបំផ្លាញព្រៃឈើ
- ផ្សែងពុលចេញពីរោងចក្រឧស្សាហកម្មធំៗ សហគ្រាស
- ឧស្ម័នផ្ទះកញ្ចក់ សារធាតុគីមី
- ការបំពុលដោយធូលី
- ការបម្រែបម្រួលអាកាសធាតុ
- ភ្លៀងអាស៊ីត។

ការបំពុលខ្យល់នេះមិនត្រឹមតែធ្វើឱ្យមានការបំផ្លាញទៅលើអាកាសធាតុ និងបរិស្ថានប៉ុណ្ណោះទេ វាក៏ធ្វើឱ្យប៉ះពាល់ខ្លាំងទៅដល់សុខភាពមនុស្សសត្វផងដែរ ព្រោះថាជីវិតមនុស្សរស់នៅត្រូវការខ្យល់ដើម្បីដកដង្ហើម ប៉ុន្តែបើយើងរស់នៅជាមួយបរិស្ថានដែលពោរពេញទៅដោយការបំពុល និងស្រូបយកខ្យល់ដែលមានជាតិពុលជារៀងរាល់ថ្ងៃទៀតវាអាចបណ្ដាលឱ្យយើងមានជំងឺជាច្រើនដូចជា ជំងឺមហារីក មហារីកសួត ក្អក គាំងបេះដូង ព្រមទាំងជំងឺផ្សេងៗទៀតដែលពាក់ព័ន្ធទៅ និងជំងឺផ្លូវដង្ហើមដោយសារតែការបំពុលខ្យល់[41]។

**២.២.២.៤. ការបំពុលសំណល់រឹង រាវ**

[40] https://km.eferrit.comនិយមន័យការបំពុលខ្យល់

[41] https://km.hesperian.org/hhg/A_Community_Guide_to_Environmental_Health ដកស្រង់ថ្ងៃទី ០២ ខែមិថុនា ឆ្នាំ ២០២៣។

សំណល់រឹង គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង សម្ភារទាំងឡាយណាដែលពុំមានតម្លៃសម្រាប់ប្រើប្រាស់ ហើយត្រូវបានគេបោះបង់ចោល[42]។

ដើម្បីឱ្យមានភាពងាយស្រួលនៅក្នុងការដឹកជញ្ជូន ការប្រមូល និងការចាត់ចែងគ្រប់គ្រងសំណល់រឹងឱ្យបានល្អ គេបានបែងចែកប្រភេទនៃសំណល់រឹងជាច្រើនប្រភេទផ្សេងៗគ្នាដូចជា សំណល់ដែលចេញពីលំនៅដ្ឋាន មន្ទីរពេទ្យ សាលារៀន រោងចក្រឧស្សាហកម្ម ពាណិជ្ជកម្ម និងសំណល់កសិកម្មជាដើម។ សំណល់រឹងនេះមិនត្រឹមតែបែងចែកជាច្រើនប្រភេទប៉ុណ្ណោះទេ គេថែមទាំងបែងចែកជាចំណាត់ថ្នាក់ទៀតផង ដោយចែកចេញជា ២ ចំណាត់ថ្នាក់ធំៗគឺ សំណល់រឹងប្រកបដោយភាពគ្រោះថ្នាក់ និងសំណល់រឹងមិនបង្កគ្រោះថ្នាក់ (សំណល់ធម្មតា)។ សំណល់រឹងប្រកបដោយភាពគ្រោះថ្នាក់ គឺសំដៅទៅលើសារធាតុវិទ្យុសកម្មដូចជា ផ្ទុះ ពុល ឆេះ បង្កឱ្យមានជំងឺមហារីក ចម្លងជំងឺ ធ្វើឱ្យរលាក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីផ្សេងទៀតដែលអាចនាំឱ្យមានគ្រោះថ្នាក់ទៅដល់មនុស្ស សត្វ ឬធ្វើឱ្យមានការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថានផងដែរ។ សំណល់ប្រកបដោយគ្រោះថ្នាក់អាចមានប្រភពពីលំនៅដ្ឋាន រោងចក្រ ឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និងសេវាកម្មអាជីវកម្មផ្សេងៗ[43] សំណល់ប្រកបដោយភាពគ្រោះថ្នាក់ភាគច្រើនកើតចេញរោងចក្រឧស្សាហកម្ម សហគ្រាសធំៗមួយចំនួនដូចជា រោងចក្រផលិតថ្នាំសម្លាប់សត្វល្អិត ជីគីមី ថ្នាំពេទ្យ ថ្នាំលាប និងរោងចក្រសហគ្រាសផ្សេងៗទៀតដែលប្រើប្រាស់សារធាតុគីមី ឬសារធាតុផ្សេងទៀតដែលប្រកបទៅដោយភាពគ្រោះថ្នាក់។

ចំណែកឯសំណល់នៅតាមលំនៅដ្ឋានក៏អាចបង្កឱ្យមានភាពគ្រោះថ្នាក់ផងដែរ គ្រាន់តែកម្រិតនៃភាពគ្រោះថ្នាក់មានបន្តិចបន្តួចតែប៉ុណ្ណោះ បើក្រឡេកទៅមើលវិស័យកសិកម្មវិញដោយសារតែបច្ចេកទេសក្នុងការប្រើប្រាស់របស់យើងនៅមានកម្រិត ហើយកសិករមួយចំនួនទៀតមិនទាន់មានការយល់ដឹងអំពីការប្រើប្រាស់ជីគីមី ឬថ្នាំសម្លាប់សត្វល្អិតដែលមានជាតិពុលខ្លាំងជាហេតុអាចបង្កឱ្យមានគ្រោះថ្នាក់ ពីព្រោះសារធាតុទាំងនោះ គឺសម្បូរទៅដោយជាតិពុលខ្ពស់។ រីឯប្រភេទសំណល់រឹងដែលមិនបង្កគ្រោះថ្នាក់ដល់សុខភាពរបស់មនុស្ស សត្វ និងរុក្ខជាតិ ហើយសំណល់ទាំងនោះមានដូចជា សំណល់ផ្ទះបាយ កម្ទេចកម្ទី ថង់ប្លាស្ទិកពីទីផ្សារទីសាធារណៈ និងភោជនីយដ្ឋានជាដើម។ ទោះបីជាសំណល់ទាំងនេះមិនបង្កឱ្យមានគ្រោះថ្នាក់ក៏ពិតមែន ប៉ុន្តែបើយើងទុកដាក់វេចខ្ចប់វាមិនបានល្អ ឬគ្មានអនាម័យនោះនឹងធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់មនុស្សហើយនាំឱ្យកើតមានជំងឺផ្សេងៗទៀតផងដែរ។[44]

---

[42] https://www.khsearch.com/qna/5780 ស្រង់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣។

[43] មាត្រា៣ នៃអនុក្រឹត្យ លេខ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៦។

[44] https://comped-cam.org/Documents/developmentguideline/Environmental.pdf ដកស្រង់ថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០២៣។

សំណល់រាវ គឺសំដៅទៅដល់ប្រភពទឹកមានផ្ទុកសារធាតុគីមីដែលបំពុលដល់បរិស្ថានដែលបញ្ចេញពីរោងចក្រសហគ្រាស លំនៅដ្ឋាន មន្ទីរពេទ្យ ឧស្សាហកម្ម ឬសេវាកម្ម។[45] សំណល់ប្រភេទនេះសុទ្ធតែជាហេតុបង្កឱ្យមានការបំពុលដល់បរិស្ថាន។ សំណល់រាវបង្កឡើងពីការបន្ទោរបង់ ការបោកខោអាវ ការលាងបន្លែ ផ្លែឈើ ត្រីសាច់ ចេញពីរោងចក្រ ឧស្សាហកម្មគីមី ឧស្សាហកម្មតម្បាញ ឧស្សាហកម្មប្រេង ឧស្សាហកម្មលោហៈធាតុ និងសំណល់វេជ្ជសាស្ត្រដូចជា ឈាម និងទឹករំអិលជាដើម។ សារធាតុគីមីពុលគ្រោះថ្នាក់ដូចជា ភ្លុយអរ ផូស្វរ ស៊ីលីស្យូម អាម៉ូញាក់ នីទ្រីត អាចធ្វើឱ្យដី និងទឹកខូចគុណភាព ព្រមទាំងបង្កគ្រោះថ្នាក់ដល់សុខភាព សត្វ និងជីវចម្រុះ។ បើចំពោះមនុស្សវិញអាចបង្កផលប៉ះពាល់ខ្លាំង ជាពិសេសសុខភាពតែម្តងបណ្តាលឱ្យមានជំងឺជាច្រើនកើតឡើងដូចជា ជំងឺគ្រុនចាញ់ គ្រុនពោះវៀន និងរាគរូសជាដើម ពីព្រោះមនុស្សអាចឆ្លងរោគតាមរយៈការបរិភោគ និងការប្រើប្រាស់ទឹកដែលមានសារធាតុពុល ឬកន្លែងផ្សេងៗទៀតដែលមានសារធាតុពុល។

ដូចនេះ ប្រសិនបើមិនមានការគ្រប់គ្រងឱ្យបានល្អនោះទេ ការបំពុលគឺមានផលប៉ះពាល់ជាច្រើន ដែលអាចកើតមានឡើងចំពោះ សុខភាពមនុស្ស សត្វ រុក្ខជាតិ និងបរិស្ថាន។

#### ២.២.២.៥. ការរំខានដោយសំឡេង

ការបំពុលដោយសំឡេង ឬសំឡេងរំខានខ្លាំងៗបានជះឥទ្ធិពលដល់បរិស្ថាន នៃទីកន្លែងជាក់លាក់ណាមួយ។ ទោះបីជាសំឡេងទាំងនោះ មិនធ្វើឱ្យប៉ះពាល់ដូចការបំពុលផ្សេងៗក៏ដោយ ប៉ុន្តែវាអាចបង្កឱ្យអន្តរាយដល់អាយុជីវិតរបស់មនុស្សដទៃទៀតដែរ។ ការបំពុលដោយសំឡេងនេះ គឺបង្កឡើងដោយសំឡេងយន្តហោះ សំឡេងចរាចរណ៍ ទូក រថយន្ត ម៉ូតូ សំឡេងតន្ត្រី ឧបករណ៍បំពងសំឡេង ព្រមទាំងម៉ាស៊ីននៅក្នុងរោងចក្រជាដើម។ ការបំពុលសំឡេងត្រូវបានបែងចែកជា២ប្រភេទគឺ ការបំពុលសំឡេងដោយប្រភពចល័ត និងការបំពុលសំឡេងដោយប្រភពអចល័ត។

ការបំពុលដោយប្រភពចល័ត គឺសំដៅទៅលើប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ មានន័យថាការដែលមិននៅឈប់ស្ងៀមមួយកន្លែង ហើយការបំពុលនោះអាចកើតចេញពី យានយន្ត ទោចក្រយានយន្ត គ្រឿងយន្ត យន្តហោះ នាវាដឹកជញ្ជូន និងគ្រឿងបំពង់សំឡេងផ្សេងៗគ្រប់ប្រភេទ។ ចំណែកឯការបំពុលដោយប្រភពអចល័តវិញ គឺសំដៅទៅលើប្រភពដែលនៅទីតាំងអចិន្ត្រៃយ៍មួយកន្លែង មានន័យថាជាការដែលនៅឈប់ស្ងៀមមួយកន្លែង ហើយការបំពុលនេះអាចកើតចេញពីរោងចក្រ សហគ្រាស ការដ្ឋានសំណង់ ឡដុតសំរាម សិប្បកម្ម និងឧបករណ៍បំពង់សំឡេងដែលចេញពីកន្លែងកម្សាន្ត ឬក្លឹបកម្សាន្តផ្សេងៗជាដើម។ ការបំពុលដោយសំឡេងនេះបានផ្តល់ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ទៅដល់សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់មនុស្សដូចជា អាចបណ្តាលឱ្យ

[45] មាត្រា៤ អនុក្រឹត្យ លេខ២៣៥ អនក្រ.បក ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧

មានការតានតឹង ថប់អារម្មណ៍ បង្កឱ្យកើតជាជំងឺផ្លូវចិត្ត ការគាំងបេះដូង កាត់បន្ថយនូវការចងចាំ ការស្តាប់ និង អាចឈានទៅដល់ការបាត់បង់អាយុជីវិតថែមទៀតផង[46]។

### ២.២.៣. ដំណោះស្រាយពាក់ព័ន្ធ និងការបំពុលបរិស្ថានក្នុងខណ្ឌច្បារអំពៅ

#### ២.២.៣.១. ដំណោះស្រាយពាក់ព័ន្ធការបំពុលទឹក

យើងដឹងរួចមកហើយថា ចំពោះបញ្ហានីមួយៗដែលបានកើតឡើង គឺតែងតែមានដំណោះស្រាយ និង ការទប់ស្កាត់ជានិច្ច។ ជាក់ស្តែង ចំពោះបញ្ហានៃការបំពុលទឹកនេះ យើងក៏មានវិធានការក្នុងការដោះស្រាយដូចគ្នា ទៅ និងបញ្ហាផ្សេងៗដែរក្នុងនោះរួមមានៈ

- ការណែនាំ និងអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យយល់ដឹងអំពីផលប៉ះពាល់នៃការចោលសំរាមទៅក្នុង ទឹក និងផលប៉ះពាល់ដល់សុខភាព
- ការកាត់បន្ថយសារធាតុគីមី និងសារធាតុពុល (ជីគីមី ឬថ្នាំសម្លាប់សត្វល្អិត) ព្រោះវាជាធាតុសំខាន់មួយ ដែលអាចបំពុលទឹកដោយសារកសិករភាគច្រើនបានប្រើប្រាស់សារធាតុទាំងនេះយ៉ាងទូលំទូលាយនៅ ក្នុងវិស័យកសិកម្ម[47]។
- កម្រិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវពីប្រភពទាំងឡាយ
- ហាមឃាត់ដាច់ខាតនូវការចោលសំរាម ការបង្ហូរកាកសំណល់រឹង រាវ និងសារធាតុផ្សេងៗដែលងាយបង្ក គ្រោះថ្នាក់ចូលទៅក្នុងតំបន់ដែលមានទឹក និងប្រព័ន្ធលូសាធារណៈ
- ហាមដាច់ខាតនូវការបង្ហូរទឹកចេញពីលំនៅដ្ឋាន រោងចក្រ សហគ្រាស ដោយពុំឆ្លងកាត់ប្រព័ន្ធលូ សាធារណៈ ឬប្រព័ន្ធចម្រោះសំអាតនានា។[48]
- រៀបចំឱ្យអាងប្រព្រឹត្តកម្ម ឬអាងចម្រោះសំអាតមុននឹងបង្ហូរទឹកសម្អុយ ឬទឹកកខ្វក់ចូលទៅក្នុងប្រភពទឹក
- ត្រូវចាត់វិធានការឱ្យបានតឹងរឹងបំផុត និងត្រូវផាកពិន័យ ឬផ្តន្ទាទោសតាមច្បាប់ចំពោះជនណាដែលមិន គោរពនឹងអនុវត្តតាម។

#### ២.២.៣.២. ដំណោះស្រាយពាក់ព័ន្ធការបំពុលដី

ដើម្បីដោះស្រាយបញ្ហានៃការបំពុលដី យើងគប្បីត្រូវមានវិធានការ ឬចំណាត់ការដូចជាៈ

- ណែនាំអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យមានការយល់ដឹងអំពីផលប៉ះពាល់បរិស្ថាន និងការបំពុលដី ដែលអាចនាំឱ្យមានបញ្ហាដល់សុខភាពរបស់មនុស្សសត្វ និងរុក្ខជាតិ

[46] https://km.warbletoncouncil.org/tipos-contaminacion-acustica-16274 ដកស្រង់ថ្ងៃទី០២ ខែខែមិថុនា ឆ្នាំ២០២៣។

[47] https://www.postposmo.com/km/ ដកស្រង់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣។

[48] មាត្រា៤ មាត្រា៨និងមាត្រា៩ អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១

- ត្រូវសិក្សាស្វែងយល់អំពីធាតុផ្សំពីជីគីមី និងការប្រើប្រាស់ជីគីមីត្រូវប្រើក្នុងបរិមាណមួយដែលសមល្មម
- ការកាត់បន្ថយការប្រើប្រាស់ជីគីមីដោយប្រើជីធម្មជាតិ (ជីកំប៉ុស) ជំនួសវិញ
- ហាមឃាត់រាល់សកម្មភាពនៃការចាក់សំរាម និងសំណល់រឹងរាវចោលទៅលើដី
- ការកែច្នៃកាកសំណល់ ឬសំរាមឡើងវិញ
- ហាមដាច់ខាតមិនត្រូវឱ្យមានការបង្ហូរទឹកល្អូ ឬទឹកកង្វក់ចូលទៅលើដី
- ត្រូវមានការរៀបចំកន្លែងទុកដាក់សំរាមឱ្យបានត្រឹមត្រូវ និងមានអនាម័យ
- ត្រូវចាត់វិធានការឱ្យបានតឹងរឹងបំផុត និងត្រូវផាកពិន័យ ឬផ្តន្ទាទោសតាមច្បាប់ចំពោះជនណាដែលមិនគោរពនឹងអនុវត្តតាម។[49]

**២.២.៣.៣. ដំណោះស្រាយពាក់ព័ន្ធការបំពុលខ្យល់**

ចំពោះបញ្ហានៃការបំពុលខ្យល់នេះ យើងក៏មានវិធានការ និងដំណោះស្រាយផងដែរដូចជា៖

- កាត់បន្ថយការប្រើប្រាស់យានយន្តចាស់ៗ ដោយប្រើប្រាស់មធ្យោបាយសាធារណៈជំនួសវិញដូចជារថយន្តក្រុងថ្មីៗ
- កាត់បន្ថយយានយន្តដែលប្រើប្រាស់ប្រេងឥន្ធនៈ ដោយជំនួសមកវិញយានយន្តដែលប្រើប្រាស់ថាមពលអគ្គិសនី
- កាត់បន្ថយការកាប់ ឬការដុតបំផ្លាញព្រៃឈើ
- ណែនាំអប់រំប្រជាពលរដ្ឋឱ្យមានការយល់ដឹងពីផលប៉ះពាល់នៃការបំពុលខ្យល់
- ជំរុញឱ្យមានប្រព័ន្ធបន្សុទ្ធខ្យល់
- ត្រូវប្រើប្រាស់ថាមពលធម្មជាតិដូចជា ចរន្តទឹកហូរ ខ្យល់ ដើម្បីយកមកធ្វើជាចរន្តអគ្គិសនី ដោយកាត់បន្ថយការប្រើប្រាស់ធ្យូងថ្ម
- ហាមឃាត់ដាច់ខាតនូវការបញ្ចេញសារធាតុពុលទៅក្នុងបរិយាកាស
- ហាមឃាត់ការនាំចូល និងផលិតនូវសារធាតុឆេះ ដែលមានជាតិស្ពាន់ធ័រ
- ហាមឃាត់ការបញ្ចេញវិទ្យុសកម្ម ឬសារធាតុគីមីទៅក្នុងបរិយាកាស។
- ត្រូវចាត់វិធានការឱ្យបានតឹងរឹងបំផុត និងត្រូវផាកពិន័យ ឬផ្តន្ទាទោសតាមច្បាប់ចំពោះជនណាដែលមិនគោរពនឹងអនុវត្តតាម[50]។

[49] https://www.postposmo.com/km/contaminacion-del-suelo/ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣។

[50] មាត្រា៨ មាត្រា១០ និងមាត្រា១២ អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០០

### ២.២.៣.៤. ដំណោះស្រាយពាក់ព័ន្ធការបំពុលសំណល់រឹង រាវ

ជាទូទៅកាលណាមានហេតុបង្ក និងនាំឱ្យមានផលប៉ះពាល់ហើយនោះ ដូច្នេះដំណោះស្រាយក៏ត្រូវតែមានដូចគ្នាដែរ។ ដោយសារតែឃើញមានផលប៉ះពាល់ពីការបំពុលសំណល់រឹងរាវយ៉ាងខ្លាំង ដូច្នេះហើយរាជរដ្ឋាភិបាលក៏បានស្វែងរកនូវដំណោះស្រាយ និងការទប់ស្កាត់នូវបញ្ហានេះមួយចំនួនដូចជា៖

- រាល់កាកសំណល់រឹងរាវទាំងអស់ត្រូវតែមានការវេចខ្ចប់ អនាម័យ និងទុកដាក់ឱ្យបានត្រឹមត្រូវទៅក្នុងធុងសំរាម
- ការកែច្នៃកាកសំណល់ផ្ទះបាយ ឬសំណល់សិរីរាង្គ ដោយបំលែងទៅជាជីកំប៉ុសវិញ
- កាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក ដោយជំនួសមកវិញការប្រើប្រាស់ថង់ក្រដាសវិញ
- កាត់បន្ថយនូវការចោលសំណល់រឹងនូវទីលានចាក់សំរាម
- ជំរុញឱ្យប្រជាពលរដ្ឋប្រើប្រាស់នូវសំរាមដែលអាចកែច្នៃឡើងវិញបាន
- ណែនាំប្រជាពលរដ្ឋឱ្យយល់ដឹងអំពីផលប៉ះពាល់ដល់បរិស្ថានដូចជា ការសម្អាត អនាម័យ ការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកសំរាមសំណល់រឹងទីប្រជុំជនដែលបានរៀបចំទុកក្នុងមូលដ្ឋាន
- អប់រំ និងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងទីប្រជុំជនដែលប្រកបទៅដោយសុវត្ថិភាពបរិស្ថាន
- ចូលរួមដោះស្រាយនូវបញ្ហានានាដែលពាក់ព័ន្ធទៅនឹងការងារសម្អាត ការប្រមូល និងការដឹកជញ្ជូនសំរាមនៅក្នុងទីប្រជុំជន និងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមនូវការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធទៅនឹងគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន[51]។

### ២.២.៣.៥. ដំណោះស្រាយពាក់ព័ន្ធការបំពុលដោយសំឡេង

ចំពោះបញ្ហានៃការបំពុលសំឡេងនេះ យើងក៏មានវិធានការ និងការដោះស្រាយដូចគ្នាដែរក្នុងនោះមានដូចជា:

- កាត់បន្ថយនូវការប្រើប្រាស់សំឡេងមិនថានៅក្នុងផ្ទះ ឬកន្លែងធ្វើការជាដើម
- កាត់បន្ថយនូវការប្រើប្រាស់ស្នូរតន្ត្រី ឬទូរទស្សន៍ដែលមានកម្រិតសំឡេងខ្ពស់ខ្លាំង
- ដែលអាចនាំឱ្យមានផលប៉ះពាល់អ្នកជទៃ ឬសមាជិកក្នុងគ្រួសារ

[51] អនុក្រឹត្យ លេខ ១១៣ អនក្រ.បក.ស្តីពីការការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥

- កម្រិតកំណត់ស្តង់ដារបញ្ចេញសំឡេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកម្រិតកំណត់ស្តង់ដារសំឡេងអតិបរិមាសម្រាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន
- ហាមឃាត់ដាច់ខាតនូវការបង្កឱ្យមានសំឡេង ដែលមានឆ្លើយតបទៅនឹងកម្រិតកំណត់ស្តង់ដារ
- ត្រូវចាត់វិធានការឱ្យបានតឹងរឹងបំផុត និងត្រូវផាកពិន័យ ឬផ្តន្ទាទោសតាមច្បាប់ចំពោះជនណាដែលមិនគោរពនឹងអនុវត្តតាម។[52]

[52] មាត្រា៣ មាត្រា៧និងមាត្រា៩ នៃអនុក្រឹត្យ លេខ៤២ ស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់ និងរំខានដោយសំលេង ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០០

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវយ៉ាងលម្អិតអំពីប្រធានបទខាងលើរួចមក យើងអាចសន្និដ្ឋានបានថាកត្តាដែលនាំមានការរៀបចំសណ្តាប់ធ្នាប់នៅក្នុងខណ្ឌច្បារអំពៅនេះ គឺបណ្តាលមកពីភាពខ្វះខាត ការកើនឡើងនូវកំណើនប្រជាជន ព្រមទាំងកត្តាសេដ្ឋកិច្ច កត្តាសង្គម ស្ថានភាពសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងបញ្ហាការកកស្ទះចរាចរណ៍។ ដោយឡែកសកម្មភាពការរៀបចំសណ្តាប់ធ្នាប់នៅក្នុងខណ្ឌច្បារអំពៅ គឺពិតជាបានផ្តល់ផលប្រយោជន៍ដល់ការប្រកបរបរប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្នុងតំបន់នេះបានយ៉ាងល្អ ងាយស្រួលប្រកបអាជីវកម្ម បំពេញតម្រូវការរបស់ប្រជាពលរដ្ឋ មានសោភ័ណភាព សុវត្ថិភាព របៀបរៀបរយនៅក្នុងខណ្ឌនេះផងដែរ។ មិនតែប៉ុណ្ណោះប្រជាពលរដ្ឋក៏បានចូលរួមយកចិត្តទុកដាក់សហការជាមួយ និងមន្ត្រីគ្រប់ជាន់ថ្នាក់ដើម្បីធ្វើយ៉ាងណាឱ្យខណ្ឌនេះដំណើរការអភិវឌ្ឍ ការរៀបចំសណ្តាប់ធ្នាប់បានល្អ។ យ៉ាងណាមិញ ខណ្ឌច្បារអំពៅបានរីកចម្រើន និងអភិវឌ្ឍន៍ស្ទើរតែគ្រប់វិស័យក៏ពិតមែន ក៏ប៉ុន្តែយើងសង្កេតឃើញថា ការរៀបចំសណ្តាប់ធ្នាប់អាចប្រកបដោយនិរន្តរភាពបានត្រូវឈរក្រោមសសរស្តម្ភចំនួន៥ដូចជា៖ ផលិតភាព និរន្តរភាព ភាពដែលអាចរស់នៅបាន ភាពជាអ្នកដឹកនាំ ការរចនាដ៏ល្អប្រសើរ។ ហើយបញ្ហាទាំងនេះរដ្ឋបាលខណ្ឌច្បារអំពៅកំពុងយកចិត្តទុកដាក់ដោយរៀបចំឱ្យមានការកែប្រែ ការសាងសង់កសាង ហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត ដើម្បីឱ្យខណ្ឌច្បារអំពៅនេះមានសណ្តាប់ធ្នាប់ល្អ និងកាត់បន្ថយនូវបញ្ហាបរិស្ថាន។ លើសពីនេះទៅទៀត យើងដឹងរួចមកហើយថា នៅក្នុងខណ្ឌច្បារអំពៅនេះ គឺតែងតែជួបប្រទះបញ្ហាដែលជាហេតុនាំឱ្យមានការបំពុលបិស្ថាននៅក្នុងខណ្ឌមួយនេះ ដោយសារតែបណ្តាលមកពីការបំពុលទាំង៥មានដូចជា ការបំពុលទឹក ការបំពុលដី ការបំពុលខ្យល់ ការបំពុលដោយសំណល់រឹង រាវ និងការបំពុលដោយសម្លេង។ មួយវិញទៀត កំណើនប្រជាជន និងប្រព័ន្ធបង្ហូរលូទឹកស្អុយមិនទាន់មានភាពត្រឹមត្រូវ ការកកស្ទះសំរាម កម្មេចកម្មីនៃការកសាង ឬការជួសជុលប្រព័ន្ធផ្លូវថ្នល់ មិនទាន់ត្រឹមត្រូវទៅតាមស្តង់ដារ ដែលជាហេតុនាំឱ្យមានការខូចខាត លិចលង់ ហើយជាពិសេសទៀតនោះ គឺធ្វើឱ្យមានភាពខ្វះខាត ទៅលើការរៀបចំប្រព័ន្ធលូ នៅតាមភូមិ ឬសង្កាត់នីមួយៗជូនប្រជាពលរដ្ឋ ដែលជាហេតុនាំឱ្យប្រជាពលរដ្ឋរស់នៅទីនោះមានការលំបាក និងការប្រកបការងារអាជីវកម្មផងដែរ។ ដោយសារតែបញ្ហានេះហើយ ទើបរដ្ឋបាលខណ្ឌបាន យកចិត្តទុកដាក់ទៅលើបញ្ហាការបំពុលទាំង៥នេះ គឺសុទ្ធតែជាផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅដល់បរិស្ថាន ព្រមទាំងសុខភាពរបស់ប្រជាជន ជាពិសេសសោភ័ណភាពនៅក្នុងខណ្ឌច្បារអំពៅ និងមានការធ្លាក់ចុះ ប្រសិនបើមិនមានការដោះស្រាយឱ្យបានឆាប់រហ័សទនោះ។

ដូច្នេះក្រោយពីបានសិក្សាស្រាវជ្រាវទៅលើប្រធានបទសារណា **ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានក្នុងខណ្ឌច្បារអំពៅ** គឺបានធ្វើឱ្យយើងខ្ញុំយល់កាន់តែច្បាស់អំពីបុព្វហេតុដែលនាំឱ្យមានការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានក្នុងខណ្ឌច្បារអំពៅ ព្រមទាំងយល់ដឹងពីសារៈសំខាន់នៃការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានផងដែរ។

# ការផ្តល់អនុសាសន៍

# ការផ្តល់អនុសាសន៍

យោងតាមការបកស្រាយខាងលើឃើញថា ថ្វីត្បិតតែអភិបាល និងអាជ្ញាធរខណ្ឌបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការរៀបចំ និងអភិវឌ្ឍន៍ខណ្ឌពិតមែន ប៉ុន្តែឃើញថាការរៀបចំ និងអភិវឌ្ឍន៍នេះបានជួបបញ្ហាប្រឈម និងនៅមានចំណុចខ្វះខាតជាច្រើន ហើយមិនទាន់បានបំពេញតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ បញ្ហានេះផងដែរ ជាបញ្ហាដែលប្រជាពលរដ្ឋ ចង់ឱ្យអាជ្ញាធរធ្វើការដោះស្រាយ និងកែលម្អ ជាពិសេសទាក់ទងទៅនឹងបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ និងបរិស្ថាន។ ដើម្បីដោះស្រាយនឹងបញ្ហាទាំងនេះ នាងខ្ញុំទាំងពីរសូមផ្តល់មតិយោបល់ និងសំណូមពរមួយចំនួនដូចតទៅៈ

- អាជ្ញាធរគ្រប់ជាន់ថ្នាក់ គួរតែយកចិត្តទុកដាក់ឱ្យបានខ្ពស់ទៅលើបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ និងបង្កើតការបង្ក្រាប ក៏ដូចជាទប់ស្កាត់នូវបញ្ហាចោរកម្ម ល្បែងស៊ីសងគ្រប់ប្រភេទ ក្មេងទំនើង ដើម្បីកុំឱ្យមានផលប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ និងបរិយាកាសក្នុងខណ្ឌ។
- អាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ចគួរចេញនូវវិធានការអប់រំផ្សព្វផ្សាយ ឱ្យបានទូលំទូលាយទៅដល់ប្រជាពលរដ្ឋដោយសារប្រើគ្រប់មធ្យោបាយ ដើម្បីឱ្យយល់ដឹង និងសហការជាមួយប្រជាពលរដ្ឋឱ្យបានស៊ីជម្រៅក្នុងការចុះអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- អាជ្ញាធរមានសមត្ថកិច្ចគួរតែលើកទឹកចិត្តឱ្យមាននូវការលើកឡើងនូវមតិយោបល់ជាសាធារណៈពាក់ព័ន្ធទៅនឹងបញ្ហាចរាចរណ៍ ដើម្បីជាការវិភាគមួយក្នុងការស្វែងយល់ពីចន្លោះប្រហោង ចំណុចខ្វះខាត ដើម្បីបំពេញបន្ថែម ឬកែលម្អ ដើម្បីប្រសិទ្ធិភាព និងនិរន្តរភាព។
- អាជ្ញាធរ ឬស្ថាប័នដែលមានសមត្ថកិច្ច គួរតែយកចិត្តទុកដាក់ទៅលើបញ្ហានៃការគ្រប់គ្រងសំរាមឱ្យទទួលបានទាំងប្រសិទ្ធិភាព និងប្រសិទ្ធិផល
- ត្រូវមានការរៀបចំសកម្មភាពក្នុងការចុះអប់រំ ផ្សព្វផ្សាយ ទៅដល់ប្រជាពលរដ្ឋឱ្យមានការយល់ដឹងកាន់តែច្បាស់អំពីបញ្ហាសំរាម និងគុណភាពវិបត្តិរបស់វាដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់យើងទាំងអស់គ្នា ជាពិសេសអ្នកដែលរស់នៅជិតកន្លែងដាក់សំរាម។
- រដ្ឋបាលខណ្ឌ និងមន្ត្រីគ្រប់ជាន់ថ្នាក់ត្រូវយកចិត្តទុកដាក់ពង្រឹង អប់រំ ក៏ដូចជាណែនាំប្រជាពលរដ្ឋឱ្យយល់ដឹងអំពី សេចក្តីណែនាំស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ ដើម្បីជៀសវាងនូវការបំពុលបរិស្ថាន។

- ការណែនាំផ្សព្វផ្សាយនេះ រដ្ឋបាលខណ្ឌត្រូវណែនាំប្រជាពលរដ្ឋឱ្យចេះញែក វេចខ្ចប់ ទុកដាក់ និងការបញ្ចេញសំរាមសំណល់រឹងឱ្យមានសណ្តាប់ធ្នាប់ ហើយមិនតែប៉ុណ្ណោះមុននិងបញ្ចេញសំរាមត្រូវសម្រិតទឹកចេញដាក់ចូលទៅក្នុងប្រព័ន្ធលូឱ្យបានត្រឹមត្រូវ។
- ត្រូវញែកសំរាមជា២ប្រភេទឱ្យដាច់ពីគ្នាគឺ សំរាមសើម និងសំរាមស្ងួតមុននឹងបោះចោលក្នុងធុងសំរាម ការធ្វើបែបនេះមិនត្រឹមតែធ្វើឱ្យបរិស្ថានគ្មានការបំពុលទេ គឺថែមទាំងធ្វើឱ្យទីក្រុងមានសោភ័ណភាពល្អស្អាតមួយកម្រិតទៀត។
- រដ្ឋបាលខណ្ឌ និងមន្ត្រីគ្រប់ជាន់ថ្នាក់ទាំងអស់ត្រូវអនុវត្តយ៉ាងតឹងរឹងបំផុតចំពោះជនណាដែលមិនគោរព ឬអនុវត្តតាមដែលនាំមានការបំពុលបរិស្ថានព្រមទាំងខូចសោភ័ណភាពនៅទីក្រុងនោះ ត្រូវដាក់ទោស ឬផាកពិន័យជននោះ។

# ឯកសារយោង

# ឯកសារយោង

**១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**

- ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៥។
- ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត មាត្រា៦។
- ច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អនុក្រឹត្យ លេខ៥៧៩ អនក្រ.បក ស្តីពីការបង្កើតខណ្ឌច្បារអំពៅនៃរាជធានីភ្នំពេញ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ២០១៣។
- គោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព អនុក្រឹត្យលេខ០១
- កថាខណ្ឌទី២ នៃមាត្រា១១ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ២០១៧
- មាត្រា១១ នៃច្បាប់ស្តីចរាចរណ៍ផ្លូវគោកឆ្នាំ២០១៧
- អនុក្រឹត្យលេខ៣១៨ ស្តីពីការតែងតាំងមន្ត្រីរាជការ ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២១។
- អនុក្រឹត្យលេខ៣៩ អនក្រ.បក ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ មាត្រា៦ថ្មី មាត្រា៧ថ្មី មាត្រា៨ថ្មី មាត្រា៩ថ្មី មាត្រា១០ថ្មី មាត្រា១១ថ្មី និងមាត្រា១២ថ្មី។
- មាត្រា៣ នៃអនុក្រឹត្យ លេខ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ ១៩៩៦។
- មាត្រា៤ អនុក្រឹត្យលេខ២៣៥ អនក្រ.បក ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ចុះ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧
- មាត្រា៤ មាត្រា៨ និងមាត្រា៩ អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ចុះថ្ងៃ ទី២៧ ខែមេសា ឆ្នាំ២០២១
- អនុក្រឹត្យលេខ១១៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥
- មាត្រា៣ មាត្រា៧និងមាត្រា៩ នៃអនុក្រឹត្យ លេខ៤២ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងរំខាន ដោយសំលេង ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០០
- មាត្រា៨ មាត្រា១០ និងមាត្រា១២ អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០០

**២. ប្រកាស និងសារាចរណ៍**

- ប្រកាស ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ លេខ៤៦៦១ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២។

**៣. សៀវភៅ**

- សៀវភៅ នីតិនគរូបនីយវិទ្យា, សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា បោះពុម្ព ឆ្នាំ២០២៣ ទំព័រទី១ ទំព័រទី១៦ ទំព័រទី១៧ ទំព័រទី៤៥ ទំព័រទី៥១ និងទំព័រទី៥២។
- សៀវភៅការគ្រប់គ្រងរដ្ឋបាល សាលាខណ្ឌច្បារអំពៅ ឆ្នាំ២០១៤ ទំព័រទី៦ទំព័រទី៦៤ ទំព័រទី៦៥ និងទំព័រទី៦៥។

**៤. វចនានុក្រម**

- វចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត

**៥. គេហទំព័រ**

- តើបរិស្ថានគឺជាអ្វី – អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (bcv-cambodia.org)ដកស្រង់ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣
- https://phnompenh.gov.kh/phnom-penh-city/facts/ ដកស្រងថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣
- https://phnompenh.gov.kh/phnom-penh-city/facts/ដកស្រងថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៣
- https://khmer.voanews.com/amp/phnom-penh-chronic-traffic-congestion-consumes-its-residents-time-economic-and-mental-wellbeing/6714438.html ដកស្រង់នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣។
- អភិបាលខណ្ឌច្បារអំពៅ ក្រើនរំលឹកសមត្ថកិច្ចទូទាំងខណ្ឌ-សង្កាត់ ត្រូវរួមគ្នាខិតខំពង្រឹងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព ឱ្យបានម៉ឺងម៉ាត់បំផុត (freshnewsasia.com) ដកស្រង់ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣។
- https://opendevelopmentcambodia.net/km/topics/pollution-and-waste/ដកស្រង់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣។
- https://www.khsearch.com/qna/5780 ស្រង់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣។
- https://freshnewsasia.com/index.php/en/localnews/273693-2023-01-11-09-32-24.html ដកស្រង់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣។

- https://comped-cam.org/Documents/developmentguideline/Environmental.pdf ដកស្រង់ថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០២៣។
- https://km.warbletoncouncil.org/tipos-contaminacion-acustica-16274 ដកស្រង់ថ្ងៃទី០២ ខែ ខែមិថុនា ឆ្នាំ២០២៣។
- https://km.hesperian.org/hhg/A_Community_Guide_to_Environmental_Health ដកស្រង់ថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០២៣។
- https://km.eferrit.comនិយមន័យការបំពុលខ្យល់
- https://km.warbletoncouncil.org/contaminacion-del-suelo-3188 ដកស្រង់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣។
- https://opendevelopmentcambodia.net/km/topics/air-pollution/ដកស្រង់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣។
- https://opendevelopmentcambodia.net/km/topics/solid-waste/ដកស្រង់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣។
- https://www.postposmo.com/km/ ដកស្រង់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣។
- https://khmerpostasia.com/archives/92340 ដកស្រង់ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២៣។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ

### ឧបសម្ព័ន្ធ១



# ឧបសម្ព័ន្ធ២



សកម្មភាពកម្លាំងរដ្ឋបាលខណ្ឌច្បារ
អំពៅ ចុះត្រួតពិនិត្យអាវុធជាតិផ្ទុះ




សកម្មភាពកម្លាំងសណ្តាប់ធ្នាប់ខណ្ឌ
ចុះស្តាលូបង្ហូរទឹកភ្លៀង



សកម្មភាពចុះបូមលូកកស្ទះនៅ
ចំណុចផ្សារបឹងព្រលឹត



សកម្មភាពកម្លាំងសណ្តាប់ធ្នាប់ខណ្ឌ
ចុះស្តាលូបង្ហូរទឹកភ្លៀង

## ឧបសម្ព័ន្ធ៣



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៧៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតខណ្ឌច្បារអំពៅ នៃរាជធានីភ្នំពេញ

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ត្រូវចាត់តាំងឱ្យមានចលនាប្រឡងប្រណាំងបង្កើតស្នាដៃប្រចាំឆ្នាំនីមួយៗ សំដៅស្វែងរកអង្គភាព និងបុគ្គលដែលខិតខំព្យាយាមពុះពារបំពេញកាតព្វកិច្ច ហើយបង្កើតបានជាស្នាដៃធំធេងធ្វើជាគំរូក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ។

៨. គ្រប់ក្រសួង ស្ថាប័ន និងគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ ត្រូវចាត់តាំងប្រជុំបូកសរុប រយៈពេលយ៉ាងយូរ០៦ខែម្តង ដើម្បីមានមូលដ្ឋានក្នុងការវាយតម្លៃ ដកពិសោធន៍ និងដាក់ចេញទិសដៅអនុវត្តបន្ត។

ត្រូវធ្វើរបាយការណ៍បូកសរុបលទ្ធផលអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្ញើមកលេខាធិការដ្ឋានក្រសួងមហាផ្ទៃ។

៩. គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រដ្ឋបាលឃុំ សង្កាត់ ត្រូវមានក្រុមប្រឹក្សាប្រឡងប្រណាំង ដើម្បីបំផុសចលនាប្រឡងប្រណាំង និងពិនិត្យបូកសរុប វាយតម្លៃអង្គភាព និងបុគ្គលដែលមានស្នាដៃក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។

១០.គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានការគិតគូរគ្រោងថវិកាសម្រាប់អនុវត្តផែនការសកម្មភាពពាក់ព័ន្ធនឹងគោលនយោយបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» នៅក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់សាមីក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នីមួយៗ។

គោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវបានយកទៅផ្សព្វផ្សាយទូលំទូលាយទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋដើម្បីយល់ជ្រួតជ្រាប និងចូលរួមគាំទ្រអនុវត្តប្រកបដោយជោគជ័យ។

ថ្ងៃ អង្គារ ១៣ កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល៖**</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-សម្តេច ឯកឧត្តម លោកជំទាវប្រធានក្រុមការងាររាជរដ្ឋាភិបាល
ចុះមូលដ្ឋានរាជធានី ខេត្ត
-គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញ អាជ្ញាធរ គ្រឹះស្ថានសាធារណៈ
រដ្ឋបាលថ្នាក់ក្រោមជាតិ
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធ៤**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: [illegible]

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងមន្ត្រីរាជការចំនួន ០៣រូប ជាអភិបាលនៃគណៈអភិបាលខណ្ឌ នៃរាជធានីភ្នំពេញ សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដែល ដូចមានរាយនាមខាងក្រោម ៖

១-លោក **សុខ ពេញវុធ** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ ជាអភិបាល នៃគណៈអភិបាលខណ្ឌដូនពេញ

២-លោក **ខេង មុនីរ៉ា** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦ ជាអភិបាល នៃគណៈអភិបាលខណ្ឌច្បារអំពៅ

៣-លោក **ម៉ុង ម៉ានិត** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ ជាអភិបាល នៃគណៈអភិបាលខណ្ឌសែនសុខ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៤៦៦១ ប្រក

## ប្រកាស

### ស្តីពី

### ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងលិខិតលេខ ២៣៤/២២ លស.ធ.ក្រ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២ របស់រដ្ឋបាលរាជធានីភ្នំពេញ

## សម្រេច

**ប្រការ ១.—**

ត្រូវបានផ្ទេរភារកិច្ចមន្ត្រីរាជការចំនួន ១២រូប ជាអភិបាលរង នៃគណៈអភិបាលខណ្ឌនានា ក្នុងរាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម ៖

១-លោកស្រី **លី រ៉ូហ្សាមី** ឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ១ ពីអភិបាលរង នៃគណៈអភិបាលខណ្ឌសែនសុខ ទៅជាអភិបាលរង នៃគណៈអភិបាលខណ្ឌជ្រោយចង្វារ

២-លោក **កែវ សំណាង** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ ពីអភិបាលរង នៃគណៈអភិបាលខណ្ឌចំការមន ទៅជាអភិបាលរង នៃគណៈអភិបាលខណ្ឌមានជ័យ។

| | |
|---|---|
| ៨-លោកស្រី **ខុន ខេម៉ា** | ឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌជ្រោយចង្វារ |
| ៩-លោកស្រី **ហ្វូត ឃីម** | ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ២ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌមានជ័យ |
| ១០-លោក **ឌី សុខខែម** | ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ៤ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌមានជ័យ |
| ១១-លោក **គៀវ ចក់** | ឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៥ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌមានជ័យ |
| ១២-លោក **កេត ឧត្តម** | ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌ៧មករា |
| ១៣-លោក **យិន គា** | ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌពោធិ៍សែនជ័យ |
| ១៤-លោក **ផុន សុផាន** | ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ២ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌពោធិ៍សែនជ័យ |
| ១៥-លោក **ញាណ ច័ន្ទសោភា** | ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ១ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌច្បារអំពៅ |
| ១៦-លោក **ម៉ុក ពុទ្ធា** | ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ១ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌច្បារអំពៅ |
| ១៧-លោក **ឡាយ ស៊ីទិន** | ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ៣ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌច្បារអំពៅ |
| ១៨-លោក **លឹម ចាន់ដារុធ** | ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៣ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌកំបូល |
| ១៩-លោក **ទ្រី ណារ៉ែត** | ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ៣ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌកំបូល |
| ២០-លោក **គន់ ចាន់សុតារី** | ឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌកំបូល |
| ២១-លោក **ឆាយ ទាសនា** | ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ៤ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌសែនសុខ |
| ២២-លោកស្រី **មុិល សោភ័ណនារី** | ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌសែនសុខ |
| ២៣-លោក **ញាណ ចន្ទាទេវ៉ា** | ឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌសែនសុខ |
| ២៤-លោក **ឃុត សុខខា** | ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ១ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌសែនសុខ |
| ២៥-លោក **សុខ ទីរៈ** | ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌបឹងកេងកង។ |

២៦-លោក **ជ្រុន ផៅរ៉ាវឌឿ** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌបឹងកេងកង

២៧-លោក **ហ៊ិត ង៉ាន់ធី** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌចំការមន

២៨-លោក **ជិន ទិចិត្រ** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ២ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌចំការមន

២៩-លោក **ម៉ៅ បូណែត** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ១ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌចំការមន

៣០-លោក **ចាប ឌីណា** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ១ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌដូនពេញ

៣១-លោក **សន សោភ័ណ្ឌ** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌឫស្សីកែវ

៣២-លោក **រ៉ិន សុឃីម** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៤ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌឫស្សីកែវ

៣៣-លោក **ម៉ិត បូទណ្ណារ័ត្ន** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៤ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌឫស្សីកែវ

៣៤-លោក **ស្មាស់ រិទ្ធី** ឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌឫស្សីកែវ

៣៥-លោក **ស៊ឹម សុផល់** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ១ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌទួលគោក

៣៦-លោក **ឈាង ឡុទ្ធី** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ ជាអភិបាលរង នៃគណៈអភិបាលខណ្ឌទួលគោក។

**ប្រការ ៣.—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤.—**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយក នៃអគ្គនាយកដ្ឋានកស្តុភារ និងហិរញ្ញវត្ថុ ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានីភ្នំពេញ ប្រធាននាយកដ្ឋានបុគ្គលិក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ និងសាមីខ្លួនដូចមានឈ្មោះក្នុងប្រការ១ និងប្រការ២ខាងលើ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៣រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ

  «ដើម្បីជូនជ្រាប»

- ដូចប្រការ ៤
- ឯកសារ - កាលប្បវត្តិ